ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 10

# របាយការណ៍ហិរញ្ញវត្ថុសមាស

## Consolidated Financial Statements

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនកម្មផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

៚៚ 🙞 ៚៚

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**"។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន "*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* " និង "*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*" ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ទី តាឃី**

## គោលបំណង

១ គោលបំណង នៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះគឺ ដើម្បីកសាងគោលការណ៍សម្រាប់ការបង្ហាញ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាស នៅពេលដែលអង្គភាពអភិបាលលើអង្គភាពមួយឬច្រើន។

## ការឆ្លើយតបទៅនឹងគោលបំណង

២ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៅក្នុងកថាខណ្ឌ ១ ស្តង់ដាររបាយ-ការណ៍ ហិរញ្ញវត្ថុអន្តរជាតិនេះ÷

(ក) តម្រូវឲ្យអង្គភាព (ក្រុមហ៊ុនមេ) ដែលអភិបាលលើអង្គភាពមួយ ឬច្រើនផ្សេងទៀត (ក្រុមហ៊ុនបុត្រសម្ព័ន្ធ) ដើម្បីដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសមាស

(ខ) កំណត់អំពីគោលការណ៍នៃ*ការគ្រប់គ្រង*, និងបង្កើតអភិបាលភាព (ការអភិបាល) ដែលជាមូលដ្ឋាននៃការរួមបញ្ចូល

(គ) កំណត់អំពីរបៀបអនុវត្តន៍គោលការណ៍នៃអភិបាលភាព ដើម្បីកំណត់ថាតើវិនិយោគិនអភិបាលក្រុមហ៊ុនទទួលដែលការវិនិយោគយ៉ាងដូចម្តេច និងហេតុដូច្នេះ ត្រូវរួមបញ្ចូលក្រុមហ៊ុន ដែលទទួលការវិនិយោគ

(ឃ) កំណត់អំពីការតម្រូវផ្នែកគណនេយ្យសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាស។

៣ ស្តង់ដាររបាយការណ៍នេះមិនទាក់ទងនឹងការតម្រូវផ្នែកគណនេយ្យ សម្រាប់សមាយោគអាជីវកម្មនិងផលប៉ះពាល់ របស់វាលើការរួមបញ្ចូល ដោយរួមមាន មូលនិធិពាណិជ្ជកម្មដែលកើតមកពីសមាយោគអាជីវកម្ម (មើលស្តង់ដាររបាយការណ៍អន្តរជាតិ ៣ *សមាយោគអាជីវកម្ម*) ។

៤ អង្គភាពដែលជាក្រុមហ៊ុនមេ ត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសមាស។ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះអនុវត្តន៍ចំពោះគ្រប់អង្គភាពទាំងអស់ លើកលែងតែដូចខាងក្រោមៈ

(ក) ក្រុមហ៊ុនមេមិនចាំបាច់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសមាសឡើយ ប្រសិនបើ វាបំពេញបានតាមលក្ខខណ្ឌទាំង អស់ដូចខាងក្រោមៈ

(១) វាគឺជាក្រុមហ៊ុនបុត្រសម្ពន្ធ័ ដែលមានកម្មសិទ្ធិទាំងស្រុង ឬ ក្រុមហ៊ុនបុត្រសម្ពន្ធ័ដែលមានកម្មសិទ្ធិមួយផ្នែកនៃអង្គភាព ផ្សេងទៀត និងបណ្តាម្ចាស់កម្មសិទ្ធិផ្សេងទៀត ដោយរួមមាន បណ្តាអ្នកទាំងឡាយដែលមានសំលេងឆ្នោត, អ្នកដែលនឹង ត្រូវបានជូនដំណឹងអំពី, និងមិនជំទាស់ទៅនឹង, ដែលក្រុម ហ៊ុនមេ មិនបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសមាស

(២) ឧបករណ៍ហិរញ្ញវត្ថុបំណុលនិងទ្រព្យម្ចាស់ មិនត្រូវបានជួញ ដូរនៅក្នុងទីផ្សារសាធារណៈ (ទីផ្សារប្តូរប្រាក់បរទេស ឬ ក្នុងស្រុក ឬទីផ្សារដោះដូរតាមបញ្ជ, ដោយរួមមានទីផ្សារ តំបន់ ឬទីផ្សារក្នុងស្រុក)

(៣) អង្គភាពមិនបានរៀបចំ, និងមិនស្ថិតនៅក្នុងដំណើការ នៃ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ជាមួយគណៈ កម្មការមូលបត្រ ឬអង្គភាពនិយ័តករផ្សេងៗទៀត សម្រាប់ គោលបំណងនៃការបោះផ្សាយ ឧបករណ៍ហិរញ្ញវត្ថុប្រភេទ ណាមួយនៅក្នុងទីផ្សារសាធារណៈ និង

(ឃ) ក្រុមហ៊ុនមេចុងក្រោយឬបន្ទាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាសដែលអាចមានសម្រាប់ការប្រើប្រាស់ របស់មហាជន និងអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

(ខ) ផែនការអត្ថប្រយោជន៍ ក្រោយបញ្ចប់សេវាការងារ ឬផែនការអត្ថប្រយោជន៍និយោជិតរយៈពេលវែង ដែលស្តង់ដារគណនេយ្យអន្តរជាតិ១៩ ត្រូវអនុវត្ត។

## អនុបាលភាព

៥ ក្រុមហ៊ុនវិនិយោគ ដោយមិនគិតពីចរិតលក្ខណៈនៃការពាក់ពន្ធ័ជាមួយអង្គភាព (ក្រុមហ៊ុនទទួលបានការវិនិយោគ), ត្រូវកំណត់ថាតើខ្លួន គឺជាលក្រុមហ៊ុនមេឬយ៉ាងណា ដោយត្រូវធ្វើការវាយតម្លៃថាតើ ខ្លួនធ្វើអភិបាលលើក្រុមហ៊ុនទទួលការវិនិយោគក្នុងកម្រិតណា។

៦ ក្រុមហ៊ុនវិនិយោគធ្វើអភិបាលលើក្រុមហ៊ុនរងការវិនិយោគនៅពេលដែលខ្លួនត្រូវប្រឈម ឬ មានសិទ្ធិចំពោះប្រាក់ចំណេញពីការវិនិយោគអថេរជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ និងមានលទ្ធភាពធ្វើឱ្យមានឥទ្ធិពលដល់ប្រាក់ចំណេញទាំងនោះតាមរយៈសិទ្ធិអំណាចរបស់ខ្លួនលើក្រុមហ៊ុនទទួលការវនិយោគ។

៧ ដូច្នេះ, ក្រុមហ៊ុនវិនិយោគធ្វើអភិបាល លើក្រុមហ៊ុនរងការវិនិយោគក្នុងករណីនិងតែក្នុងករណី ក្រុមហ៊ុនវិនិយោគ មានលក្ខណៈទាំងអស់ ដូចខាងក្រោមៈ

**(ក) មានសិទ្ធិអំណាចទៅលើក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌ ១០-១៤)**

**(ខ) មានការប្រឈម ឬសិទ្ធិ ចំពោះប្រាក់ចំណេញពីការវិនិយោគអថេរ ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ (មើល កថាខណ្ឌ១៥ និង ១៦)**

**(គ) មានលទ្ធភាពប្រើសិទ្ធិអំណាចរបស់ខ្លួនទៅលើក្រុមហ៊ុនរងការ វិនិយោគដើម្បីធ្វើឲ្យមានផលប៉ះពាល់ដល់ ប្រាក់ចំណេញរបស់ ក្រុមហ៊ុនវិនិយោគ (មើល កថាខណ្ឌ១៧ និង១៨)។**

៨ ក្រុមហ៊ុនវិនិយោគត្រូវពិចារណារាល់នហេតុការណ៍និងកាលៈទេសៈ នៅ ពេលវាយតម្លៃអំពីការអភិបាលរបស់ខ្លួន លើក្រុមហ៊ុនរងការវិនិយោគ។ ក្រុមហ៊ុនវិនិយោគត្រូវធ្វើការវាយតម្លៃឡើងវិញអំពីការអភិបាលរបស់ខ្លួន លើក្រុមហ៊ុនរងការវិនិយោគ ប្រសិនបើហេតុការណ៍ និងកាលៈទេសៈ បង្ហាញថាមានការផ្លាស់ប្ដូរនូវសមាសធាតុ មួយក្នុងចំណោមសមាសធាតុ ទាំងបីនៃការអភិបាល ដែលបានបង្ហាញ នៅក្នុងកថាខណ្ឌ ៧ (មើល កថាខណ្ឌខ ៨០-ខ៨៥)។

៩ ក្រុមហ៊ុនវិនិយោគពីរឬច្រើនធ្វើអភិបាលរួមគ្នាលើក្រុមហ៊ុនរងការវិនិយោគ មួយនៅពេលដែល ពួកគេត្រូវតែធ្វើ សកម្មភាពទាំងអស់គ្នាដើម្បីដឹកនាំ សកម្មភាពដែលពាក់ពន្ធ័។នៅក្នុងករណីនេះ, ដោយសារតែគ្មានក្រុមហ៊ុន វិនិយោគណាមួយអាចដឹកនាំសកម្មភាពដោយមិនមានការសហប្រតិបត្តិការ ពីក្រុមហ៊ុនមួយទៀត, គ្មានក្រុមហ៊ុនវិនិយោគណាមួយធ្វើអភិបាលតែម្នាក់ឯង លើក្រុមហ៊ុនរងការវិនិយោគបានឡើយ។ក្រុមហ៊ុនវិនិយោគនិមួយៗ នឹង

ត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងក្រុមហ៊ុនរងការវិនិយោគដោយយោងតាមស្តង់ដាររបាយការណ៍អន្តរជាតិពាក់ពន្ធ័ដូចជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមគ្នា*, ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ និងអាជីវកម្មរួមទុន* ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ *ឧបករណ៍ហិរញ្ញវត្ថុ*។

## អំណាច

១០ ក្រុមហ៊ុនវិនិយោគមានសិទ្ធិអំណាចលើក្រុមហ៊ុនរងការវិនិយោគ នៅពេលដែល ក្រុមហ៊ុនវិនិយោគនោះមាន សិទ្ធិវិជ្ជមានដែលនឹងផ្តល់ឲ្យខ្លួននូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ មានន័យថា មានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។

១១ អំណាចកតឡើងពីសិទ្ធិ។ ជួនកាលការវាយតម្លៃអំពីអំណាច គឺជារឿងសាមញ្ញ ដូចជា នៅពេលដែលអំណាចមានទៅលើ ក្រុមហ៊ុនទទួលការវិនិយោគគឺទទួលបានដោយផ្ទាល់និងតែតាមសំលេងឆ្នោតដែលបានផ្តល់ឲ្យដោយឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់ ដូចជាសន្លឹកហ៊ុន, និងអាចត្រូវបានវាយតម្លៃដោយការពិចារណា នូវសំលេងឆ្នោតពីអ្នកកាន់កាប់សន្លឹកហ៊ុន។ នៅក្នុងករណីផ្សេងទៀត ការវាយតម្លៃមានភាពស្មុគ្រស្មាញជាងនិងទាមទារនូវការពិចារណានូវកត្តាជាច្រើន ជាឧទាហរណ៍ អំណាចដែលបានមកពីកិច្ចព្រមព្រៀងដែលមានចែងនៅក្នុងកុងត្រាជាដើម។

១២ ក្រុមហ៊ុនវិនិយោគ ដែលមានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័មានអំណាច បើទោះបីជាសិទ្ធិដើម្បីដឹកនាំរបស់ខ្លួនមិនទាន់បាន

ប្រើក៏ដោយ ។ ភស្តុតាង ដែលបញ្ជាក់ថាក្រុមហ៊ុនវិនិយោគកំពុងដឹកនាំសកម្មភាពពាក់ព័ន្ធ អាចជួយកំណត់ថាតើក្រុមហ៊ុនមានអំណាច ឬអត់, ប៉ុន្តែភស្តុតាងនោះ ដោយខ្លួនវាមិនប្រាកដជាកំណត់បានថាតើក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនទទួលវិនិយោគ ឬយ៉ាងណា។

១៣ ប្រសិនបើ ក្រុមហ៊ុនវិនិយោគពីរឬច្រើន ដែលក្រុមហ៊ុននីមួយៗមានសិទ្ធិវិជ្ជមាន ដែលផ្តល់ឱ្យពួកគេនូវលទ្ធភាពជាឯកតោភាគី ដើម្បីដឹកនាំសកម្មភាពពាក់ព័ន្ធផ្សេងៗ, ក្រុមហ៊ុនវិនិយោគដែលមានលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ។

១៤ ក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ បើទោះបីជាអង្គភាពផ្សេងមានសិទ្ធិដែលមានស្រាប់ ដែលផ្តល់ឱ្យពួកគេនូវលទ្ធភាពបច្ចុប្បន្ន ដើម្បីចូលរួមនៅក្នុងការដឹកនាំសកម្មភាពពាក់ព័ន្ធ, ឧទាហរណ៍ នៅពេលអង្គភាពមួយផ្សេងទៀតមានឥទ្ធិពលជាដុំកំភួន។ ទោះជាយ៉ាងណា ក្រុមហ៊ុនវិនិយោគដែលកាន់កាប់តែសិទ្ធិដែលមានការការពារ មិនមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឡើយ (មើលកថាខណ្ឌ ខ២៦-ខ២៨), និងជាផលវិបាក មិនធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគឡើយ។

## ប្រាក់ចំណេញ

១៥ ក្រុមហ៊ុនវិនិយោគដែលត្រូវប្រឈម ឬមានសិទ្ធិ ចំពោះប្រាក់ចំណេញអថេរ ដែលបានមកពីការពាក់ព័ន្ធរបស់ខ្លួនជាមួយក្រុមហ៊ុនរងការ

វិនិយោគ នៅពេលដែលប្រាក់ចំណេញរបស់ក្រុមហ៊ុនវិនិយោគដែលបាន ពីការពាក់ពន្ធ័របស់ខ្លួនមានសក្តានុពលប្រែប្រួល ចំពោះលទ្ធផលនៃការធ្វើ អាជីវកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ។ ប្រាក់ចំណេញរបស់ក្រុមហ៊ុន វិនិយោគ អាចជាវិជ្ជមានទាំងស្រុង អវិជ្ជមានទាំងស្រុង ឬវិជ្ជមាននិង អវិជ្ជមាន។

១៦ ទោះបីជាមានតែក្រុមហ៊ុនវិនិយោគតែមួយគត់ ដែលអាចធ្វើអភិបាលភាព លើក្រុមហ៊ុនទទួលការវិនយោគ, ភាគីច្រើនជាងមួយអាចចែករំលែកនូវ ប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។ ឧទាហរណ៍អ្នកកាន់កាប់ បណ្ណ័ភាគហ៊ុនដែលមិនមានអភិបាលភាពអាចចែករំលែកប្រាក់ចំណេញឬ ការបែងចែកប្រាក់ចំណេញពីក្រុមហ៊ុនទទួលការវិនិយោគ។

**ចំណងទាក់ទងរវាងអំណាចនិងប្រាក់ចំណេញ**

១៧ ក្រុមហ៊ុនវិនិយោគធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ មិនតែ ក្នុងករណីដែលក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ និងមានការដាក់បង្ហាញឬសិទ្ធិទៅលើប្រាក់ចំណេញអថេរដែលបានមកពី ការពាក់ពន្ធ័របស់ខ្លួន ជាមួយក្រុមហ៊ុនរងការវិនិយោគ ប៉ុន្តែវាក៏មាន លទ្ធភាព ប្រើអំណាចរបស់ខ្លួន ដើម្បីធ្វើឱ្យមានផលប៉ះពាល់លើប្រាក់ ចំណេញរបស់ក្រុមហ៊ុនវិនិយោគដែលកើតចេញពីការពាក់ពន្ធ័របស់ខ្លួនជា មួយនឹងក្រុមហ៊ុនរងការវិនិយោគ។

១៨ ដូច្នេះក្រុមហ៊ុនវិនិយោគ ដែលមានសិទ្ធិក្នុងការធ្វើការសម្រេចចិត្ត ត្រូវ កំណត់ថា តើខ្លួនជាក្រុមហ៊ុនមេឬជាភ្នាក់ងារ។ ក្រុមហ៊ុនវិនិយោគ ដែល ជាភ្នាក់ងារ ដោយអនុលោមតាមកថាខណ្ឌ ខ៥៨ - កថាខណ្ឌ ៧២ មិនធ្វើ

អភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគឡើយ នៅពេលដែលខ្លួនអនុវត្តសិទ្ធិនៃការធ្វើការសម្រេចចិត្តដែលបានផ្ដល់ឲ្យខ្លួន។

## ការតម្រូវផ្នែកគណនេយ្យ

**១៩ ក្រុមហ៊ុនមេត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាស ដោយប្រើគោលនយោបាយគណនេយ្យឯករូបសម្រាប់ប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលស្រដៀងគ្នានៅក្នុងកាលៈទេសៈដែលស្រដៀងគ្នា។**

២០ ការរួមបញ្ចូលក្រុមហ៊ុនរងការវិនិយោគត្រូវចាប់ផ្ដើមពីកាលបរិច្ឆេទ ដែលក្រុមហ៊ុនវិនិយោគទទួលបានអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ និងបញ្ចប់ទៅវិញនៅពេលដែលក្រុមហ៊ុនវិនិយោគបាត់បង់អភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ។

២១ កថាខណ្ឌ ខ៨៦ - កថាខណ្ឌ ៩៣ កំណត់ពីសេចក្ដីណែនាំអំពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាស។

## ភាគកម្មមិនមានអភិបាលភាព

២២ ក្រុមហ៊ុនមេត្រូវបង្ហាញភាគកម្មមិនមានអភិបាលភាព នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមនៅក្នុងផ្នែកទ្រព្យម្ចាស់, ដោយដាក់ដាច់ដោយឡែកពីទ្រព្យម្ចាស់របស់ម្ចាស់នៃក្រុមហ៊ុនមេ។

២៣ បម្រែបម្រួលនៃភាគកម្មកម្មសិទ្ធិរបស់ក្រុមហ៊ុនមេ នៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ដែលមិនធ្វើឲ្យក្រុមហ៊ុនមេបាត់បង អភិបាលភាពលើក្រុមហ៊ុនបុត្រ

សម្ព័ន្ធ គឺជាប្រតិបត្តិការជាទ្រព្យម្ចាស់ (មានន័យថាប្រតិបត្តិការជាមួយម្ចាស់ក្នុងនាមជាម្ចាស់)។

២៤ កថាខណ្ឌ ខ៩៤ - កថាខណ្ឌ ខ៩៦ កំណត់អំពីសេចក្តីណែនាំ សម្រាប់ការងារគណនេយ្យសម្រាប់ភាគកម្មមិនមាន កាពិបាលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស។

## ការបាត់បង់អភិបាលភាព

២៥ ប្រសិនបើក្រុមហ៊ុនមេបាត់បង់អភិបាលភាពលើក្រុមហ៊ុនបុត្រសម្ពន្ធ័ ក្រុមហ៊ុនមេៈ

(ក) មិនទទួលស្គាល់ទ្រព្យសកម្ម និងបំណុលរបស់អតីតក្រុមហ៊ុនបុត្រសម្ពន្ធ័នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមឡើយ។

(ខ) ទទួលស្គាល់ការវិនិយោគ ដែលនៅរក្សាទុកនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ពន្ធ័តាមតម្លៃសមស្រប នៅពេលដែលអភិបាលភាព ត្រូវបានបាត់បង់និងជាបន្តបន្ទាប់ត្រូវគណនាបរិមាណនៃការវិនិយោគ និងបរិមាណដែលជំពាក់ ដោយឬជំពាក់ចំពោះអតីតក្រុមហ៊ុនបុត្រសម្ពន្ធ័ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលពាក់ពន្ធ័។ តម្លៃសមស្របនោះត្រូវចាត់ទុកថាជាតម្លៃសមស្របនៅពេលនៃការទទួលស្គាល់ដំបូង ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ឬនៅពេលដែលសមស្រប

តម្លៃដើមនៅពេលនៃការទទួលស្គាល់ដំបូងនៃការវិនិយោគ នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធឬក្រុមអាជីវកម្មរួមទុន។

(គ) ទទួលស្គាល់ចំណេញឬខាតទាក់ទងនឹងការបាត់បង់អភិបាលភាពដែលអាចកំណត់បានចំពោះអតីតភាគកម្មដែលមានអភិបាលភាព។

**២៦** កថាខណ្ឌ ខ៩៧ - កថាខណ្ឌ ខ៩៩ កំណត់អំពីសេចក្តីណែនាំ សម្រាប់ការងារគណនេយ្យសម្រាប់ការបាត់បង់អភិបាលភាព។

## ឧបសម្ព័ន្ធ ក

## បច្ចេកសព្ទកំណត់អត្ថន័យ

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្រង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ*

| | |
|---|---|
| **របាយការណ៍ហិរញ្ញវត្ថុសមាស** | របាយការណ៍ហិរញ្ញវត្ថុរបស់គ្រុប ដែលនៅក្នុននោះទ្រព្យសកម្ម បំណុល ទ្រព្យម្ចាស់ ចំណូល ចំណាយ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបាន បង្ហាញថាជារបស់អង្គភាពសេដ្ឋកិច្ចតែមួយ។ |
| **អភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ** | ក្រុមហ៊ុនវិនិយោគ ធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគនៅពេលដែលក្រុមហ៊ុន វិនិយោគត្រូវបង្ហាញ ឬមានសិទ្ធិ ចំពោះប្រាក់ចំណេញ ពីការពាក់ពន្ធ័របស់ខ្លួនជាមួយក្រុមហ៊ុន ទទួលការវិនិយោគ និងមានលទ្ធភាពធ្វើឱ្យមានផលប៉ះពាល់ដល់ប្រាក់ចំណេញទាំងនោះ តាមរយៈអំណាចរបស់ខ្លួនលើក្រុមហ៊ុនរងការវិនិយោគ។ |

**អ្នកធ្វើការសម្រេចចិត្ត** អង្គភាពដែលមានសិទ្ធិនៃការធ្វើការសម្រេចចិត្តដែលជាក្រុមហ៊ុនមេ ឬភ្នាក់ងារ សម្រាប់ភាគីផ្សេងទៀត។

**គ្រុប** ក្រុមហ៊ុនមេនិងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់វា។

**ភាគកម្មមិនមានអភិបាលភាព** ទ្រព្យម្ចាស់នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនមានអាចទុកដាក់ដោយផ្ទាល់ឬដោយប្រយោលថាជារបស់ក្រុមហ៊ុនមេ។

**ក្រុមហ៊ុនមេ** អង្គភាពដែលធ្វើអភិបាលភាពលើអង្គភាពមួយឬច្រើន។

**អំណាច** សិទ្ធិវិជ្ជមាន ដែលផ្តល់នូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

**សិទ្ធិដែលមានការការពារ** សិទ្ធិដែលបានកំណត់ទុកដើម្បីការពារភាគកម្មរបស់ភាគីដែលកាន់កាប់សិទ្ធិទាំងនោះ ដោយមិនផ្តល់ឲ្យភាគីនោះនូវអំណាចទៅលើអង្គភាព ដែលសិទ្ធិនោះមានការពាក់ពន្ធ័។

**សកម្មភាពពាក់ពន្ធ័** សម្រាប់គោលបំណងនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សកម្មភាពពាក់ពន្ធ័ គឺជាសកម្មភាពនានារបស់ក្រុមហ៊ុនរងការវិនិយោគដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។

**សិទ្ធិនៃការដកចេញ** សិទ្ធិបដិសេធអំណាចនៃការធ្វើការសម្រេចចិត្តរបស់អ្នកធ្វើការសម្រេចចិត្ត។

**ក្រុមហ៊ុនបុត្រសម្ព័ន្ធ** អង្គភាពដែលត្រូវបានអភិបាលដោយក្រុមហ៊ុនមួយផ្សេងទៀត។

បច្ចេកសព្ទខាងក្រោមត្រូវបានឲ្យអត្ថន័យនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២ *ការលាតត្រដាងព័ត៌មានអំពីភាគកម្មនៅក្នុងក្រុមហ៊ុនផ្សេងទៀត,* ស្តង់ដារគណនេយ្យអន្តរជាតិ២៨ (បានកែប្រែនៅឆ្នាំ២០១១) ឬស្តង់ដារគណនេយ្យអន្តរជាតិ ២៤ *ការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ពន្ធ័* ដែលបានប្រើនៅក្នុងស្រង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះជាមួយនឹងអត្ថន័យជាក់លាក់នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទាំងអស់នោះ÷:

- ក្រុមហ៊ុនបុត្រសម្ព័ន្ធ
- ភាគកម្មនៅក្នុងក្រុមហ៊ុនផ្សេងទៀត
- អាជីវកម្មរួមទុន
- បុគ្គលិកគ្រប់គ្រងសំខាន់ៗ
- ភាគីពាក់ពន្ធ័
- ឥទ្ធិពលជុំកំភួន

## ឧបសម្ព័ន្ធ ខ

## សេចក្តីណែនាំសម្រាប់ការអនុវត្តន៍

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។វាបរិយាយអំពីការអនុវត្តន៍កថាខណ្ឌ ១ -២៦ និង មានអំណាចដូចគ្នានឹងផ្នែកផ្សេងទៀតនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។*

ខ១ ឧទាហរណ៍នៅក្នុងឧបសម្ពន្ធ័នេះគឺជាស្ថានភាពសម្មតិកម្មគំរូ ។ ទោះជាយ៉ាងណា ទិដ្ឋភាពខ្លះនៃឧទាហរណ៍ទាំងនោះ អាចតំណាងឲ្យគំរូ ហេតុ-ការណ៍ជាក់ស្តែងក៏ដោយ ក៏រាល់ហេតុការណ៍ និងកាលៈទេសៈ នៃគំរូ

ហេតុការណ៍ ជាក់ស្តែងដ៏ជាក់លាក់នោះនឹងចាំបាច់ត្រូវតែបានវាយតម្លៃ ពេលអនុវត្តស្រង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០។

## ការវាយតម្លៃលើអនិច្ចាលភាព

ខ២ ដើម្បីកំណត់ថា តើខ្លួនធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ ឬយ៉ាងណា ក្រុមហ៊ុនវិនិយោគត្រូវវាយតម្លៃ ថាតើខ្លួនមានលក្ខខណ្ឌ ដូចខាងក្រោមឬយ៉ាងណា:

(ក) មានអំណាចលើក្រុមហ៊ុនរងការវិនិយោគ

(ខ) មានការបង្ហាញ ឬសិទ្ធិចំពោះប្រាក់ចំណេញអថេរពីការពាក់ពន្ធ័របស់ខ្លួនជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ និង

(គ) មានលទ្ធភាពប្រើអំណាចរបស់ខ្លួនលើក្រុមហ៊ុមទទួលការវិនិយោគ ដើម្បីធ្វើឲ្យមានផលប៉ះពាល់ លើផលចំណេញរបស់ ក្រុមហ៊ុនវិនិយោគ

ខ៣ ការពិចារណាអំពីកត្តាខាងក្រោមអាចជួយក្នុងការកំណត់នោះ÷

(ក) គោលបំណងនិងការបង្កើតរបស់ក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌ ខ៥-ខ៨)

(ខ) អ្វីខ្លះជាសកម្មភាពពាក់ពន្ធ័ និងរបៀបនៃការសម្រេចចិត្តពាក់ពន្ធ័នឹងសកម្មភាពទាំងនោះ (មើល កថាខណ្ឌ ខ១១-ខ១៣)

(គ) តើសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគនោះ ផ្តល់ឲ្យនូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ទាំងនោះ (មើលកថាខណ្ឌខ១៤ - ខ៥៤)

(ឃ) តើក្រុមហ៊ុនវិនិយោគត្រូវបង្ហាញ ឬមានសិទ្ធិ ចំពោះប្រាក់ចំណេញអថេរពីការពាក់ពន្ធ័របស់ខ្លួនជាមួយនឹងក្រុមហ៊ុនទទួលការវិនិយោគ ឬយ៉ាងណា(មើល កថាខណ្ឌ ខ៥៥- ខ៥៧) និង

(ង) តើក្រុមហ៊ុនវិនិយោគមានលទ្ធភាពប្រើអំណាចរបស់ខ្លួន លើក្រុមហ៊ុមទទួលការវិនិយោគ ដើម្បីធ្វើឲ្យមានផលប៉ះពាល់ លើផលចំណេញរបស់ក្រុមហ៊ុនវិនិយោគ ឬយ៉ាងណា (មើលកថាខណ្ឌ ខ៥៨- ខ៧២)។

ខ៤ នៅពេលវាយតម្លៃលើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគក្រុមហ៊ុនវិនិយោគត្រូវពិចារណាចរិតលក្ខណៈ នៃទំនាក់ទំនងរបស់ខ្លួនជាមួយនឹងភាគីផ្សេងៗ (មើល កថាខណ្ឌ ខ៧៣ - ខ៧៥)។

## គោលបំណងនិងការបង្កើតក្រុមហ៊ុនរងការវិនិយោគ

ខ៥ នៅពេលវាយតម្លៃលើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគក្រុមហ៊ុនវិនិយោគត្រូវពិចារណាគោលបំណងនិងទម្រង់នៃការបង្កើរបស់ក្រុមហ៊ុនរងការវិនិយោគ ដើម្បីកំណត់អំពីសកម្មភាពពាក់ពន្ធ័របៀប នៃការធ្វើការសម្រេចចិត្តពាក់ពន្ធ័នឹង សកម្មភាពទាំងនោះ អ្នកណាមានលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពទាំងនោះ និងអ្នកណាទទួលប្រាក់ចំណេញពីសកម្មភាពទាំងនោះ។

ខ៦ នៅពេលដែល គោលបំណង និងទម្រង់នៃការបង្កើតរបស់ក្រុមហ៊ុនរងការវិនិយោគត្រូវបានពិចារណ, វាអាចច្បាស់លាស់ថា ក្រុមហ៊ុនទទួលការវិនិយោត្រូវបានធ្វើអភិបាលភាពតាមមធ្យោបាយនៃឧបករណ៍ហិរញ្ញវត្ថុ

កម្មសិទ្ធិ ដែលផ្តល់ឲ្យអ្នកកាន់កាប់នូវសំលេងឆ្នោតមួយចំណែក ដូចជា ប័ណ្ណភាគហ៊ុនធម្មតានៅក្នុងក្រុមហ៊ុនទទួលការវិនិយោគ។នៅក្នុងករណី នេះ, នៅពេលមិនមានការរៀបចំបន្ថែមណាមួយ ដែលនឹងធ្វើឲ្យមាន ការផ្លាស់ប្តូរការធ្វើការសម្រេចចិត្ត, ការវាយតម្លៃលើអភិបាលភាពត្រូវផ្តោត លើភាគីណាមួយដែលអាចអនុវត្តសិទ្ធិបោះឆ្នោត ដោយគ្រប់គ្រាន់ ដើម្បី កំណត់គោលនយោបាយហិរញ្ញប្រទាននិងគោលនយោបាយប្រតិបត្តិការ របស់ក្រុមហ៊ុនទទួលការវិនិយោគ (មើលកថាខណ្ឌ ខ៣៤ -ខ៥០)។ នៅក្នុងករណីដ៏សាមញ្ញ ដោយក្នុងករណីមិនមានកត្តាផ្សេងទៀត ក្រុមហ៊ុន វិនិយោគដែលកាន់កាប់នីតិភាព នៃសំលេងឆ្នោត នឹងធ្វើអភិបាលភាព លើក្រុមហ៊ុនទទួលការវិនិយោគ។

ខ៧ នៅក្នុងករណីដែលស្មុគស្មាញជាងនេះ ដើម្បីកំណត់ថាតើ ក្រុមហ៊ុន វិនិយោគធ្វើអភិបាលភាពលើក្រុមហ៊ុនទទួលការវិនិយោគ វាអាចជាការ ចាំបាច់ដែលត្រូវពិចារណានូវកត្តាមួយចំនួនឬកត្តាទាំងអស់ ដែលមាននៅ ក្នុងកថាខណ្ឌ ខ៣។

ខ៨ ក្រុមហ៊ុនទទួលការវិនិយោគអាចត្រូវបានបង្កើតឡើង ដើម្បីធ្វើឲ្យសិទ្ធិបោះ ឆ្នោតមិនមែនជាកត្តាដែលមានឧត្តមានុភាពក្នុងការសម្រេចថាតើ អ្នកណា ធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ, ដូចជា សិទ្ធិបោះឆ្នោតមាន តែចំពោះកិច្ចការរដ្ឋបាលតែប៉ុណ្ណោះនិងថាសកម្មភាពពាក់ពន្ធ័ត្រូវបានដឹក នាំដោយកិច្ចព្រមព្រៀងតាមដែលបញ្ញតិដោយកិច្ចសន្យា។ក្នុងករណីបែប នេះការពិចារណារបស់ក្រុមហ៊ុនវិនិយោគអំពីគោលបំណងនិងការបង្កើត របស់ក្រុមហ៊ុនទទួល ការវិនិយោគត្រូវរាប់បញ្ចូលផងដែរនូវការពិចារណា

អំពីហានិភ័យដែលក្រុមហ៊ុនរងការវិនិយោគត្រូវបានបង្កើតឡើង, ហានិភ័យដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ឲ្យទៅភាគីនានា ដែលពាក់ពន្ធ័ជាមួយនឹងក្រុមហ៊ុនទទួលការវិនិយោគ និងថាតើក្រុមហ៊ុនវិនិយោគត្រូវបង្ហាញនូវហានិភ័យមួយចំនួន ឬហានិភ័យទាំងអស់នោះ។ ការពិចារណា អំពីហានិភ័យមិនមែនរាប់បញ្ចូលតែការបន្ថយហានិភ័យទេ តែក៏ត្រូវរាប់បញ្ចូលផងដែរនូវការកើនឡើងនូវហានិភ័យ។

**អំណាច**

៦៩ ដើម្បីមានអំណាច លើក្រុមហ៊ុនរងការវិនិយោគ ក្រុមហ៊ុនវិនិយោគត្រូវមានសិទ្ធិវិជ្ជមាន ដែលនឹងផ្តល់ឲ្យខ្លួននូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។សម្រាប់គោលបំណងនៃការវាយតម្លៃអំណាចមានតែសិទ្ធិចំបងៗនិងសិទ្ធិដែលមិនទទួលបាននូវការការពារប៉ុណ្ណោះ ត្រូវបានគេយកមកពិចារណា (មើលកថាខណ្ឌ ខ២២- ខ២៨)។

៦១០ ការកំណត់ អំពីអំណាចរបស់ក្រុមហ៊ុនវិនិយោគអាស្រ័យលើសកម្មភាពពាក់ពន្ធ័ អាស្រ័យលើរបៀបនៃការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័ និងសិទ្ធិដែលក្រុមហ៊ុនវិនិយោគនិងភាគីដទៃទៀតមាន ទាក់ទងនឹងក្រុមហ៊ុនទទួលការវិនិយោគ។

## សកម្មភាពពាក់ពន្ធ័ និង ការដឹកនាំសកម្មភាពពាក់ពន្ធ័

៦១១ សម្រាប់ក្រុមហ៊ុនរងការវិនិយោគជាច្រើន កម្រិតសកម្មភាពហិរញ្ញប្បទាន និងសកម្មភាពប្រតិបត្តិការមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញ

របស់ពួកគេ។ អាស្រ័យលើកាលៈទេសៈ ឧទាហរណ៍អំពីសកម្មភាពដែល អាចមានភាពពាក់ពន្ធ័ រួមមាន ប៉ុន្តែមិនកម្រិតត្រឹមៈ

(ក) ការលក់និងការទិញទំនិញឬសេវាកម្ម

(ខ) ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងអំឡុងពេលនៃអាយុកាល របស់វា(រួមមានទាំង ការបោកប្រាស់មិនសង)

(គ) ការជ្រើសរើស ការទិញ ឬ ការលក់ចោលទ្រព្យសកម្ម

(ឃ) ការស្រាវជ្រាវនិងការអភិវឌ្ឍន៍ផលិតផលថ្មីឬដំណើការផលិតកម្មថ្មី និង

(ង) ការកំណត់រចនាសម្ពន្ធ័នៃទុន ឬ ការទទួលបានទុន។

១១២ ឧទាហរណ៍អំពីការសម្រេចចិត្តស្ដីពីសកម្មភាពពាក់ពន្ធ័រួមមាន ប៉ុន្តែមិនកម្រិតត្រឹមៈ

(ក) ការបង្កើតការសម្រេចចិត្ត អំពីប្រតិបត្តិការ និងអំពីដើមទុនរបស់ ក្រុមហ៊ុនរងការវិនិយោគ រួមមានទាំងគម្រោងថវិកាផងដែរ និង

(ខ) ការតែងតាំងនិងការផ្ដល់កម្រៃអ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកផ្ដល់ សេវារបស់ក្រុមហ៊ុនរងការវិនិយោគ និងការបញ្ចប់សេវា និងការងារ របស់បុគ្គលទាំងនោះ។

១១៣ នៅក្នុងស្ថានភាពខ្លះ សកម្មភាពមុន និងក្រោយកាលៈទេសៈមួយចំនួន ដែលកើតឡើង ឬព្រឹត្តិការណ៍កើតឡើង អាចជាសកម្មភាពពាក់ពន្ធ័។ នៅពេលដែលក្រុមហ៊ុនវិនិយោគពីរ ឬច្រើនមានលទ្ធភាពបច្ចុប្បន្ន ដើម្បី ដឹកនាំសកម្មភាពពាក់ពន្ធ័ ហើយសកម្មភាពទាំងនោះកើតឡើងក្នុងពេល វេលាខុសៗគ្នា, បណ្ដាក្រុមហ៊ុនវិនិយោគទាំងនោះត្រូវកំណត់ថាតើក្រុម

ហ៊ុនវិនិយោគណាមួយដែលអាចដឹកនាំសកម្មភាពដែលមានផលប៉ះពាល់ខ្លាំងលើប្រាក់ចំណេញដែលមានសង្គតិភាពជាមួយនឹងប្រព្រឹត្តិកម្មនៃសិទ្ធិនៃការធ្វើការសម្រេចចិត្តដែលស្របគ្នា (មើលកថាខណ្ឌ១៣)។ ក្រុមហ៊ុនវិនិយោគត្រូវពិចារណាឡើងវិញនូវការវាយតម្លៃនេះជាបន្តបន្ទាប់ប្រសិនបើហេតុការណ៍ជាក់ស្តែងឬកាលៈទេសៈមានការផ្លាស់ប្តូរ។

**ឧទាហរណ៍ ១**

ក្រុមហ៊ុនវិនិយោគពីរបង្កើតក្រុមហ៊ុនរងការវិនិយោគមួយដើម្បីអភិវឌ្ឍ និងលក់ផលិតផលវេជ្ជសាស្ត្រ។ក្រុមហ៊ុនវិនិយោគមួយទទួលខុសត្រូវលើការអភិវឌ្ឍ និងទទួលការអនុម័តដោយនិយ័តករអំពីផលិតផលវេជ្ជសាស្ត្រ --ការទទួលខុសត្រូវរួមមាន លទ្ធភាពជាឯកតោភាគី ដើម្បីធ្វើរាល់ការសម្រេចចិត្ត ទាក់ទងនឹងការអភិវឌ្ឍន៍ផលិតផលនិងទទួលបានការអនុម័ត ដោយនិយ័តករ។ នៅពេលដែលនិយ័តករអនុម័តលើផលិតផល, ក្រុមហ៊ុនវិនិយោគផ្សេងទៀតនឹងដំណើរការផលិតនិងលក់ផលិតផលទាំងនោះ--ក្រុមហ៊ុនវិនិយោគនេះ មានលទ្ធភាពជាឯកតោភាគីដើម្បីធ្វើការផលិត និងធ្វើសកម្មភាពម៉ាឃីតធីង របស់គម្រោង។ ប្រសិនបើរាល់សកម្មភាពទាំងអស់--ការអភិវឌ្ឍន៍ និងការទទួលបានការអនុម័តដោយនិយ័តករក៏ដូចជាការផលិតនិងការធ្វើម៉ាឃីតទីងផលិតផលវេជ្ជសាស្ត្រ--គឺជាសកម្មភាពពាក់ពន្ធ័, ក្រុមហ៊ុនវិនិយោគនីមួយៗ ចាំបាច់ត្រូវកំណត់ថាតើខ្លួនអាចដឹកនាំសកម្មភាព ដែលមានផលប៉ះពាល់ជាដុំកំភួន លើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណា។ យោងតាមនោះ, ក្រុមហ៊ុនវិនិយោគនិមួយៗចាំបាច់ត្រូវពិចារណាថាតើការអភិវឌ្ឍន៍និងការទទួលការអនុម័តដោយនិយ័តករឬការផលិតនិងការធ្វើ ម៉ាឃីតទីង ផលិតផលវេជ្ជសាស្ត្រគឺជាសកម្មភាព

| |
|---|
| ដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ និងថាតើខ្លួនអាចដឹកនាំសកម្មភាពនោះបានឬយ៉ាងណា។នៅក្នុងការកំណត់ថា ក្រុមហ៊ុនវិនិយោគណាមួយ មានអំណាច, ក្រុមហ៊ុនវិនិយោគត្រូវពិចារណាៈ<br>(ក) គោលបំណងនិងការបង្កើតក្រុមហ៊ុនរងការវិនិយោគ<br>(ខ)កត្តាដែលកំណត់កម្រិតប្រាក់ចំណេញ,ចំណូលនិងតម្លៃរបស់ក្រុមហ៊ុនរងការ វិនិយោគក៏ដូចជាតម្លៃរបស់ផលិតផលវេជ្ជសាស្ត្រ<br>(គ)ផលប៉ះពាល់លើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគដែលកើតចេញ ពីអំណាចនៃការសម្រេចរបស់ក្រុមហ៊ុនវិនិយោគនីមួយៗដោយយោងតាម (ខ) និង<br>(ឃ) ការប្រឈមរបស់ក្រុមហ៊ុនវិនិយោគចំពោះបម្រែបម្រួលប្រាក់ចំណេញ។ នៅក្នុងឧទាហរណ៍នេះ, ក្រុមហ៊ុនវិនិយោគក៏ត្រូវពិចារណាផងដែរនូវៈ<br>(ង)ភាពមិនប្រាកដប្រជា និងកិច្ចខិតខំប្រឹងប្រែងចាំបាច់ នៅក្នុងការទទួលការ អនុម័តដោយនិយ័តករ (ពិចារណាកំណត់ត្រាឯកសាររបស់ក្រុមហ៊ុនវិនិយោគ អំពីការអភិវឌ្ឍនិងការអនុម័តដោយនិយ័តករលើផលិតផលវេជ្ជសាស្ត្រ) និង<br>(ច)ក្រុមហ៊ុនវិនិយោគណាមួយដែលធ្វើអភិបាលភាពលើផលិតផលវេជ្ជសាស្ត្រ នៅពេលដែលដំណាក់កាលអភិវឌ្ឍន៍ ផលិតផលទទួលបានជោគជ័យ។ |
| |

**ឧទាហរណ៍ ២**

គម្រោងវិនិយោគមួយ (ក្រុមហ៊ុនទទួលរងការវិនិយោគ) ត្រូវបានបង្កើតឡើង និងផ្តល់ហិរញ្ញប្បទានដោយឧបករណ៍ហិរញ្ញវត្ថុបំណុលដែលបានកាន់កាប់ដោយក្រុមហ៊ុនវិនិយោគ (វិនិយោគិនបំណុល) និងឧបករណ៍ហិរញ្ញវត្ថុទ្រព្យម្ចាស់ដែលកាន់កាប់ដោយក្រុមហ៊ុនវិនិយោគមួយចំនួន។ ចំណែកនៃបណ្ណាភាគហ៊ុនត្រូវបានបង្កើតឡើង ដើម្បីស្រូបយកការខាតបង់លើកដំបូង និងទទួលយកនូវភាគចំណេញនៅសល់ពីក្រុមហ៊ុនរងការវិនិយោគ។ ក្រុមហ៊ុនវិនិយោគ ជាទ្រព្យម្ចាស់មួយដែលជាអ្នកកាន់កាប់កម្មសិទ្ធិភាពចំនួន ៣០ភាគរយ គឺជាក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មផងដែរ។ ក្រុមហ៊ុនរងការវិនិយោគ ប្រើទឹកប្រាក់ដែលទទួលបានដើម្បីទិញផលបត្រទ្រព្យសកម្មហិរញ្ញវត្ថុ, ធ្វើឲ្យក្រុមហ៊ុនរងការវិនិយោគត្រូវប្រឈមនឹងហានិភ័យឥណទានដែលពាក់ពន្ធ័នឹងការខកខាន មិនអាចសងបាន ដែលអាចកើតមាន ចំពោះទូទាត់ប្រាក់ដើម និងការប្រាក់របស់ទ្រព្យសកម្ម។ប្រតិបត្តិការត្រូវបានលក់ទៅឲ្យវិនិយោគិនបំណុលថាជាការវិនិយោគដែលមានការប្រឈមកម្រិតទាបបំផុតទៅនឹងហានិភ័យឥណទានដែលពាក់ពន្ធ័នឹងលទ្ធភាព មិនអាចសងបានរបស់ទ្រព្យសកម្មនៅក្នុងផលបត្រដោយសារតែចរិតលក្ខណៈរបស់ទ្រព្យសកម្មទាំងនោះនិងដោយសារតែចំណែកនៃទ្រព្យម្ចាស់ត្រូវបានបង្កើតឡើង ដើម្បីស្រូបយកការខាតបង់លើកដំបូង របស់ក្រុមហ៊ុនរងការវិនិយោគ។ប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគទទួលរងផលប៉ះពាល់

យ៉ាងខ្លាំងដោយការគ្រប់គ្រងផលបត្រទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ ដែលរួមមានការសម្រេចចិត្តអំពីការជ្រើសរើស, ការទិញយក, និងការបោះបង់ចោលទ្រព្យសកម្មស្ថិតនៅក្នុងក្របខណ្ឌនៃសេចក្តីណែនាំអំពីការផលបត្រ និងការគ្រប់គ្រងលទ្ធភាព មិនអាចសងបានរបស់ទ្រព្យសកម្ម នៅក្នុងផលបត្រ។ សកម្មភាពទាំងអស់នោះត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម រហូតដល់លទ្ធភាពមិនអាចសងបានឈានដល់កម្រិតជាក់លាក់មួយ នៃតម្លៃផលបត្រ (មានន័យថា នៅពេលដែលតម្លៃផលបត្រ គឺជាតម្លៃដែលចំណែកទ្រព្យម្ចាស់របស់ក្រុមហ៊ុនរងការវិនិយោគត្រូវបានប្រើប្រាស់)។ ពីពេលនោះមក, អភិបាលដែលជាភាគីទីបីគ្រប់គ្រងទ្រព្យសកម្មដោយយោងតាម ការណែនាំរបស់វិនិយោគិនបំណុល។ ការគ្រប់គ្រងផលបត្រទ្រព្យសកម្ម របស់ក្រុមហ៊ុនរងការវិនិយោគ គឺជាសកម្មភាពពាក់ពន្ធ័របស់ក្រុមហ៊ុនរងការវិនិយោគ។ ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម មានលទ្ធភាពដឹកនាំសកម្មភាពពាក់ពន្ធ័រហូតដល់ទ្រព្យសកម្ម ដែលមិនមានលទ្ធភាពសងឈានដល់កម្រិតជាក់លាក់មួយ នៃតម្លៃផលបត្រ, វិនិយោគិនបំណុលមានលទ្ធភាពដឹកនាំសកម្មភាពពាក់ពន្ធ័ នៅពេលដែលតម្លៃនៃទ្រព្យសកម្មដែលមិនមានលទ្ធភាពសងឡើងហួសពីកម្រិតជាក់លាក់នៃតម្លៃផលបត្រ។ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម និងវិនិយោគិនបំណុលចាំបាច់ត្រូវកំណត់ថាតើពួកគេអាចដឹកនាំសកម្មភាព ដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណា, ដោយរួមមានការពិចារណាពីគោលបំណង និងការបង្កើតក្រុមហ៊ុនរងការវិនិយោគ ក៏ដូចជាការប្រឈមមុខរបស់ភាគីនីមួយៗ ចំពោះភាពងាយប្រែប្រួលនៃប្រាក់ចំណេញ។

## សិទ្ធិដែលផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវអំណាចលើក្រុមហ៊ុនរងការវិនិយោគ

១១៤ អំណាចបានមកពីសិទ្ធិ។ ដើម្បីមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ, ក្រុមហ៊ុនវិនិយោគត្រូវតែមានសិទ្ធិវិជ្ជមានដែលផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ព័ន្ធ។ សិទ្ធិអាចផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវអំណាចដែលអាចខុសៗគ្នាពីក្រុមហ៊ុនរងការវិនិយោគនានា។

១១៥ ឧទាហរណ៍អំពីសិទ្ធិ ជាលក្ខណៈបុគ្គលឬលក្ខណៈរួម ដែលអាចផ្តល់អំណាចឲ្យក្រុមហ៊ុនវិនិយោគ រួមមាន ប៉ុន្តែ មិនកម្រិតត្រឹមៈ

(ក) សិទ្ធិមានទម្រង់ជាសំលេងឆ្នោត(ឬសំលេងឆ្នោតសក្តានុពល)របស់ក្រុមហ៊ុនរងការវិនិយោគ(មើល កថាខណ្ឌ ខ៣៤- កថាខណ្ឌខ៥០)

(ខ) សិទ្ធិដើម្បីជ្រើសតាំង, សិទ្ធិចាត់តាំងឡើងវិញ, ឬសិទ្ធិដកចេញនូវសមាជិករបស់បុគ្គលិកគ្រប់គ្រងសំខាន់ៗ ដែលជាអ្នកមានលទ្ធភាពដឹកនាំសកម្មភាពរបស់ក្រុមហ៊ុនរងការិនិយោគ

(គ) សិទ្ធិតែងតាំងឬដកចេញអង្គភាពផ្សេងទៀតដែលដឹកនាំ សកម្មភាពពាក់ពន្ធ័

(ឃ) សិទ្ធិដើម្បីដឹកនាំក្រុមហ៊ុនរងការវិនិយោគដើម្បីចូលរួម ឬសិទ្ធិវេតូចំពោះការផ្លាស់ប្តូរណាមួយចំពោះប្រតិបត្តិការដែលផ្តល់ប្រយោជន៍ដល់ក្រុមហ៊ុនវិនិយោគ និង

(ង) សិទ្ធិផ្សេងៗ (ដូចជា សិទ្ធិនៃការសម្រេចចិត្ត ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាគ្រប់គ្រង) ដែលផ្តល់ឲ្យអ្នកកាន់កាប់នូវលទ្ធភាពដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

១១៦ ជាទូទៅ, នៅពេលដែលក្រុមហ៊ុនរងការវិនិយោគមានដែននៃសកម្មភាពប្រតិបត្តិការ និងសកម្មភាពហិរញ្ញប្បទាន ដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ និងនៅពេលដែលការសម្រេចចិត្តដែលពាក់ពន្ធ័នឹងសកម្មភាពទាំងនេះ ត្រូវបានតម្រូវជាបន្តបន្ទាប់, វានឹងជាសិទ្ធិបោះឆ្នោត ឬសិទ្ធិស្រដៀងដែល ផ្តល់អំណាចឱ្យក្រុមហ៊ុនវិនិយោគជាលក្ខណៈបុគ្គលឬលក្ខណៈរួមជាមួយនឹងការរៀបចំផ្សេងទៀត។

១១៧ នៅពេលសិទ្ធិបោះឆ្នោត មិនអាចមានផលប៉ះពាល់ជាដុំកំភួន លើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ, ដូចជា ពេលសិទ្ធិបោះឆ្នោតទាក់ទងនឹងកិច្ចការរដ្ឋបាលនិងកិច្ចព្រមព្រៀងដែលបញ្ញត្តិដោយកិច្ចសន្យាដើម្បីកំណត់ទិសដៅនៃសកម្មភាពពាក់ពន្ធ័, ក្រុមហ៊ុនវិនិយោគចាំបាច់ត្រូវវាយតម្លៃកិច្ចព្រមព្រៀងដែលបញ្ញត្តិដោយកិច្ចសន្យាទាំងនោះដើម្បីកំណត់ថាតើខ្លួនមានសិទ្ធិគ្រប់គ្រាន់ដើម្បីមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណា។ ដើម្បីកំណត់ថាតើ ក្រុមហ៊ុនវិនិយោគមានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបាននូវអំណាយ ឬយ៉ាងណានោះ ក្រុមហ៊ុនវិនិយោគត្រូវពិចារណា អំពីគោលបំណងនិងការបង្កើតរបស់ក្រុមហ៊ុនរងការវិនិយោគ (មើល កថាខណ្ឌខ៥-ខ៨) និងការតម្រូវនៅក្នុងកថាខណ្ឌខ៥១-កថាខណ្ឌខ៥៤ រួមជាមួយនឹងកថាខណ្ឌ ១១៨-កថាខណ្ឌ ១២០។

១១៨ នៅក្នុងកាលៈទេសៈខ្លះ វាអាចជាការលំបាកដើម្បីកំណត់ថាតើ សិទ្ធិរបស់ក្រុមហ៊ុនវិនិយោគមានគ្រប់គ្រាន់ដើម្បីមានអំណាចលើក្រុមហ៊ុនរងការវិនិយោគយ៉ាងណា។ នៅក្នុងករណីបែបនេះ ដើម្បីអាចធ្វើការវាយតម្លៃអំពី

អំណាច ក្រុមហ៊ុនវិនិយោគ ត្រូវពិចារណាអំពីភស្តុតាងថាតើ ខ្លួនមានលទ្ធភាពជាក់ស្តែងដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ជាឯកតោភាគី ឬយ៉ាងណា។ ការពិចារណាត្រូវបានធ្វើឡើងតែមិនកំណត់ត្រឹម ដូចខាងក្រោមឡើយ នៅពេលត្រូវបានពិចារណារួមជាមួយសិទ្ធិរបស់ខ្លួន និងសូចនាករនានានៅក្នុងកថាខណ្ឌ ខ១៩ និង ខ២០, អាចផ្តល់ជាភស្តុតាង ដែលសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគមានគ្រប់គ្រាន់ដើម្បីមានអំណាចលើក្រុមហ៊ុនរងការវិនិយោគៈ

(ក) ដោយមិនមានសិទ្ធិ តាមកិច្ចសន្យា ដើម្បីឱ្យធ្វើដូច្នេះ ក្រុមហ៊ុនវិនិយោគ អាចតាំងតាំងឬអនុម័តយល់ព្រមលើ អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនរងការវិនិយោគដែលជាអ្នកមានលទ្ធភាពដឹកនាំសកម្មភាពពាក់ពន្ធ័។

(ខ) ដោយមិនមានសិទ្ធិតាមកិច្ចសន្យាដើម្បីឱ្យធ្វើដូច្នេះក្រុមហ៊ុនវិនិយោគអាចដឹកនាំក្រុមហ៊ុនរងការវិនិយោគឱ្យ ចូលរួមនៅក្នុង ឬប្រើសិទ្ធិវេតូលើការផ្លាស់ប្តូរណាមួយទៅលើប្រតិបត្តិការសំខាន់ៗដែលមានប្រយោជន៍ដល់ក្រុមហ៊ុនវិនិយោគ។

(គ) ក្រុមហ៊ុនវិនិយោគអាចគ្របដណ្តប់លើដំណើការតែងតាំង សម្រាប់ការជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនរងការវិនិយោគ ឬទទួលបានសិទ្ធិប្រទានពី អ្នកកាន់កាប់បណ្ណ័ភាគហ៊ុនមានសំលេងឆ្នោតផ្សេងទៀត។

(ឃ) អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនរងការវិនិយោគ គឺជាភាគីពាក់ពន្ធ័របស់ក្រុមហ៊ុនវិនិយោគ (ឧទាហរណ៍, នាយកប្រតិបត្តិរបស់

ក្រុមហ៊ុនរងការវិនិយោគនិងនាយកប្រតិបត្តិរបស់ក្រុមហ៊ុនវិនិយោគ គឺជាបុគ្គលតែមួយ)។

(ង) សមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនរងការវិនិយោគគឺជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុនវិនិយោគ។

១១៩ ជួនកាល មានការចង្អុលបង្ហាញថា ក្រុមហ៊ុនវិនិយោគមានទំនាក់ទំនងពិសេស ជាមួយក្រុមហ៊ុនរងការវិនិយោគ ដែលបង្ហាញថា ក្រុមហ៊ុនវិនិយោគមានភាគកម្មអកម្មជាច្រើន ជាមួយក្រុមហ៊ុនរងការវិនិយោគ។ អត្ថិភាពនៃការចង្អុលបង្ហាញនីមួយៗ ឬការផ្គួបផ្សំ នូវការចង្អុលបង្ហាញណាមួយ មិនចាំបាច់ត្រូវមានន័យថា លក្ខណៈវិនិច្ឆ័យអំពីអំណាចត្រូវបានឆ្លើយតបនោះឡើយ។ទោះជាយ៉ាងណាមានភាគកម្មអកម្មជាច្រើនជាមួយក្រុមហ៊ុនរងការវិនិយោគអាចបង្ហាញថា ក្រុមហ៊ុនវិនិយោគមានសិទ្ធិពាក់ពន្ធ័ផ្សេងៗទៀតដែលគ្រប់គ្រាន់ដើម្បីមានអំណាច ឬផ្ដល់ភស្តុតាងអំពីអំណាច ដែលមានទៅលើក្រុមហ៊ុនរងការវិនិយោគ។ ឧទាហរណ៍ចំណុចខាងក្រោមណែនាំថា ក្រុមហ៊ុនវិនិយោគមានភាគកម្មអកម្មជាច្រើនជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ និងដោយការគួបផ្សំជាមួយនឹង សិទ្ធិផ្សេងទៀត អាចបង្ហាញអំពីអំណាចៈ

(ក) អ្នកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនរងការវិនិយោគ ដែលជាអ្នកមានលទ្ធភាពដឹកនាំសកម្មភាពពាក់ពន្ធ័ គឺជាបុគ្គលិកបច្ចុប្បន្ន ឬអតីតបុគ្គលិករបស់ក្រុមហ៊ុនវិនិយោគ។

(ខ) ប្រតិបត្តិការរបស់ក្រុមហ៊ុនរងការវិនិយោគអាស្រ័យលើក្រុមហ៊ុនវិនិយោគដូចមាន ចំណែកសំខាន់ នៃសកម្មភាពរបស់ក្រុមហ៊ុន

រងការវិនិយោគទាក់ទងនឹង ឬត្រូវបានធ្វើឡើងក្នុងនាមក្រុមហ៊ុនវិនិយោគ

(ឃ) ការប្រឈម ឬសិទ្ធិចំពោះប្រាក់ចំណេញពីការពាក់ព័ន្ធរបស់ខ្លួនជាមួយនឹងក្រុមហ៊ុនរងការវិនិយោគមានចំណែកមួយភាគធំ ដោយវិសមាមាត្រជាងសិទ្ធិបោះឆ្នោត ឬសិទ្ធិដែលស្រដៀងរបស់ខ្លួន។ ឧទាហរណ៍ អាចមានស្ថានភាពដែលក្រុមហ៊ុនវិនិយោគសិទ្ធិ ឬត្រូវបង្ហាញចំពោះចំណែកច្រើនជាងពាក់កណ្តាលនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ ប៉ុន្តែកាន់កាប់តិចជាងពាក់កណ្តាលនៃបណ្ណ័ភាគហ៊ុនមានសិទ្ធិបោះឆ្នោត នៅក្នុងក្រុមហ៊ុន នៅក្នុងស្ថានភាពដូចខាងក្រោមៈ

(១) ក្រុមហ៊ុនរងការវិនិយោគពឹងអាស្រ័យលើក្រុមហ៊ុនវិនិយោគផ្តល់ហិរញ្ញវត្ថុក្នុងចំណែកដ៏ច្រើនសម្រាប់ប្រតិបត្តិការរបស់ខ្លួន។

(២) ក្រុមហ៊ុនវិនិយោគធានា លើចំណែកសំខាន់ៗ នៃបំណុលរបស់ក្រុមហ៊ុនរងការវិនិយោគ

(៣) ក្រុមហ៊ុនរងការវិនិយោគពឹងអាស្រ័យលើក្រុមហ៊ុនវិនិយោគសម្រាប់សេវាកម្ម, បច្ចេកវិទ្យា, ការផ្គត់ផ្គង់សំភារៈ និងវត្ថុធាតុដើមសំខាន់ៗ របស់ក្រុមហ៊ុនវិនិយោគ

(៤) ក្រុមហ៊ុនវិនិយោគធ្វើអភិបាលលើទ្រព្យសកម្ម ដូចជាអជ្ញាបណ្ណ័ ឬសញ្ញាពាណិជ្ជកម្ម ដែលមានភាពចាំបាច់បំផុតចំពោះប្រតិបត្តិការរបស់ក្រុមហ៊ុនរងការវិនិយោគ។

(៥) ក្រុមហ៊ុនរងការវិនិយោគពឹងអាស្រ័យលើក្រុមហ៊ុន វិនិយោគសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់ ដូចជានៅពេលដែលបុគ្គលិករបស់ក្រុមហ៊ុនវិនិយោគមានចំណេះដឹងជំនាញពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនរងការវិនិយោគ

ខ២០ ការប្រឈម ឬសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគកាន់តែច្រើន លើភាពងាយប្រែប្រួលនៃប្រាក់ចំណេញ ដែលបានពីការពាក់ពន្ធ័របស់ខ្លួនជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ នឹងមានការលើកទឹកចិត្តកាន់តែច្រើន ចំពោះក្រុមហ៊ុនវិនិយោគដើម្បីទទួលបានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបានអំណាចរបស់ខ្លួន។ ដូច្នេះហើយ ប្រឈមកាន់តែខ្លាំង ជាមួយនឹងភាពងាយប្រែប្រួលនៃប្រាក់ចំណេញគឺជាសូចនករមួយដែលក្រុមហ៊ុនវិនិយោគអាចទទួលបាននូវអំណាចរបស់ខ្លួន។ ទោះជាយ៉ាងណា, កម្រិតនៃការប្រឈមរបស់ក្រុមហ៊ុនវិនិយោគ ដោយខ្លួនឯងមិនកំណត់អំពីថាតើ ក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណានោះឡើយ។

ខ២១ នៅពេលដែលកត្តានានាដែលបានកំណត់នៅក្នុង កថាខណ្ឌ ខ១៨ និងបណ្តាសូចនករដែលបានកំណត់នៅក្នុងកថាខណ្ឌ ខ១៩ និង កថាខណ្ឌ ខ២០ ត្រូវបានពិចារណារួមគ្នា ជាមួយនឹងសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគនោះទម្ងន់កាន់តែធ្ងន់នឹងត្រូវបានផ្តល់ឲ្យអំពីភស្តុតាងនៃអំណាច ដែលបានបរិយាយនៅក្នុងកថាខណ្ឌ ខ១៨។

## សិទ្ធិលើសលែង

១២២ នៅក្នុងការវាយតម្លៃអំពីអំណាចរបស់ខ្លួន ក្រុមហ៊ុនវិនិយោគពិចារណាតែសិទ្ធិលើសលែងដែលទាក់ទងនឹងក្រុមហ៊ុនរងការវិនិយោគ (ដែលកាន់កាប់ដោយក្រុមហ៊ុនវិនិយោគនិងក្រុមហ៊ុនដទៃទៀត)។ ដើម្បីឲ្យមានសិទ្ធិជាលើសលែងអ្នកកាន់កាប់ត្រូវមានលទ្ធភាពជាក់ស្តែង ដើម្បីអនុវត្តន៍សិទ្ធិនោះ។

១២៣ ដើម្បីកំណត់ថាតើសិទ្ធិនោះមានលក្ខណៈចិន្រ្តៃយ៍ឬយ៉ាងណា វាទាមទារនូវការវិនិច្ឆ័យ ដោយរាប់បញ្ចូលនូវរាល់គ្រប់ហេតុការណ៍និងកាលៈទេសៈ។ បណ្តាកត្តាដែលត្រូវពិចារណានៅក្នុងការធ្វើការកំណត់រួមមាន ដូចខាងក្រោម តែមិនកំណត់ត្រឹមៈ

(ក) តើមានឧបសគ្គ (ខាងសេដ្ឋកិច្ចឬឧបសគ្គសផ្សេងៗ) ដែលរារាំងអ្នកកាន់កាប់ណាមួយ (ឬបណ្តាអ្នកកាន់កាប់) មិនឲ្យអនុវត្តន៍សិទ្ធិបាន។ ឧទាហរណ៍នៃឧបសគ្គទាំងនោះរួមមាន តែមិនកំណត់ត្រឹមៈ

(១) ការពិន័យនិងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលនឹងរារាំង (ឬធ្វើឲ្យវា)អ្នកកាន់កាប់មិនឲ្យអនុវត្តន៍សិទ្ធិរបស់ខ្លួន។

(២) ថ្លៃអនុវត្តន៍ឬថ្លៃបំផ្លែងដែលនឹងបង្កើតឲ្យមានឧបសគ្គផ្នែកហិរញ្ញវត្ថុដែលនឹងរារាំង (ឬធ្វើឲ្យរារាំង) អ្នកកាន់កាប់មិនឲ្យអនុវត្តន៍សិទ្ធិរបស់ខ្លួន។

(៣) លក្ខខណ្ឌនិងការដាក់កំហិតដែលនឹងធ្វើឲ្យសិទ្ធិនឹង ត្រូវបានអនុវត្តន៍ ជាឧទាហរណ៍ ការដាក់កំហិតថានឹងកម្រិតពេលវេលានៃការអនុវត្តន៍។

(៤) មិនមានយន្តការសមស្របជាក់ស្តែងនៅក្នុងឯកសារ នៃការបង្កើតក្រុមហ៊ុនរងការវិនិយោគ ឬក្នុងច្បាប់ ឬនិយ័តកម្ម ដែលអាចអនុវត្តន៍បាន ដែលនឹងអនុញ្ញាតិឲ្យអ្នកកាន់កាប់អនុវត្តន៍សិទ្ធិរបស់ខ្លួន។

(៥) ភាពមិនមានលទ្ធភាពរបស់អ្នកកាន់កាប់សិទ្ធិ ដើម្បីទទួលបានព័ត៌មានចាំបាច់សម្រាប់អនុវត្តន៍សិទ្ធិរបស់ខ្លួន។

(៦) ឧបសគ្គ ឬការលើកទឹកចិត្តផ្នែកប្រតិបត្តិការដែលនឹងរារាំង (ឬធ្វើឲ្យរា) អ្នកកាន់កាប់មិនឲ្យអនុវត្តន៍សិទ្ធិរបស់ខ្លួន (ឧ. អវត្តមានរបស់អ្នកគ្រប់គ្រងផ្សេងទៀត ឬការមិនអាចផ្តល់នូវសេវាកម្មឯកទេស ឬផ្តល់នូវសេវាកម្ម និងទទួលយកនូវចំណែកភាគកម្មផ្សេងទៀតដែលកាន់កាប់ដោយអ្នកគ្រប់គ្រងក្នុងតំណែង)

(៧) ការតម្រូវដោយច្បាប់ឬនិយ័តកម្មដែលរារាំងអ្នកកាន់កាប់មិនឲ្យអនុវត្តន៍សិទ្ធិរបស់ខ្លួនបាន (ឧ. ច្បាប់ឬនិយ័តកម្ម ដែលហាមឃាត់ជនបរទេសមិនឲ្យអនុវត្តន៍សិទ្ធិរបស់ខ្លួន)។

(ខ) នៅពេលអនុវត្តន៍សិទ្ធិដែលទាមទារនូវការព្រមព្រៀងពីភាគីជាច្រើន ឬនៅពេលដែលសិទ្ធិត្រូវបានកាន់កាប់ដោយភាគីជាច្រើន ទោះបីជាមានយន្តការដែលផ្តល់ឲ្យភាគីទាំងនោះនូវលទ្ធភាពជាក់ស្តែងដើម្បីអនុវត្តន៍សិទ្ធិ ជារួមប្រសិនបើពួកគេជ្រើសរើសធ្វើដូច្នេះក៏ដោយ។ ការមិនមានយន្តការបែបនោះគឺជាសូចនាករមួយដែលសិទ្ធិអាចមិនមានលក្ខណៈលើសលែង។ នៅពេលដែលមានភាគីច្រើនត្រូវបាន

តម្រូវឲ្យមានការយល់ព្រមលើ ការអនុវត្តន៍សិទ្ធិ វាកាន់តែបង្ហាញថាសិទ្ធិមិនមានលក្ខណៈលើសលែង។ ទោះជាយ៉ាងណា ក្រុមប្រឹក្សាភិបាល ដែលសមាជិករបស់ខ្លួន មានភាពឯករាជ្យពីអ្នកធ្វើការសម្រេចចិត្តអាចដើរតួនាទីជាយន្តការសម្រាប់វិនិយោគិនមួយចំនួនដើម្បីធ្វើសកម្មភាពរួមគ្នាក្នុងការអនុវត្តន៍សិទ្ធិ។ ដូច្នេះ សិទ្ធិនៃការដកចេញដែលអាចអនុវត្តន៍បាន ដោយក្រុមប្រឹក្សាភិបាលឯករាជ្យហាក់ ដូចជាមានលក្ខណៈលើសលែងជាង ប្រសិនបើសិទ្ធិដូចគ្នាអាចត្រូវបានអនុវត្តន៍ ដោយបុគ្គលនីមួយៗ ដែលបានធ្វើឡើងដោយវិនិយោគិនជាច្រើននាក់។

(គ) ថាតើ ភាគីមួយ ឬភាគីច្រើន ដែលកាន់កាប់សិទ្ធិ នឹងទទួលបានប្រយោជន៍ពីការអនុវត្តន៍សិទ្ធិទាំងនោះ។ ឧទាហរណ៍ អ្នកកាន់កាប់សំលេងឆ្នោតសក្តានុពលនៅក្នុងក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌខ៤៧-កថាខណ្ឌខ៥០) ត្រូវពិចារណានូវថ្លៃនៃការអនុវត្តឬថ្លៃនៃការបម្លែងរបស់ឧបករណ៍ហិរញ្ញវត្ថុ។ លក្ខខណ្ឌនិងការដាក់កម្រិតលើសំលេងឆ្នោតសក្តានុពលហាក់មានលក្ខណៈលើសលែងជាង នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុមានតម្លៃទឹកប្រាក់ច្រើន ឬក្រុមហ៊ុនវិនិយោគនឹងទទួលបានប្រយោជន៍ក្នុងហេតុផលផ្សេងៗ (ឧ. ការទទួលស្គាល់ថាមវន្តរវាងក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនរងការវិនិយោគ) ពីការអនុវត្តន៍ឬការបំលែងឧបករណ៍ហិរញ្ញវត្ថុ។

ខ២៤ ដើម្បីមានភាពលើសលែង សិទ្ធិត្រូវតែអាចអនុវត្តន៍បាន នៅពេលការសម្រេចចិត្ត អំពីទិសដៅនៃសកម្មភាពពាក់ពន្ធ័ចាំបាច់ ត្រូវតែធ្វើឡើង។

ជាធម្មតា ដើម្បីមានភាពលើសលែង សិទ្ធិចាំបាច់ត្រូវតែអាចអនុវត្តន៍បាន ជាពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណា ជួនកាលសិទ្ធិអាចត្រូវលើសលែង បើទោះបីជាសិទ្ធិទាំងនោះមិនអាចអនុវត្តន៍បាននាពេលបច្ចុប្បន្នក៏ដោយ។

ឧទាហរណ៍

**ឧទាហរណ៍ ៣**

ក្រុមហ៊ុនរងការវិនិយោគមានកិច្ចប្រជុំប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន ដែលនៅក្នុងនោះការសម្រេចចិត្តអំពីការដឹកនាំសកម្មភាពពាក់ពន្ធ័នឹងត្រូវបានធ្វើឡើង។ កិច្ចប្រជុំរបស់ម្ចាស់ហ៊ុនបន្ទាប់តាមការគ្រោងទុកគឺក្នុងរយៈពេល ៨ខែ ទៀត។ ទោះបីជាយ៉ាងណា ម្ចាស់ហ៊ុនដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥ភាគរយ ជាបុគ្គលក្តី ឬជាសមូហភាពក្តីអាចកោះអញ្ជើញឲ្យមានកិច្ចប្រជុំពិសេស ដើម្បីផ្លាស់ប្តូរបណ្តាគោលនយោបាយបច្ចុប្បន្នទាក់ទងនឹងសកម្មភាពបច្ចុប្បន្ន, ប៉ុន្តែមានការតម្រូវឲ្យមានការផ្តល់ សេចក្តីជូនដំណឹងទៅម្ចាស់ភាគីហ៊ុនផ្សេងទៀត មានន័យថា កិច្ចប្រជុំមិនអាចធ្វើបានឡើយក្នុងរយៈពេល ៣០ថ្ងៃ យ៉ាងតិច។ បណ្តាគោលនយោបាយទាក់ទងនឹងសកម្មភាពអាចត្រូវបានផ្លាស់ប្តូរតែនៅកិច្ចប្រជុំម្ចាស់ភាគហ៊ុនតាមការគ្រោងទុកឬតាមពេលវេលាពិសេស។ នេះរួមមានការអនុម័ត លើការលក់ទ្រព្យសកម្មសំខាន់ៗ ក៏ដូចជាការវិនិយោគឬការលក់ចេញការវិនិយោគ។

គម្រូខាងលើអនុវត្តន៍ ចំពោះឧទាហរណ៍ ៣ក-៣ឃ ដូចបរិយាយខាងក្រោម។ ឧទាហរណ៍នីមួយៗគឺជាករណីដាច់ដោយឡែកពីគ្នា។

## ឧទាហរណ៍ ៣ ក

ក្រុមហ៊ុនវិនិយោគមួយកាន់កាប់នីតិភាព នៃសំលេងឆ្នោតនៅក្នុងក្រុមហ៊ុនរងការវិនិយោគ។ សិទ្ធិបោះឆ្នោតមានភាពលើសលែងដោយសារតែ ក្រុមហ៊ុនវិនិយោគអាចធ្វើការសម្រេចចិត្តអំពីទិសដៅនៃសកម្មភាពពាក់ពន្ធ័ នៅពេលដែលពួកគេចាំបាច់ត្រូវធ្វើ។ ការពិត វាត្រូវចំណាយពេល ៣០ថ្ងៃ មុនពេលដែលក្រុមហ៊ុនវិនិយោគអាចអនុវត្តន៍សិទ្ធិបោះឆ្នោត ដែលមិនអាចបញ្ឈប់ក្រុមហ៊ុនវិនិយោគមិនឲ្យមានលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ខណៈពេលដែលក្រុមហ៊ុនវិនិយោគទទួលបានការកាន់កាប់បណ្ណ័ភាគហ៊ុន។

## ឧទាហរណ៍ ៣ ខ

ក្រុមហ៊ុនវិនិយោគគឺជាភាគីមួយចំពោះកិច្ចសន្យាអនាគតដើម្បីទទួលបាននីតិភាពនៃសន្លឹកហ៊ុននៅក្នុងក្រុមហ៊ុនរងការវិនិយោគ។ កាលបរិច្ឆេទទូទាត់របស់កិច្ចសន្យាអនាគតមានចំនួន ២៥ថ្ងៃ។ ម្ចាស់ភាគហ៊ុនបច្ចុប្បន្ន មិនអាចផ្លាស់ប្តូរបណ្តាគោលនយោបាយបច្ចុប្បន្ន ទៅលើសកម្មភាពពាក់ពន្ធ័បានទេ ពីព្រោះកិច្ចប្រជុំពិសេសមិនអាចធ្វើទៅបានក្នុងរយៈពេល ៣០ថ្ងៃ យ៉ាងតិច ដែលនៅចំណុចពេលនោះកិច្ចសន្យាអនាគត នឹងត្រូវបានទូទាត់សម្រេច។ ដូច្នេះ ក្រុមហ៊ុននិយោគមានសិទ្ធិដែលមានសមមូលយ៉ាងសំខាន់ទៅនឹងម្ចាស់ភាគហ៊ុនដែលមាននីតិភាពនៅក្នុងឧទាហរណ៍ ៣ក ខាងលើ (មានន័យថា ក្រុមហ៊ុនវិនិយោគដែលកាន់កាប់កិច្ចសន្យាអនាគតអាចធ្វើការសម្រេចអំពីទិសដៅរបស់សកម្មភាព

ពាក់ពន្ធ័នៅពេលដែលពួកគេត្រូវការ)។កិច្ចសន្យាអនាគតរបស់ក្រុមហ៊ុនវិនិយោគ គឺជាសិទ្ធិលើសលែងដែលផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ មុនពេលកិច្ចសន្យាអនាគតត្រូវបានទូទាត់។

**ឧទាហរណ៍ ៣គ**

ក្រុមហ៊ុនវិនិយោគកាន់កាប់សិទ្ធិជម្រើសពិសេសដែលមានភាពលើសលែងដើម្បីទទួលបាននីតិភាពនៃប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុនរងការវិនិយោគ ដែលអាចអនុវត្តន៍បាននៅក្នុងរយៈពេល ២៥ថ្ងៃ មិនមានតម្លៃទឹកប្រាក់យ៉ាងក្រាស់ក្រែល។ ការសន្និដ្ឋានដូចគ្នានឹងត្រូវបានធ្វើដូចគ្នានៅក្នុងឧទាហរណ៍ ៣ខ។

**ឧទាហរណ៍ ៣ឃ**

ក្រុមហ៊ុនវិនិយោគគឺជាភាគីមួយចំពោះកិច្ចសន្យាអនាគតដើម្បីទទួលបាននីតិភាពនៃបណ្ណ័ភាគហ៊ុននៅក្នុងក្រុមហ៊ុនរងការវិនិយោគ ដោយមិនមានសិទ្ធិពាក់ពន្ធ័ផ្សេងទៀតលើក្រុមហ៊ុនរងការវិនិយោគ។ កាលបរិច្ឆេទទូទាត់ របស់កិច្ចសន្យាអនាគតមានចំនួន ៦ខែ។ ផ្ទុយនឹងឧទាហរណ៍ខាងលើ ក្រុមហ៊ុនវិនិយោគមិនមានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ឡើយ។ ម្ចាស់ភាគហ៊ុនបច្ចុប្បន្ន មានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ ពីព្រោះពួកគេអាចផ្លាស់ប្តូរបណ្តាគោលនយោបាយបច្ចុប្បន្នលើសកម្មពាក់ពន្ធ័មុនពេល ដែលកិច្ចសន្យាអនាគតត្រូវបានទូទាត់។

ខ២៥ សិទ្ធិ លើសលែងអាចអនុវត្តបានដោយបណ្តាភាគីផ្សេងៗ អាចរារាំងក្រុមហ៊ុនវិនិយោគ ពីការធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគដែលពាក់ពន្ធ័នឹងសិទ្ធិទាំងនោះ។ សិទ្ធិលើសលែងបែបនេះ មិនតម្រូវឲ្យអ្នកកាន់កាប់មានលទ្ធភាពផ្តួចផ្តើមការសម្រេចចិត្តឡើយ។ ដរាបណា សិទ្ធិទាំងនោះមិនមែនជាសិទ្ធិ ដែលមានការការពារ (មើលកថាខណ្ឌ ខ២៦-កថាខណ្ឌ ខ២៨), សិទ្ធិលើសលែងដែលកាន់កាប់ដោយបណ្តាភាគីផ្សេងៗ អាចរារាំងក្រុមហ៊ុន វិនិយោគមិនឲ្យមានអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគឡើយ បើទោះបីជាសិទ្ធិនោះផ្តល់ឲ្យអ្នកកាន់កាប់ នូវលទ្ធភាពបច្ចុប្បន្នដើម្បីអនុម័តឬរាំងខ្ទប់ការសម្រេចចិត្តទាក់ទងនឹងសកម្មភាពពាក់ពន្ធ័។

*សិទ្ធិដែលមានការការពារ*

ខ២៦ នៅក្នុងការវាយតម្លៃថាតើសិទ្ធិផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវអំណាច លើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណា, ក្រុមហ៊ុនវិនិយោគត្រូវវាយតម្លៃថាតើសិទ្ធិរបស់ខ្លួន, និងសិទ្ធិដែលកាន់កាប់ដោយអ្នកផ្សេង គឺជាសិទ្ធិដែលមានការការពារ។ សិទ្ធិដែលមានការការពាទាក់ទងនឹងការផ្លាស់ប្តូរជាមូលដ្ឋានចំពោះសកម្មភាពរបស់ក្រុមហ៊ុនរងការវិនិយោគ ឬអនុវត្តន៍ នៅក្នុងកាលៈទេសៈពិសេស។ ទោះបីជាយ៉ាងណា មិនមែនសិទ្ធិទាំងអស់ ដែលអនុវត្តនៅក្នុងកាលៈទេសៈពិសេស ឬដែលមានយថាភាពលើព្រឹត្តិការណ៍ គឺជាសិទ្ធិដែលមានការការពារ (មើល កថាខណ្ឌ ខ១៣ និង ខ៥៣)។

ខ២៧ ដោយសារតែ សិទ្ធិដែលមានការការពារត្រូវបានបង្កើតឡើង ដើម្បីការពារភាគកម្មរបស់អ្នកកាន់កាប់ ដោយមិនផ្តល់ឲ្យភាគីនោះនូវអំណាច លើ

ក្រុមហ៊ុនវិនិយោគដែលពាក់ពន្ធ័នឹងសិទ្ធិទាំងនោះ, ក្រុមហ៊ុនវិនិយោគមួយដែលកាន់កាប់តែភាគហ៊ុនដែលមានការការពារមិនអាចមានអំណាច ឬមិនអាចរារាំងភាគីមួយផ្សេងទៀត ពីការមានអំណាចលើក្រុមហ៊ុនរងការវិនិយោគបានឡើយ (មើល កថាខណ្ឌ១៤)។

ខ២៨ ឧទាហរណ៍អំពីសិទ្ធិដែលមានការការពាររួមមាន ប៉ុន្តែមិនកំណត់ត្រឹមៈ

(ក) សិទ្ធិរបស់ម្ចាស់បំណុល ដើម្បីដាក់កម្រិត ចំពោះអ្នកខ្ចីមិនឲ្យធ្វើសកម្មភាពដែលអាចធ្វើឲ្យមានការផ្លាស់ប្តូរជាដុំកំភួន លើហានិភ័យឥណទានរបស់អ្នកខ្ចីដែលនាំដល់ការខូចខាតប្រយោជន៍របស់ម្ចាស់បំណុល។

(ខ) សិទ្ធិរបស់ភាគីមួយដែលកាន់កាប់ភាគកម្មមិនអភិបាល នៅក្នុងក្រុមហ៊ុនរងការវិនិយោគ ដើម្បីអនុម័តលើគម្រោងការវិនិយោគរយៈពេលវែងដែលមានទំហំធំជាងអ្វីដែលបានតម្រូវនៅក្នុងសកម្មភាពអាជីវកម្មធម្មតា, ឬដើម្បីអនុម័តលើការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិឬឧបករណ៍ហិរញ្ញវត្ថុបំណុល។

(គ) សិទ្ធិរបស់ម្ចាស់បំណុលដើម្បីរឹបអូសយកទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ ប្រសិនបើអ្នកខ្ចី មិនបំពេញបានតាមលក្ខខណ្ឌនៃការទូទាត់ប្រាក់កម្ចីដែលមានកំណត់។

## ឯកសិទ្ធិ

ខ២៩ កិច្ចព្រមព្រៀងឯកសិទ្ធិដែលក្នុងនោះក្រុមហ៊ុនរងការវិនិយោគ គឺជាអ្នកទទួលឯកសិទ្ធិតែងតែផ្តល់ឲ្យអ្នកផ្តល់ឯកសិទ្ធិនូវសិទ្ធិ ដែលត្រូវបានបង្កើត

ឡើងដើម្បីការពារម៉ាកយីហោឯកសិទ្ធិ។ ជាធម្មតា កិច្ចព្រមព្រៀងឯកសិទ្ធិផ្តល់ឱ្យអ្នកផ្តល់ឯកសិទ្ធិនូវសិទ្ធិនៃការសម្រេចចិត្តមួយចំនួន ដោយយោងទៅតាមប្រតិបត្តិការរបស់អ្នកទទួលឯកសិទ្ធិ។

១៣០ ជាទូទៅសិទ្ធិរបស់អ្នកផ្តល់ឯកសិទ្ធិមិនកម្រិតអំពីលទ្ធភាព របស់បណ្តាភាគីផ្សេងៗដែលមិនមែនជាអ្នកផ្តល់ឯកសិទ្ធិ ដើម្បីធ្វើការសម្រេច ដែលមានផលប៉ះពាល់ប្រាក់ចំណេញរបស់អ្នកទទួលឯកសិទ្ធិ។មិនផ្តល់សិទ្ធិរបស់អ្នកផ្តល់ឯកសិទ្ធិនៅក្នុងកិច្ចព្រមព្រៀងផ្តល់ឯកសិទ្ធិដែលមាន ដើម្បីឱ្យអ្នកផ្តល់ឯកសិទ្ធិនូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពដែលមានផលប៉ះពាល់ជាដុំកំភួនដល់ប្រាក់ចំណេញរបស់អ្នកទទួលឯកសិទ្ធិ។

១៣១ វាជាការចាំបាច់ដើម្បីញែកចេញពីគ្មាននូវការមានលទ្ធភាពបច្ចុប្បន្ន ដើម្បីធ្វើការសម្រេចចិត្ត ដែលមានផលប៉ះពាល់ជាដុំកំភួន ដល់ប្រាក់ចំណេញរបស់អ្នកទទួលឯកសិទ្ធិ និងការមាលទ្ធភាពដើម្បីធ្វើការសម្រេចចិត្ត ដែលការពារម៉ាកយីហោឯកសិទ្ធិ។ អ្នកផ្តល់ឯកសិទ្ធិ មិនមានអំណាចលើអ្នកទទួលឯកសិទ្ធិឡើយប្រសិនបើ បណ្តាភាគីផ្សេងទៀតមានសិទ្ធិ ដែលមានស្រាប់ ដើម្បីផ្តល់ឱ្យពួកគេនូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័របស់អ្នកទទួលឯកសិទ្ធិ។

១៣២ ដោយការធ្វើកិច្ចព្រមព្រៀងឯកសិទ្ធិ អ្នកទទួលឯកសិទ្ធិបានធ្វើការសម្រេចចិត្ត ជាឯកតោភាគីដើម្បីដំណើរការអាជីវកម្មរបស់ខ្លួនយោងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងឯកសិទ្ធិ ប៉ុន្តែដើម្បីប្រយោជន៍របស់ខ្លួនផ្ទាល់។

២៣៣ ការធ្វើអភិបាលលើការសម្រេចចិត្តជាមូលដ្ឋាន ដូចជា ទម្រង់គតិយុត្តិរបស់អ្នកទទួលឯកសិទ្ធិ និងរចនាសម្ព័ន្ធទុនរបស់ខ្លួន អាចត្រូវបានកំណត់ដោយបណ្តាភាគីដែលមិនមែនជាអ្នកផ្តល់ឯកសិទ្ធិ និងអាចមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់អ្នកទទួលឯកសិទ្ធិ។ កម្រិតកាន់តែទាបនៃការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលបានធ្វើឡើង ដោយអ្នកផ្តល់ឯកសិទ្ធិ និងកម្រិតកាន់តែទាប ដែលការប្រឈមរបស់អ្នកផ្តល់ឯកសិទ្ធិ ទៅនឹងភាពងាយប្រែប្រួលនៃប្រាក់ចំណេញពីអ្នកទទួលឯកសិទ្ធិ វាកាន់តែថា អ្នកផ្តល់ឯកសិទ្ធិមានសិទ្ធិដែលមានការការពារ។

## សំលេងឆ្នោត

២៣៤ ជាញឹកញាប់ ក្រុមហ៊ុនវិនិយោគមានលទ្ធភាពបច្ចុប្បន្ន តាមរយៈសិទ្ធិបោះឆ្នោតឬសិទ្ធិស្រដៀង ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។ ក្រុមហ៊ុនវិនិយោគពិចារណាអំពីការតម្រូវនៅក្នុងផ្នែកនេះ (កថាខណ្ឌ ២៣៥ - ២៥០) ប្រសិនបើ សកម្មភាពពាក់ពន្ធ័របស់ក្រុមហ៊ុនរងការវិនិយោគ ត្រូវបានដឹកនាំតាមរយៈសំលេងឆ្នោត។

*អំណាចដែលមាននីតិភាពនៃសំលេងឆ្នោត*

២៣៥ ក្រុមហ៊ុនវិនិយោគដែលកាន់កាប់ច្រើនជាងពាក់កណ្តាល នៃសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគមានអំណាចក្នុងស្ថានភាពដូចខាងក្រោម ដរាបណា កថាខណ្ឌ ២៣៦ ឬ កថាខណ្ឌ២៣៧ អនុវត្តន៍ៈ

(ក) សកម្មភាពពាក់ពន្ធ័ត្រូវបានដឹកនាំ ដោយសំលេងឆ្នោតមួយសន្លឹករបស់អ្នកកាន់កាប់នីតិភាពនៃសំលេងឆ្នោត ឬ

(ខ) នីតិភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល ដែលដឹកនាំសកម្មភាពពាក់ពន្ធ័ត្រូវបានតែងតាំង ដោយសំលេងឆ្នោតរបស់អ្នកកាន់កាប់នីតិភាពនៃសំលេងឆ្នោត។

*នីតិភាពនៃសំលេងឆ្នោត ប៉ុន្តែមិនមានអំណាច*

ខ៣៦ សម្រាប់ក្រុមហ៊ុនវិនិយោគ ដែលកាន់កាប់ច្រើនជាងពាក់កណ្តាល នៃសំលេងឆ្នោត ដើម្បីមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ សំលេងឆ្នោតរបស់ក្រុមហ៊ុនវិនិយោគត្រូវតែមានភាពលើសលែង ដោយយោងតាមកថាខណ្ឌខ២២-កថាខណ្ឌ២៥ និងត្រូវតែផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ ដែលជាញឹកញាប់នឹងត្រូវធ្វើតាមរយៈការកំណត់គោលនយោបាយប្រតិបត្តិការនិងហិរញ្ញវត្ថុ។ ប្រសិនបើ អង្គភាពមួយផ្សេងទៀតមានសិទ្ធិដែលមានស្រាប់ ដែលផ្តល់ឲ្យអង្គភាពនោះនូវសិទ្ធិដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ ហើយអង្គភាពនោះមិនមែនជាភ្នាក់ងារមួយរបស់ក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនវិនិយោគនោះមិនមានអំណាច លើក្រុមហ៊ុនរងការវិនិយោគឡើយ។

ខ៣៧ ក្រុមហ៊ុនមិនមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឡើយ បើទោះបីជាក្រុមហ៊ុនវិនិយោគ កាន់កាប់នីតិភាពនៃ សំលេងឆ្នោតនៅក្នុងក្រុមហ៊ុនរងការវិនិយោគ នៅពេលដែលសិទ្ធិបោះឆ្នោតទាំងនោះ មិនមានភាពលើកលែង។ ឧទាហរណ៍ ក្រុមហ៊ុនវិនិយោគដែលមានសំលេងឆ្នោតច្រើនជាងពាក់កណ្តាល នៅក្នុងក្រុមហ៊ុនរងការវិនិយោគ មិនអាចមានអំណាចបានឡើយ ប្រសិនបើសកម្មភាពពាក់ពន្ធ័ត្រូវបានដឹកនាំ ដោយ

រដ្ឋាភិបាល ដោយតុលាការ ដោយភ្នាក់ងាររដ្ឋការ ដោយអ្នកទទួកបន្ទុក ដោយអ្នកជម្រះបញ្ជី ឬ ដោយនិយ័តករ។

*អំណាចដែលមិនមាននីតិភាពនៃសំលេងឆ្នោត*

ខ៣៨ ក្រុមហ៊ុនវិនិយោគ អាចមានអំណាច បើទោះបីជាខ្លួន កាន់កាប់សិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន រងការវិនិយោគតិចជាងនិតិភាព។ ក្រុមហ៊ុនវិនិយោគអាចមានអំណាច ដោយមានសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគតិចជាងនីតិភាព តាមរយៈ ឧទាហរណ៍ៈ

(ក) កិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យារវាងក្រុមហ៊ុនវិនិយោគ និងអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀត (មើលកថាខណ្ឌ ខ៣៩)

(ខ) សិទ្ធិដែលបានមកពីកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យា (មើល កថាខណ្ឌ ខ៤០)

(គ) សំលេងឆ្នោតរបស់ក្រុមហ៊ុនវិនិយោគ (មើលកថាខណ្ឌ ខ៤១ - កថាខណ្ឌ ខ៤៥)

(ឃ) សំលេងឆ្នោតសក្តានុពល (មើលកថាខណ្ឌ ខ៤៧-កថាខណ្ឌ ខ៥០) ឬ

(ង) ការរួមបញ្ចូលចំណុច (ក)-(ឃ)។

*កិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យាជាមួយអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀត*

ខ៣៩ កិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យារវាងក្រុមហ៊ុនវិនិយោគមួយ និងអ្នកាកាន់កាប់សំលេងឆ្នោតផ្សេងទៀតអាចផ្តល់ឲ្យអ្នកវិនិយោគនូវសិទ្ធិ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតដែលមានចំនួនគ្រប់គ្រាន់ដើម្បីផ្តល់អំណាចទៅ

ឲ្យក្រុមហ៊ុនវិនិយោគ បើទោះបីជាក្រុមហ៊ុនវិនិយោគមិនមានសំលេងឆ្នោតគ្រប់គ្រាន់ដើម្បីផ្តល់អំណាច ដល់ខ្លួនដោយមិនមានកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យា។ ទោះបីជាយ៉ាងណា កិច្ចព្រមព្រៀង ដែលបញ្ញតិដោយកិច្ចសន្យាអាចធានាថា ក្រុមហ៊ុនវិនិយោគអាចណែនាំអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀតអំពីរបៀបនៃការបោះឆ្នោត ដើម្បីអាចឲ្យក្រុមហ៊ុនវិនិយោគនោះធ្វើការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័។

*សិទ្ធិដែលបានមកពីកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យា*

ខ៤០ សិទ្ធិនៃការសម្រេចចិត្តផ្សេងទៀត ដោយរួមផ្សំជាមួយនឹងសិទ្ធិបោះឆ្នោតផ្សេងទៀត អាចផ្តល់ឲ្យក្រុមហ៊ុនវិនិយោគ នូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។ ឧទាហរណ៍ សិទ្ធិដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀង ដែលបញ្ញតិដោយកិច្ចសន្យាដោយរួមផ្សំជាមួយនឹងសិទ្ធិបោះឆ្នោតផ្សេងទៀតអាចមានចំនួនគ្រប់គ្រាន់ដើម្បីផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំដំណើរការផលិតកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ ឬដើម្បីដឹកនាំសកម្មប្រតិបត្តិការ និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗរបស់ក្រុមហ៊ុនរងការវិនិយោគ ដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។ទោះជាយ៉ាងណានៅពេលដែលមិនមានសិទ្ធិផ្សេងទៀតទេ ភាពពឹងអាស្រ័យខាងសេដ្ឋកិច្ចរបស់ក្រុមហ៊ុនរងការវិនិយោគទៅលើក្រុមហ៊ុនវិនិយោគ (ដូចជា ទំនាក់ទំនងរបស់អ្នកផ្គត់ផ្គង់ ជាមួយអតិថិជនសំខាន់ៗ) មិននាំឲ្យក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឡើយ។

*សំលេងឆ្នោតរបស់ក្រុមហ៊ុនវិនិយោគ*

២៤១ ក្រុមហ៊ុនវិនិយោគដែលកាន់កាប់សំលេងឆ្នោតតិចជាងនីតិភាពមានសិទ្ធិដែលគ្រប់គ្រាន់ដើម្បីផ្តល់អំណាចដល់ក្រុមហ៊ុនវិនិយោគ នៅពេលដែលក្រុមហ៊ុនវិនិយោគនោះមានលទ្ធភាពជាក់ស្តែងដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័ជាឯកតោភាគី។

២៤២ នៅពេលវាយតម្លៃថា តើសំលេងឆ្នោតរបស់ក្រុមហ៊ុនវិនិយោគមានគ្រប់គ្រាន់ ដើម្បីផ្តល់អំណាចឲ្យខ្លួន ឬយ៉ាងណា ក្រុមហ៊ុនវិនិយោគ ត្រូវពិចារណារាល់ហេតុការណ៍និងកាលៈទេសៈទាំងអស់ ដែលរួមមានៈ

(ក) ទំហំនៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនវិនិយោគ ធៀបទៅនឹងទំហំនិងភាពរាយប៉ាយនៃការកាន់កាប់សិទ្ធិរបស់អ្នកកាន់កាប់ផ្សេងទៀត ដោយកត់សំគាល់ថាៈ

(១) ក្រុមហ៊ុនវិនិយោគដែលកាន់កាប់សំលេងឆ្នោតកាន់តែច្រើន ក្រុមហ៊ុនវិនិយោគនោះកាន់តែមានសិទ្ធិបច្ចុប្បន្នកាន់តែច្រើន ដែលផ្តល់នូវលទ្ធភាពបច្ចុនប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

(២) ក្រុមហ៊ុនវិនិយោគ មានសំលេងឆ្នោត កាន់តែច្រើនឡើង ធៀបនឹងអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀត ក្រុមហ៊ុនវិនិយោគនឹងកាន់តែមានសិទ្ធិដែលមានស្រាប់ដែលនឹងផ្តល់ឲ្យខ្លួននូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

(៣) មានភាគីច្រើន ដែលនឹងត្រូវធ្វើសកម្មភាពរួមគ្នា ដើម្បីឲ្យមានសំលេងឆ្នោតលើសលុប លើក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនវិនិយោគនោះនឹងមានសិទ្ធិដែលមានស្រាប់កាន់តែច្រើន

ដើម្បីឲ្យខ្លួនមានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

(ខ) សំលេងបោះឆ្នោតជាសក្តានុពល ដែលកាន់កាប់ដោយក្រុមហ៊ុនវិនិយោគ កាន់កាប់ដោយអ្នកមានសំលេងឆ្នោតផ្សេងទៀត ឬបណ្ណាភាគីផ្សេងទៀត (មើល កថាខណ្ឌខ៤៧- កថាខណ្ឌ ខ៥០)

(គ) សិទ្ធិដែលបានមកពីកិច្ចព្រមព្រៀងដែលបញ្ញតិ ដោយកិច្ចសន្យាផ្សេងៗ (មើល កថាខណ្ឌ ខ៤០)

(ឃ) ហេតុការណ៍ និងព្រឹត្តិការណ៍បន្ថែមផ្សេងទៀត ដែលបង្ហាញថាក្រុមហ៊ុនវិនិយោគមាន ឬមិនមានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័នៅខណៈពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង ដោយរួមមាន បែបផែននៃការបោះឆ្នោតនៅកិច្ចប្រជុំម្ចាស់ភាគហ៊ុនពីលើកមុន។

ខ៤៣ នៅពេលដែលការដឹកនាំសកម្មភាពពាក់ពន្ធ័ត្រូវបានកំណត់ ដោយនីតិភាពនៃសំលេងឆ្នោត ហើយក្រុមហ៊ុនវិនិយោគមួយបានកាន់កាប់សំលេងឆ្នោតភាគច្រើនជាងអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀត ឬច្រើនជាងក្រុមនៃអ្នកកាន់កាប់សំលេងឆ្នោតផ្សេងទៀត និងប័ណ្ណភាគហ៊ុន ផ្សេងៗទៀត ត្រូវបានបែងចែកយ៉ាងទូលំទូលាយ បន្ទាប់ពីពិចារណាកត្តាផ្សេងទៀតដូចបានបង្ហាញនៅក្នុង កថាខណ្ឌ ៤២(ក)-(គ)តែមួយ វាអាចជាការច្បាស់លាស់មួយដែលថា ក្រុមហ៊ុនវិនិយោគមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ។

## ឧទាហរណ៍

### ឧទាហរណ៍ ៤

ក្រុមហ៊ុនវិនិយោគបានទិញយក៤៨ភាគរយនៃប័ណ្ណភាគហ៊ុនដែលមានសំលេងឆ្នោតពីក្រុមហ៊ុនរងការវិនិយោគ។ ប័ណ្ណភាគហ៊ុនដែលមានសំលេងឆ្នោតផ្សេងទៀតត្រូវបានកាន់កាប់ដោយកូនហ៊ុនរាប់ពាន់នាក់ផ្សេងទៀត ដែលក្នុងចំណោមពួកគេ មិនមានអ្នកណាម្នាក់កាន់កាប់ប័ណ្ណភាគហ៊ុនដែលមានសំលេងឆ្នោតច្រើនជាងមួយភាគរយនោះឡើយ។ មិនមានកូនហ៊ុនណាម្នាក់ មានកិច្ចព្រមព្រៀងសម្រាប់ការពិភាក្សាលើការសម្រេចចិត្តរួមណាមួយឡើយ។ នៅពេលវាយតម្លៃចំណែកណាមួយនៃប័ណ្ណភាគហ៊ុនមាន សំលេងឆ្នោតដើម្បីទិញយក ដោយមានការប្រៀបធៀបទៅនឹងចំណែកនៃការកាន់កាប់ប័ណ្ណភាគហ៊ុន ក្រុមហ៊ុនវិនិយោគបានកំណត់ថា ភាគកម្ម៤៨ភាគរយគឺជាចំនួនគ្រប់គ្រាន់សម្រាប់ការធ្វើពិបាក ។ នៅក្នុងករណីនេះ ផ្អែកលើទំហំដាច់ខាតនៃការកាន់កាប់និងទំហំ ប្រៀបធៀបរបស់កូនហ៊ុនផ្សេងទៀត ក្រុមហ៊ុនវិនិយោគអាចសន្និដ្ឋានថា ខ្លួនមានភាគកម្មគ្របដណ្តប់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ នៃការកំណត់អំណាចដោយមិនចាំបាច់ត្រូវពិចារណាភស្តុតាងផ្សេងទៀតឡើយ។

**ឧទាហរណ៍ ៤**

ក្រុមហ៊ុនវិនិយោគ **ក** កាន់កាប់ ៤០ភាគរយ នៃប័ណ្ណភាគហ៊ុនមានសំលេងឆ្នោតនៅក្នុងក្រុមហ៊ុនរងការវិនិយោគ ហើយវិនិយោគិន ១២នាក់ ផ្សេងទៀតកាន់កាប់បណ្ណ័ភាគហ៊ុនមានសំលេងឆ្នោត ៥ភាគរយ ក្នុងម្នាក់នៅក្នុងក្រុមហ៊ុនរងការវិនិយោគ។ កិច្ចព្រមព្រៀងរបស់ភូនហ៊ុនបានផ្តល់ឲ្យក្រុមហ៊ុនវិនិយោគ **ក**នូវសិទ្ធិដើម្បីតែងតាំង ដកចេញ និងកំណត់លាភការរបស់អ្នកគ្រប់គ្រងដែលទទួលខុសត្រូវលើការដឹកនាំសកម្មភាពពាក់ពន្ធ័។ ដើម្បីផ្លាស់ប្តូរកិច្ចព្រមព្រៀង ពួកគេត្រូវមានសំលេងឆ្នោតនីតិភាពចំនួនពីរភាគបី។ នៅក្នុងករណីនេះ ក្រុមហ៊ុនវិនិយោគ **ក** សន្និដ្ឋានថា ទំហំដាច់ខាតនៃការកាន់កាប់របស់ក្រុមហ៊ុនវិនិយោគ និងទំហំប្រៀបធៀបនៃការកាន់កាប់ប័ណ្ណភាគហ៊ុនតែប៉ុណ្ណឹងមិនប្រាកដជាកំណត់បានថា ក្រុមហ៊ុនវិនិយោគមានសិទ្ធិគ្រប់គ្រាន់ ដើម្បីទទួលបានអំណាចនោះឡើយ។  ទោះជាយ៉ាងណា ក្រុមហ៊ុនវិនិយោគ **ក** កំណត់ថាសិទ្ធិតាមកុងត្រារបស់ខ្លួនដើម្បីតែងតាំង ដកចេញ និងកំណត់លាភការរបស់អ្នកគ្រប់គ្រងក្រុមហ៊ុនមានចំនួនគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ខ្លួនមានអំណាចទៅលើក្រុមហ៊ុនរងការវិនិយោគ។ ការពិតដែលថា ក្រុមហ៊ុនវិនិយោគ **ក**អាចមិនអនុវត្តសិទ្ធិនេះ ឬលទ្ធភាពដែលថាក្រុមហ៊ុនវិនិយោគ **ក** នឹងអនុវត្តសិទ្ធិរបស់ខ្លួន ដើម្បីជ្រើសរើសតែងតាំងនិងដកចេញ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនមិនត្រូវបានយកមកពិចារណាឡើយនៅពេលធ្វើការវាយតម្លៃថាតើ ក្រុមហ៊ុនវិនិយោគ **ក** មានអំណាច ឬយ៉ាងណា។

២៤៤ នៅក្នុងស្ថានភាពផ្សេងទៀត វាអាចច្បាស់លាស់ថា បន្ទាប់ពីពិចារណានូវកត្តានានា ដែលបានដាក់បង្ហាញនៅក្នុង កថាខណ្ឌ ២៤២(ក)-(គ) តែមួយក្រុមហ៊ុនវិនិយោគមិនមានអំណាចឡើយ។

| **ឧទាហរណ៍** |
| --- |
| **ឧទាហរណ៍ ៦**<br><br>ក្រុមហ៊ុនវិនិយោគ **ក** កាន់កាប់៤៥ភាគរយ នៃប័ណ្ណភាគហ៊ុនមានសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ។ វិនិយោគិនពីរនាក់ផ្សេងទៀតកាន់កាប់ ២៦ ភាគរយ នៃប័ណ្ណភាគហ៊ុនក្នុងម្នាក់ៗ នៅក្នុងក្រុមហ៊ុនរងការវិនិយោគនេះ។ បណ្ណ័ភាគហ៊ុននៅសល់ ត្រូវបានកាន់កាប់ដោយភូនហ៊ុន ៣នាក់ ផ្សេងទៀត ដែលម្នាក់ៗកាន់កាប់ ១ភាគរយ។ មិនមានកិច្ចព្រមព្រៀងណា ដែលប៉ះពាល់ដល់ការសម្រេចចិត្តឡើយ។ នៅក្នុងករណីនេះ ទំហំកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនវិនិយោគ **ក** និងទំហំប្រៀបធៀបរបស់ខ្លួនជាមួយនឹងវិនិយោគិនផ្សេងទៀត មានចំនួនគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ក្រុមហ៊ុនវិនិយោគ **ក** មិនមានអំណាច។ មានតែវិនិយោគគិនពីរប៉ុណ្ណោះ ដែលត្រូវសហការគ្នា ដើម្បីអាចរារាំងក្រុមហ៊ុនវិនិយោគ **ក** មិនឲ្យដឹកនាំសកម្មភាពពាក់ពន្ធ័របស់ក្រុមហ៊ុនរងការវិនិយោគ។ |

២៤៥ ទោះជាយ៉ាងណា បណ្តាកត្តាដែលបង្ហាញនៅក្នុងកថាខណ្ឌ ២៤២(ក)-(គ) តែឯង អាចមិនប្រាកដប្រជា។ ប្រសិនបើក្រុមហ៊ុនវិនិយោគ ដោយបានពិចារណានូវកត្តាទាំងនោះ មិនច្បាស់លាស់ថាតើ ខ្លួនមានអំណាច ឬ

យ៉ាងណា ក្រុមហ៊ុនវិនិយោគនោះ ត្រូវពិចារណាលើហេតុកាណ៍ និង កាលៈទេសៈ មួយចំនួនបន្ថែមទៀត ដូចជា ថាតើកូនហ៊ុនដ៏ទៃទៀត មិនជំទាស់ប្រឆាំងដូចដែលបានបង្ហាញតាមរយៈបែបផែននៃការបោះឆ្នោត នៅឯ កិច្ចប្រជុំរបស់ម្ចាស់ភាគហ៊ុនកាលពីគ្រាកន្លងមក។នេះរួមមានការ វាយតម្លៃនូវបណ្តាកត្តាមួយចំនួនដែលបានកំណត់នៅក្នុងកថាខណ្ឌ ខ១៨ និងបណ្តាសូចនាករនៅក្នុងកថាខណ្ឌខ១៩ និង ខ២០។វិនិយោគិនដែល កាន់កាប់សំលេងបោះឆ្នោតកាន់តែតិច និងមានភាគីតិចតួច ដែលធ្វើ សកម្មភាពរួមគ្នាដើម្បីប្រឆាំងនឹងក្រុមហ៊ុនវិនិយោគ នោះនឹងកាន់តែធ្វើឲ្យ ក្រុមហ៊ុនវិនិយោគកាន់តែមានអំណាចកាន់តែគ្រប់គ្រាន់។ នៅពេលដែល ហេតុការណ៍និងកាលៈទេសៈនៅក្នុង កថាខណ្ឌខ១៨ - កថាខណ្ឌខ២០ ត្រូវបានពិចារណារួមគ្នាជាមួយនឹងសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគ ភាពមាន ទំងន់ ត្រូវបានផ្តល់ឲ្យដើម្បីធ្វើជាភស្តុតាងនៃអំណាចនៅក្នុង កថាខណ្ឌ ខ១៨ ច្រើនជាងបណ្តាសូចនាករនៃអំណាចនៅក្នុងកថាខណ្ឌ ខ១៩ និង ខ២០។

| **ឧទាហរណ៍** |
|---|
| **ឧទាហរណ៍ ៧**<br>ក្រុមហ៊ុនវិនិយោគមួយកាន់កាប់ប័ណ្ណភាគហ៊ុនមានសំលេងឆ្នោតចំនួន ៤៥ ភាគរយ នៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនរងការវិនិយោគ។ កូនហ៊ុនចំនួន ១១ |

នាក់ ផ្សេងទៀត កាន់កាប់ប័ណ្ណភាគហ៊ុនក្នុងម្នាក់ៗចំនួន ៥ភាគរយ នៃបណ្ណ័ភាគហ៊ុនរបស់ក្រុមហ៊ុនរងការវិនិយោគ។ មិនមានកូនហ៊ុនណាមួយ មានកិច្ចព្រមព្រៀង ដែលបញ្ញតិដោយកិច្ចសន្យា ដើម្បីពិគ្រោះជាមួយកូនហ៊ុនផ្សេងទៀត ឬដើម្បីធ្វើការសម្រេចចិត្តរួមឡើយ។នៅក្នុងករណីនេះ ទំហំដាច់ខាតនៃការកាន់កាប់របស់ក្រុមហ៊ុនវិនិយោគ និងទំហំប្រៀបធៀបរបស់កូនហ៊ុនដទៃតែឯងមិនប្រាកដជាកំណត់បានថាតើ ក្រុមហ៊ុនវិនិយោគ មានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបានអំណាច លើក្រុមហ៊ុនរងការវិនិយោគ ឬយ៉ាងណាឡើយ។ ហេតុការណ៍ និងកាលៈទេសៈបន្ថែមទៀតនឹងត្រូវពិចារណាដើម្បីអាចផ្តល់នូវភស្តុតាងថា ក្រុមហ៊ុនវិនិយោគមានអំណាចឬមិនមានអំណាច។

### ឧទាហរណ៍ ៨

ក្រុមហ៊ុនវិនិយោគមួយកាន់កាប់ប័ណ្ណភាគហ៊ុន មានសំលេងឆ្នោតចំនួន ៣៥ ភាគរយនៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនរងការវិនិយោគ។ កូនហ៊ុនចំនួន ៣នាក់ទៀតកាន់កាប់ប័ណ្ណភាគហ៊ុន ក្នុងម្នាក់ៗចំនួន ៥ភាគរយ នៃបណ្ណ័ភាគហ៊ុនរបស់ក្រុមហ៊ុនរងការវិនិយោគ។ ប័ណ្ណភាគហ៊ុនដែលនៅសល់ត្រូវបានកាន់កាប់ដោយកូនហ៊ុនផ្សេងៗទៀតជាច្រើននាក់ ដែលក្នុងម្នាក់ៗ កាន់កាប់បណ្ណ័ភាគហ៊ុនតិចជាង ១ភាគរយ។ មិនមានកូនហ៊ុនណាម្នាក់មានកិច្ចព្រមព្រៀង ដើម្បីពិគ្រោះគ្នាឬដើម្បីធ្វើការសម្រេចចិត្តរួមគ្នាឡើយ។ ការសម្រេចចិត្តអំពីសកម្មភាពពាក់ពន្ធ័របស់ ក្រុមហ៊ុនរងការវិនិយោគតម្រូវឲ្យមានការអនុម័តយល់ព្រម ក្នុង

សំលេងនីតិភាព ដែលត្រូវបោះឆ្នោតនៅកិច្ចប្រជុំ ដែលពាក់ពន្ធ័របស់ម្ចាស់ភាគហ៊ុន។ នៅក្នុងករណីនេះ ការចូលរួមយ៉ាងសកម្មរបស់កូនហ៊ុនផ្សេងទៀតនៅឯកិច្ចប្រជុំថ្មីៗរបស់ម្ចាស់ភាគហ៊ុនបង្ហាញថាក្រុមហ៊ុនវិនិយោគមិនមានលទ្ធភាពជាក់ស្តែង ដើម្បីដឹកនាំសកម្មពាក់ពន្ធ័ជាឯកតោភាគី ដោយមិនគិតអំពីថាតើ ក្រុមហ៊ុនវិនិយោគបានដឹកនាំសកម្មពាកើពន្ធ័ដោយសារតែមានចំនួនគ្រប់គ្រាន់ នៃកូនហ៊ុនផ្សេងទៀតបានបោះឆ្នោតតាមរបៀបដូចគ្នាដូចក្រុមហ៊ុនវិនិយោគដែរ។

ខ៤៦ ប្រសិនបើ ដោយបានពិចារណាបណ្តាកត្តាដែលបង្ហាញនៅក្នុងកថាខណ្ឌ ខ៤២(ក)-(ឃ) វានៅតែមិនច្បាស់លាស់ថាក្រុមហ៊ុនវិនិយោគមានអំណាច ឬយ៉ាងណាក្រុមហ៊ុនវិនិយោគ មិនធ្វើអភិបាលភាព លើក្រុមហ៊ុនរងការវិនិយោគឡើយ។

*សិទ្ធិបោះឆ្នោតសក្តានុពល*

ខ៤៧ នៅពេលវាយតម្លៃ លើអភិបាលភាព ក្រុមហ៊ុនវិនិយោគពិចារណាសិទ្ធិបោះឆ្នោតសក្តានុពលរបស់ខ្លួនក៏ដូចជាសិទ្ធិបោះឆ្នោតសក្តានុពល ដែលបានកាន់កាប់ដោយភាគីផ្សេងទៀត ដើម្បីកំណត់ថា តើខ្លួនមានអំណាច ឬយ៉ាងណា។ សិទ្ធិបោះឆ្នោតសក្តានុពលគឺជាសិទ្ធិទទួលបាននូវសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ ដូចជាសិទ្ធដែលកើតចេញពីឧបករណ៍ហិរញ្ញវត្ថុដែលអាចបំប្លែងបាន ឬជម្រើសពិសេស រួមមានទាំង កិច្ចសន្យាអនាគតផងដែរ។ សិទ្ធិបោះឆ្នោតសក្តានុពល ត្រូវបានពិចារណាតែក្នុង

ករណីដែល សិទ្ធិនោះមានភាពលើសលែង (មើលកថាខណ្ឌ ខ២២ - ខ២៥)។

ខ៤៨ នៅពេលពិចារណាសិទ្ធិបោះឆ្នោតសក្តានុពល ក្រុមហ៊ុនវិនិយោគ ត្រូវពិចារណាអំពីគោលបំណង និងការបង្កើតឧបករណ៍ហិរញ្ញវត្ថុ ក៏ដូចជាគោលបំណងនិងការបង្កើតការពាក់ពន្ធ័ផ្សេងទៀតដែលក្រុមហ៊ុនវិនិយោគមានជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ។ នេះរួមមានការវាយតម្លៃលក្ខខណ្ឌ និងការកម្រិតផ្សេងៗរបស់ឧបករណ៍ហិរញ្ញវត្ថុក៏ដូចជាការរំពឹងចំណង់ និងហេតុផលយ៉ាងច្បាស់លាស់របស់ក្រុមហ៊ុនវិនិយោគសម្រាប់ការព្រមព្រៀងចំពោះលក្ខខណ្ឌទាំងនោះ។

ខ៤៩ ប្រសិនបើ ក្រុមហ៊ុនវិនិយោគមានសិទ្ធិបោះឆ្នោត ឬសិទ្ធិនៃការសម្រេចចិត្តផ្សេងទៀតទាក់ទងនឹងសកម្មភាពរបស់ ក្រុមហ៊ុនរងការវិនិយោគ ក្រុមហ៊ុនវិនិយោគ វាយតម្លៃថាតើសិទ្ធិទាំងនោះ ដោយគួបផ្សំជាមួយនឹងសិទ្ធិសក្តានុពល នឹងផ្តល់អំណាចឲ្យក្រុមហ៊ុនវិនិយោគ។

ខ៥០ សិទ្ធិបោះឆ្នោតលើសលែងតែឯកឯង ឬដោយការគួបផ្សំជាមួយនឹង សិទ្ធិផ្សេងទៀត អាចផ្តល់ឲ្យក្រុមហ៊ុនវិនិយោគ នូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។ ឧទាហរណ៍ នេះគឺដូចជាករណី ដែលក្រុមហ៊ុនវិនិយោគកាន់កាប់សិទ្ធិបោះឆ្នោត ៤០ភាគរយ នៅក្នុងក្រុមហ៊ុនរងការវិនិយោគ និងដោយយោងតាម កថាខណ្ឌ ខ២៣ កាន់កាប់សិទ្ធិ លើកលែង ដែលកើតចេញពីជម្រើសពិសេស ដើម្បីទទួលបានសិទ្ធិបោះឆ្នោត ២០ភាគរយបន្ថែមទៀត។

| ឧទាហរណ៍ |
| --- |
| **ឧទាហរណ៍ ៩**<br>ក្រុមហ៊ុនវិនិយោគ **ក** កាន់កាប់ ៧០ភាគរយ នៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ។ ក្រុមហ៊ុនវិនិយោគ **ខ** មាន ៣០ភាគរយ នៃសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ និងមានជម្រើសពិសេសដើម្បី ទទួលបានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុនវិនិយោគ **ក** ចំនួនពាក់កណ្តាល។ ជម្រើសពិសេសអាចអនុវត្តនបាន ក្នុងរយៈពេល ២ឆ្នាំ ខាងមុខទៀតតាមថ្លៃថេរមួយ ដែលមានតម្លៃជាទឹកប្រាក់យ៉ាងច្រើន (និងត្រូវរំពឹងថា នឹងមានស្ថានភាពបែបនេះសម្រាប់រយៈពេលពីរឆ្នាំទៀត)។ ក្រុមហ៊ុនវិនិយោគ **ក** បានអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន និងបានដឹកនាំយ៉ាងសកម្ម លើសកម្មភាពពាក់ពន្ធ័ របស់ក្រុមហ៊ុនរងការវិនយោគ។នៅក្នុងករណីនេះ ក្រុមហ៊ុនវិនិយោគ **ក** បានបំពេញលក្ខណៈវិនិច្ឆ័យអំពីអំណាចពីព្រោះវាច្បាស់លាស់ថា ខ្លួនមានលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។ ទោះបីជា ក្រុមហ៊ុនវិនិយោគ **ខ** មានជម្រើសដែលអាចអនុវត្តបាន នាពេលបច្ចុប្បន្ន ដើម្បីទិញសិទ្ធិបោះឆ្នោតបន្ថែមទៀត (ប្រសិនបើ បានអនុវត្តមែន វានឹងផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវនីតិភាព នៃសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនរងការវិនិយោគ) លក្ខខណ្ឌនិងការកម្រិតដែលពាក់ពន្ធ័ជាមួយនឹងជម្រើសពិសេសទាំងនោះ ដែលជម្រើសពិសេសនោះ មិនត្រូវបានពិចារណាថាលើសលែងឡើយ។ |

**ឧទាហរណ៍ ១០**

ក្រុមហ៊ុនវិនិយោគ **ក** និងវិនិយោគិនពីរផ្សេងទៀត ដែលម្នាក់ៗកាន់កាប់មួយភាគបី នៃបណ្ណ័ភាគហ៊ុនមានសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ។ សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនរងការវិនិយោគមានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនវិនិយោគ **ក** ។ជាការបន្ថែមលើឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិក្រុមហ៊ុនវិនិយោគ **ក** ក៏បានកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុបំណុលដែលអាចបំប្លែងទៅជាបណ្ណ័ភាគហ៊ុនធម្មតារបស់ក្រុមហ៊ុនរងការវិនិយោគនៅពេលណាក៏បាន តាមថ្លៃថេរមួយ ដែលមានតម្លៃជាទឹកប្រាក់ច្រើន (ប៉ុន្តែ មិនមែនមានតម្លៃទឹកប្រាក់ច្រើនលើសលុបនោះទេ)។ ប្រសិនបើ បំណុលត្រូវបានបំប្លែងក្រុមហ៊ុនវិនិយោគ ក នឹងបានកាន់កាប់ ៦០ភាគរយ នៃបណ្ណ័ភាគហ៊ុនរបស់ក្រុមហ៊ុនរងការវិនិយោគ។ ក្រុមហ៊ុនវិនិយោគ **ក** នឹងទទួលបានអត្ថប្រយោជន៍ពីកំលាំងសំយោគ ប្រសិនបើ ឧបករណ៍បំណុលត្រូវបានបំប្លែងទៅជាភាគហ៊ុនធម្មតា។ ក្រុមហ៊ុនវិនិយោគ **ក** មានអំណាចលើក្រុមហ៊ុនរងការវិនិយោគដោយសារតែខ្លួនបានកាន់កាប់បណ្ណ័ភាគហ៊ុនមានសំលេងឆ្នោតរបស់ក្រុមហ៊ុនរងការវិនិយោគ បូកផ្សំជាមួយនឹងសិទ្ធិបោះឆ្នោតសក្តានុពលលើសលែង ដែលផ្តល់ឲ្យខ្លួននូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

**អំណាច នៅពេលដែលសិទ្ធិបោះឆ្នោត ឬសិទ្ធិប្រហាក់ប្រហែល មិនមានផលប៉ះពាល់ជាដុំកំភ្នួនលើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ**

ខ៥១ នៅក្នុងការវាយតម្លៃលើគោលបំណងនិងការបង្កើតរបស់ក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌខ៥-ខ៨) ក្រុមហ៊ុនវិនិយោគត្រូវពិចារណានូវការពាក់ពន្ធ័នឹងការសម្រេចចិត្តនៅពេលនៃការចាប់ផ្តើមដំបូងរបស់ក្រុម

ហ៊ុនរងការវិនិយោគ ដែលជាផ្នែកមួយនៃការបង្កើតនិងវាយតម្លៃថាតើលក្ខខណ្ឌប្រតិបត្តិការនិងលក្ខណៈពិសេសនៃការពាក់ពន្ធ័ផ្តល់ឲ្យក្រុមហ៊ុនវិនិយោគនូវសិទ្ធិដែលមានគ្រប់គ្រាន់ដើម្បីទទួលបានអំណាចឬយ៉ាងណា។ ដោយការ ពាក់ពន្ធ័នឹងការបង្កើតក្រុមហ៊ុនរងការវិនិយោគតែឯកឯង គឺមិនគ្រប់គ្រាន់ផ្តល់ឲ្យក្រុមហ៊ុនវិនិយោគ នូវអភិបាលភាពឡើយ។ ទោះជាយ៉ាងណា ការពាក់ពន្ធ័នឹងការបង្កើតអាចបង្ហាញថា ក្រុមហ៊ុនវិនិយោគមានឱកាសទទួលបាននូវសិទ្ធិយ៉ាងគ្រប់គ្រាន់ដើម្បីឲ្យខ្លួនមានអំណាច។

ខ៥២ ជាការបន្ថែម ក្រុមហ៊ុនវិនិយោគត្រូវពិចារណាកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យា ដូចជា សិទ្ធិនៃការទិញមកវិញបណ្ណ័ភាគហ៊ុន សិទ្ធិនៃការដាក់លក់បណ្ណ័ភាគហ៊ុន និងសិទ្ធិនៃការជម្រះបញ្ជី ដែលបានបង្កើតឡើងនៅពេលនៃការចាប់ផ្តើមដំបូងរបស់ក្រុមហ៊ុនរងការវិនិយោគ។ នៅពេលដែលកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យាទាំងនេះពាក់ពន្ធ័នឹងសកម្មភាព ដែលមានការទាក់ទងយ៉ាងជិតស្និទជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ សកម្មភាពទាំងនេះជាខ្លឹមសារ គឺជាផ្នែកមួយនៃសកម្មភាពរួមរបស់ក្រុមហ៊ុនរងការវិនិយោគ បើទោះបីជាសកម្មភាពទាំងនោះ អាចកើតឡើងនៅខាងក្រៅក្របខណ្ឌច្បាប់របស់ក្រុមហ៊ុនរងការវិនិយោគ ក៏ដោយ។ ហេតុដូច្នេះ សិទ្ធិនៃការសម្រេចចិត្តនិប្បរិយាយ ឬការសម្រេចចិត្តវាទរហិត ដែលបង្កប់នៅក្នុងកិច្ចព្រមព្រៀងដែលបញ្ញតិដោយកិច្ចសន្យាមានការទាក់ទងយ៉ាងជិតស្និទ ទៅនឹងក្រុមហ៊ុនរងការវិនិយោគ ដែលចាំបាច់ត្រូវតែចាត់ទុកថាជាសកម្មភាពពាក់ពន្ធ័នៅពេលកំណត់អំពីអំណាចទៅលើក្រុមហ៊ុនរងការវិនិយោគ។

ខ៥៣ សម្រាប់ក្រុមហ៊ុនរងការវិនិយោគខ្លះ សកម្មភាពពាក់ពន្ធ័កើតឡើងតែនៅពេលដែលកាលៈទេសៈជាក់លាក់ខ្លះកើតឡើង ឬព្រឹត្តិការណ៍ខ្លះលេចឡើងតែប៉ុណ្ណោះ។ ក្រុមហ៊ុនវិនិយោគអាចត្រូវបានគេបង្កើតឡើង ដែលទិសដៅសកម្មភាពនិងប្រាក់ចំណេញរបស់វាត្រូវបានគេកំណត់ទុកជាមុនរហូតទាល់តែ កាលៈទេសៈឬព្រឹត្តិការណ៍ទាំងនោះកើតឡើង។ នៅក្នុងករណីនេះ មានតែការសម្រេចចិត្តអំពីសកម្មភាពរបស់ក្រុមហ៊ុនរងការនិវិយោគទេ ដែលកាលៈទេសៈនិងព្រឹត្តិការណ៍ទាំងនោះកើតឡើង អាចមានផលប៉ះពាល់ជាដុំកំភ្ជួនលើប្រាក់ចំណេញរបស់វា ដូច្នេះហើយ ទាំងនេះគឺជាសកម្មភាពពាក់ពន្ធ័។ កាលៈទសៈនិងព្រឹត្តិការណ៍ទាំងនោះ មិនចាំបាច់កើតឡើងឡើយ សម្រាប់ក្រុមហ៊ុនវិនិយោគ ដែលមានលទ្ធភាពធ្វើការសម្រេចចិត្ត ជាមួយនឹងអំណាចដែលមាន។ ហេតុការណ៍ដែលសិទ្ធិធ្វើការសម្រេចចិត្តមានយថាភាពលើកាលៈទេសៈដែលកើតឡើង ឬព្រឹត្តិការណ៍ ដែលកំពុងកើតឡើង មិនធ្វើឲ្យសិទ្ធិទាំងនោះក្លាយជាសិទ្ធិដែលមានការការពារនោះឡើយ។

| **ឧទាហរណ៍** |
|---|
| **ឧទាហរណ៍ ១១**<br>សកម្មភាពអាជីវកម្ម តែមួយគត់របស់ក្រុមហ៊ុនរងការវិនិយោគ ដូចបានចែងនៅក្នុងឯកសារនៃការបង្កើតក្រុមហ៊ុន គឺត្រូវទិញយកបរិមាណត្រូវទារ និងលក់ |

វាជាប្រចាំថ្ងៃទៅឲ្យក្រុមហ៊ុនវិនិយោគ។ ការធ្វើសេវាកម្មប្រចាំថ្ងៃរួមមាន ការប្រមូលនិងការផ្ទេរបញ្ជូនប្រាក់ដើមនិងការប្រាក់ណាដែលប្រមូលបានតាមការកំណត់។ នៅពេលមានការបោកប្រាស់មិនសងនូវបរិមាណត្រូវទារ ក្រុមហ៊ុនវិនិយោគ ដាក់បញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងគណនីរបស់ក្រុមហ៊ុនវិនិយោគ ដូចដែលបានព្រមព្រៀងដោយឡែកពីគ្នានៅក្នុងកិច្ចព្រមព្រៀងទិញ-លក់ រវាងក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនរងការវិនិយោគ។ សកម្មភាពពាក់ពន្ធ័តែមួយគត់គឺការគ្រប់គ្រងគណនីត្រូវទារកុំឲ្យមានការបោកប្រាស់ដោយការមិនសង ពីព្រោះវាជាសកម្មភាពតែមួយគត់ដែលអាចមានផលប៉ះពាល់ជាដុំកំភួនលើផលចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។ ការគ្រប់គ្រងគណនីត្រូវទារមុនពេលមានការបោកប្រាស់ដោយការមិនសង មិនមែនជាសកម្មភាពពាក់ពន្ធ័ទេ ពីព្រោះវាមិនតម្រូវឲ្យមានការសម្រេចចិត្តលើសលែង ដែលអាចមានផលប៉ះពាល់លើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគឡើយ-- សកម្មភាពមុនពេលលមានការមិនសង ត្រូវបានកំណត់ទុកមុន និងជាបរិមាណ ដែលត្រូវតែប្រមូលជាសាច់ប្រាក់នៅពេលដល់កំណត់សងនិងផ្ទេរវាទៅឲ្យក្រុមហ៊ុនការវិនិយោគ។ដូច្នេះមានតែសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគក្នុងការគ្រប់គ្រងទ្រព្យសកម្មដែលមានការមិនសងប៉ុណ្ណោះនឹងត្រូវពិចារណានៅពេលមានការវាយតម្លៃលើសកម្មភាពរួមរបស់ក្រុមហ៊ុនរងការវិនិយោគដែលមានផលប៉ះពាល់ជាដុំកំភួន លើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ។ ក្នុងឧទាហរណ៍នេះ ការបង្កើតក្រុមហ៊ុនរង

ការវិនិយោគគឺដើម្បីធានាថា ក្រុមហ៊ុនវិនិយោគមានសិទ្ធិអំណាចក្នុងការធ្វើការសម្រេចចិត្តលើសកម្មភាពដែលមានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញ តែនៅពេលដែលត្រូវធ្វើការសម្រេចចិត្តប៉ុណ្ណោះ។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងទិញ-លក់ គឺជាផ្នែកមួយនៃសកម្មភាពទាំងមូល និងការបង្កើតក្រុមហ៊ុនរងការវិនិយោគ។ ហេតុដូច្នេះ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងទិញ-លក់ រួមផ្សំជាមួយនឹងឯកសារ នៃការបង្កើតក្រុមហ៊ុនរងការវិនិយោគ នាំឲ្យមានការសន្និដ្ឋានថាក្រុមហ៊ុនវិនិយោគ មានអំណាចលើក្រុមហ៊ុនរងការវិនិយោគ បើទោះបីជាក្រុមហ៊ុនវិនិយោគកាន់កាប់គណនី ត្រូវទារតែនៅពេលមានការបោកប្រាស់មិនសងក៏ដោយ និងគ្រប់គ្រងគណនីត្រូវទារដែលស្ថិតនៅក្រៅក្របខណ្ឌច្បាប់របស់ក្រុមហ៊ុនរងការវិនិយោគ។

**ឧទាហរណ៍ ១២**

ទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគគឺមានតែគណនីត្រូវទារប៉ុណ្ណោះ។នៅពេលដែលគោលបំណង និងការបង្កើតក្រុមហ៊ុនរងការវិនិយោគ ត្រូវបានពិចារណា គេត្រូវកំណត់ថា មានតែសកម្មភាពពាក់ពន្ធ័មួយប៉ុណ្ណោះ នោះគឺការគ្រប់គ្រងគណនីត្រូវទារអាស្រ័យលើការបោកប្រាស់មិនសង។ ភាគីដែលមានលទ្ធភាពគ្រប់គ្រងការបោកប្រាស់មិនសងនៃគណនីត្រូវទារ មានអំណាចទៅលើក្រុមហ៊ុនរងការវិនិយោគ ដោយមិនគិតថា អ្នកខ្ចីណាមួយធ្វើការបោកប្រាស់មិនសងឡើយ។

៦៥៤ ក្រុមហ៊ុនវិនិយោគមួយ អាចមានការតាំងចិត្តនិប្បរិយាយ និងវាទរហិត ដើម្បីធានាថា ក្រុមហ៊ុនរងការវិនិយោគបន្តប្រតិបត្តិការ ដូចបានបង្កើតឡើង។ ការតាំងចិត្តបែបនេះអាចបង្កើនការប្រឈមរបស់ក្រុមហ៊ុនវិនិយោគចំពោះភាពងាយប្រែប្រួលនៃប្រាក់ចំណេញ និងហេតុដូច្នេះ វាជាការបង្កើននូវគ្រឿងលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនវិនិយោគទទួលបាននូវ សិទ្ធិគ្រប់គ្រាន់ដើម្បីបានអំណាច។ ដូច្នេះ ការតាំងចិត្តដើម្បីធានាថា ក្រុមហ៊ុនរងការវិនិយោគធ្វើប្រតិបត្តិការដូចដែលបានកំណត់ អាចជាសូចនាករមួយដែលថាក្រុមហ៊ុរងការវិនិយោគមានអំណាច ប៉ុន្តែ ដោយឯកឯង មិនផ្តល់អំណាចដល់ក្រុមហ៊ុនវិនិយោគ ឬក៏មិនរារាំងភាគីផ្សេងទៀត មិនឲ្យមានអំណាចនោះឡើយ។

**ការប្រឈម ឬ សិទ្ធិ ចំពោះប្រាក់ចំណេញអថេរដែលបានពីក្រុមហ៊ុនរងការវិនិយោគ**

៦៥៥ នៅពេលវាយតម្លៃ ការអភិបាលរបស់ក្រុមហ៊ុនវិនិយោគ លើក្រុមហ៊ុនរងការវិនិយោគ ក្រុមហ៊ុនវិនិយោគកំណត់ថា តើខ្លួនត្រូវប្រឈម ឬមានសិទ្ធិចំពោះប្រាក់ចំណេញអថេរដែលបានមកពីការពាក់ពន្ធ័ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ ឬយ៉ាងណា។

៦៥៦ ប្រាក់ចំណេញអថេរគឺជាប្រាក់ចំណេញដែលមិនថេរ និងមានសក្តានុពលប្រែប្រួលទៅតាមលទ្ធផលរបស់ក្រុមហ៊ុនរងការវិនិយោគ។ ប្រាក់ចំណេញ

ប្រែប្រួលអាចជាវិជ្ជមាន និងអវិជ្ជមានផង (មើលកថាខណ្ឌ១៥)។ ក្រុមហ៊ុនវិនិយោគត្រូវវាយតម្លៃថាតើប្រាក់ចំណេញ របស់ក្រុមហ៊ុនរងការវិនិយោគជាផលចំណេញប្រែប្រួលឬយ៉ាងណា និង ថាតើវាមានកម្រិតប្រែប្រួលយ៉ាងណាដោយផ្អែកលើខ្លឹមសារនៃកិច្ចព្រមព្រៀង និង ដោយមិនគិតអំពី ទម្រង់ច្បាប់របស់ប្រាក់ចំណេញឡើយ។ ឧទាហរណ៍ ក្រុមហ៊ុនវិនិយោគអាចកាន់កាប់សញ្ញាប័ណ្ណ ដែលមានការប្រាក់ថេរ។ ការប្រាក់ថេរគឺប្រាក់ចំណេញអថេរសម្រាប់គោលបំណងនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ពីព្រោះវាជាកម្មវត្ថុនៃហានិភ័យ ដោយការមិនសង ហើយពួកវាធ្វើឱ្យក្រុមហ៊ុនវិនិយោគត្រូវប្រឈមនឹងហានិភ័យឥណទានរបស់ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណ័។ បរិមាណនៃភាពងាយប្រែប្រួល (មានន័យថា ប្រាក់ចំណេញអថេរទាំងនោះ) អាស្រ័យលើហានិភ័យឥណទានរបស់សញ្ញាបណ្ណ័។ ស្រដៀងគ្នានេះ កម្រៃថេរ ដែលបានពីការគ្រប់គ្រងទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ គឺជាប្រាក់ចំណេញអថេរ ពីព្រោះវានឹងធ្វើឱ្យក្រុមហ៊ុនវិនិយោគ ត្រូវប្រឈមនឹងហានិភ័យអាជីវកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ។ បរិមាណនៃភាពងាយប្រែប្រួលអាស្រ័យលើលទ្ធភាពរបស់ក្រុមហ៊ុនរងការវិនិយោគបង្កើតបានប្រាក់ចំណេញគ្រប់គ្រាន់សម្រាប់បង់ប្រាក់កម្រៃ។

ខ៥៧ ឧទាហរណ៍អំពីប្រាក់ចំណេញរួមមាន៖

(ក) ភាគលាភ ការបែងចែកផលប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីក្រុមហ៊ុនរងការវិនិយោគ (ឧ.ការប្រាក់បានពីមូលបត្របំណុលដែលបានបោះផ្សាយដោយក្រុមហ៊ុនរងការវិនិយោគ) និងបម្រែបម្រួលតម្លៃវិនិយោគរបស់ក្រុមហ៊ុនវិនិយោគ នៅក្នុងក្រុមហ៊ុនរងការវិនិយោគ។

(ខ) តម្លៃតបសង នៃសេវាកម្មទ្រព្យសកម្ម ឬបំណុលរបស់ក្រុមហ៊ុនរងការវិនិយោគ, ប្រាក់កម្រៃនិងការខាតបង់ដោយការគាំទ្រផ្នែកឥណទាន ឬសន្ទនីយភាព, ភាគកម្មសំណល់នៅក្នុងទ្រព្យសកម្មនិងបំណុលរបស់ក្រុមហ៊ុនរងការវិនិយោគ នៅពេលធ្វើការជម្រះបញ្ជីក្រុមហ៊ុនរងការវិនិយោគ, ចំណេញពីការបង់ពន្ធ, និងការទទួលបានសន្ទនីយភាពនាពេលអនាគត ដែលក្រុមហ៊ុនរងការវិនិយោគ មានដោយការពាក់ពន្ធ័ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ។

(គ) ប្រាក់ចំណេញ ដែលមិនសម្រាប់បែងចែកឱ្យអ្នកកាន់កាប់ភាគកម្មផ្សេងទៀត។ ឧទាហរណ៍ ក្រុមហ៊ុនវិនិយោគ អាចប្រើទ្រព្យសកម្មរបស់ខ្លួនរួមជាមួយនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគ ដូចជា ការរួមផ្សំមុខងារប្រតិបត្តិការណ៍ជាមួយគ្នា ដើម្បីសម្រេចបានសេដ្ឋកិច្ចអាស្រ័យទំហំ, ការសន្សំចំណាយ, ប្រភពនៃផលិតផលក្រខ្សត់, ទទួលបាននូវកម្មសិទ្ធិបញ្ញា ឬប្រតិបត្តិការមានដែនកំណត់ទ្រព្យសកម្មមានកម្រិតកំណត់ ដើម្បីធ្វើឱ្យប្រសើរឡើង នូវតម្លៃរបស់ទ្រព្យសកម្មផ្សេងទៀតរបស់ក្រុមហ៊ុនរងការវិនិយោគ។

## ចំណងទាក់ទងរវាងអំណាចនិងប្រាក់ចំណេញ

### អំណាចប្រគល់ឲ្យ

ខ៥៨ នៅពេលដែលក្រុមហ៊ុនវិនិយោគដែលមានសិទ្ធិធ្វើការសម្រេចចិត្ត (អ្នកធ្វើការសម្រេចចិត្ត) វាយតម្លៃថាតើខ្លួនធ្វើអភិបាលភាព លើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណា ក្រុមហ៊ុនត្រូវកំណត់ថាតើ ខ្លួនជាភារប្បទាយី ឬជាភ្នាក់ងារ។ ក្រុមហ៊ុនវិនិយោគ ត្រូវកំណត់ថាតើអង្គភាពផ្សេងទៀតដែលមានសិទ្ធិក្នុងការសម្រេចចិត្ត ធ្វើសកម្មភាពជាភ្នាក់ងារឲ្យក្រុមហ៊ុនវិនិយោគ ឬយ៉ាងណា។ ភ្នាក់ងារគឺជាភាគីមួយដែលជាប់ពាក់ពន្ធ័នឹងការធ្វើសកម្មភាពក្នុងនាម និងសម្រាប់ផលប្រយោជន៍របស់ភាគីមួយ ឬច្រើនផ្សេងទៀត (ភារប្បទាយីមួយឬច្រើន) និងហេតុដូច្នេះ មិនធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគឡើយនៅពេលដែលខ្លួនអនុវត្តន៍ អំណាចនៃការធ្វើការសម្រេចចិត្ត (មើលកថាខណ្ឌ១៧ និង កថាខណ្ឌ១៨)។ ដូច្នេះពេលខ្លះ អំណាចរបស់ភារប្បទាយីអាចត្រូវបានរក្សាទុកនិងអាចអនុវត្តន៍បានដោយភ្នាក់ងារ ប៉ុន្តែ ក្នុងនាមភារប្បទាយី។ អ្នកធ្វើការសម្រេចចិត្តមិនមែនជាភ្នាក់ងារទេ ពីព្រោះភាគី ផ្សេងទៀតអាចទទួលបានប្រយោជន៍ពីការសម្រេចចិត្តដែលបានធ្វើ។

ខ៥៩ ក្រុមហ៊ុនវិនិយោគអាចផ្តល់អំណាចនៃការសម្រេចចិត្តរបស់ខ្លួនទៅឲ្យភ្នាក់ងារលើបញ្ហាជាក់លាក់មួយចំនួន ឬលើសកម្មភាពពាក់ពន្ធ័ទាំងអស់។ នៅពេលវាយតម្លៃថាតើខ្លួនធ្វើអភិបាលភាពលើក្រុមហ៊ុនវិនិយោគឬយ៉ាងណាក្រុមហ៊ុនវិនិយោគត្រូវបរិយាយសិទ្ធិអំណាចនៃការសម្រេចចិត្តដែលបានប្រគល់ឲ្យទៅភ្នាក់ងាររបស់ខ្លួនដែលបានកាន់កាប់ដោយផ្ទាល់

ដោយក្រុមហ៊ុនវិនិយោគ។ នៅក្នុងស្ថានភាព ដែលមានភារប្បទាយី ច្រើនជាងមួយ ភារប្បទាយីនីមួយៗ ត្រូវវាយតម្លៃថាខ្លួនមានអំណាចលើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណាដោយត្រូវពិចារណានូវការតម្រូវនានានៅក្នុងកថាខណ្ឌ ខ៥-កថាខណ្ឌ ខ៥៤។ កថាខណ្ឌ ខ៦០-កថាខណ្ឌ ខ៧២ ផ្តល់នូវសេចក្តីណែនាំអំពីការកំណត់ថាតើអ្នកធ្វើការសម្រេចចិត្តជាភ្នាក់ងារឬជាភារប្បទាយី។

ខ៦០ អ្នកធ្វើការសម្រេចចិត្តត្រូវពិចារណានូវទំនាក់ទំនងរវាងខ្លួនឯងជាមួយនឹងក្រុមហ៊ុនវិនិយោគ និងបណ្តាភាគីផ្សេងទៀតដែលពាក់ពន្ធ័ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ ជាពិសេសត្រូវពិចារណារាល់កត្តាខាងក្រោមនៅក្នុងការកំណត់ថាតើខ្លួនជាភ្នាក់ងារឬយ៉ាងណា:

(ក) ក្របខណ្ឌនៃអំណាចធ្វើការសម្រេចចិត្តលើក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌ ខ៦២ និង ខ៦៣)។

(ខ) សិទ្ធិដែលកាន់កាប់ដោយបណ្តាភាគីផ្សេងទៀត (មើលកថាខណ្ឌ ខ៦៤-កថាខណ្ឌ ខ៦៧)។

(គ) តម្លៃតបសងដែលខ្លួនត្រូវបានទទួល ដោយយោងតាមបណ្តាកិច្ចព្រមព្រៀងតម្លៃតបសង (មើលកថាខណ្ឌខ៦៨ - កថាខណ្ឌ ខ៧០)។

(ឃ) ការប្រឈមរបស់អ្នកធ្វើការសម្រេចចិត្ត ចំពោះភាពងាយប្រែប្រួលប្រាក់ចំណេញដែលបានពីភាគកម្មផ្សេងៗដែលខ្លួនបានកាន់កាប់នៅក្នុងក្រុមហ៊ុនរងការវិនិយោគ (មើលកថាខណ្ឌ ខ៧១ និង ខ៧២)។

បរិមាណទំងន់ខុសគ្នាត្រូវតែបានអនុវត្តចំពោះកត្តានីមួយៗផ្អែកលើហេតុការណ៍និងកាលៈទេសៈជាក់ស្តែង។

២៦១ ការកំណត់ថាតើអ្នកធ្វើការសម្រេចចិត្តជាភ្នាក់ងារតម្រូវឱ្យមានការវាយតម្លៃគ្រប់កត្តាទាំងអស់ ដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ២៦០ ដរាបណាមានភាគីតែម្នាក់កាន់កាប់សិទ្ធិច្រើនលើសលែងដើម្បីដកចេញអ្នកធ្វើការសម្រេចចិត្ត (សិទ្ធិនៃការដកចេញ) និងអាចដកចេញអ្នកធ្វើការសម្រេចចិត្តដោយគ្មានមូលហេតុ (មើលកថាខណ្ឌ ២៦៥)។

*ក្រុបខណ្ឌនៃអំណាចធ្វើការសម្រេចចិត្ត*

២៦២ ក្របខណ្ឌនៃអំណាចធ្វើការសម្រេចចិត្តរបស់អ្នកធ្វើការសម្រេចចិត្តត្រូវបានវាយតម្លៃដោយពិចារណា:

(ក) សកម្មភាពដែលត្រូវបានអនុញ្ញាតិដោយយោងតាម កិច្ចព្រមព្រៀងនៃការសម្រេចចិត្ត និងត្រូវបានកំណត់ដោយច្បាប់និង

(ខ) ឆន្ទានុសិទ្ធរបស់អ្នកធ្វើការសម្រេចចិត្ត នៅពេលធ្វើការសម្រេចចិត្តអំពីសកម្មភាពទាំងនោះ។

២៦៣ អ្នកធ្វើការសម្រេចចិត្តត្រូវពិចារណា អំពីគោលបំណង និងការបង្កើតក្រុមហ៊ុនវិនិយោគ, ហានិភ័យរបស់ក្រុមហ៊ុនរងការវិនិយោគ, ហានិភ័យដែលត្រូវបានបង្កើតឡើងដើម្បីផ្ទេរទៅភាគីដែលពាក់ព័ន្ធ និងកម្រិតនៃការសម្រេចចិត្ត ដែលអ្នកធ្វើការសម្រេចចិត្ត នៅក្នុងការបង្កើតក្រុមហ៊ុនរងការវិនិយោគ។ ឧទាហរណ៍ ប្រសិនបើ អ្នកធ្វើការសម្រេចចិត្តមានការពាក់ពន្ធ័នៅក្នុងការបង្កើតក្រុមហ៊ុនរងការវិនិយោគ (រួមមានទាំងក្នុងការកំណត់ក្របខណ្ឌ នៃអំណាចធ្វើការសម្រេចចិត្ត) ដែលការ

ពាក់ព័ន្ធអាចបង្ហាញថា អ្នកធ្វើការសម្រេចចិត្តមានឱកាសនិងគ្រឿងលើកទឹកចិត្តដើម្បីទទួលបានសិទ្ធិ ដែលអាចធ្វើឲ្យអ្នកធ្វើការសម្រេចចិត្តមានលទ្ធភាពដឹកនាំសកម្មភាពពាក់ពន្ធ័។

*សិទ្ធិដែលកាន់កាប់ដោយភាគីផ្សេងទៀត*

ខ៦៤ សិទ្ធិលើសលែងដែលកាន់កាប់ដោយភាគីផ្សេងទៀតអាចមានឥទ្ធិពល លើលទ្ធភាពរបស់អ្នកធ្វើការសម្រេចចិត្ត ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័របស់ក្រុមហ៊ុនរងការវិនិយោគ។ សិទ្ធិលើសលែងសម្រាប់ការដកចេញ និងសិទ្ធិផ្សេងទៀតអាចបង្ហាញថា អ្នកធ្វើការសម្រេចចិត្តគឺជាភ្នាក់ងារ។

ខ៦៥ នៅពេលដែលភាគីតែម្នាក់កាន់កាប់សិទ្ធិលើសលែងនៃការដកចេញ ហើយអាចដកអ្នកធ្វើការសម្រេចចិត្តចេញដោយមិនចាំបាច់មានមូលហេតុ, ក្នុងករណីដាច់ដោយឡែក, នេះមានភាពគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា អ្នកធ្វើការសម្រេចចិត្តគឺជាភ្នាក់ងារ។ ប្រសិនបើ មានភាគីច្រើនកាន់កាប់សិទ្ធិបែបនោះ (មិនមានភាគីណាម្នាក់អាចដកអ្នកធ្វើការសម្រេចចិត្ត ដោយមិនមានការព្រមព្រៀងពីភាគីផ្សេងទៀត) សិទ្ធិទាំងនោះមិន,ជាករណីដាច់ដោយឡែក, ប្រាកដជាកំណត់បានថា អ្នកធ្វើការសម្រេចចិត្តធ្វើសកម្មភាពជាចំបងក្នុងនាម និងក្នុងប្រយោជន៍របស់អ្នកផ្សេងទៀតបានឡើយ។ ជាការបន្ថែម ការតម្រូវឲ្យមានភាគីកាន់តែច្រើនរួមគ្នាធ្វើការសម្រេចចិត្តដើម្បីអនុវត្តន៍សិទ្ធិនៃការដកអ្នកធ្វើការសម្រេចចិត្តចេញ និងទំហំកាន់តែធំនិងភាពងាយប្រែប្រួលជាមួយនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកធ្វើការសម្រេចចិត្ត (កម្រៃតបសង និងអត្ថប្រយោជន៍ផ្សេងៗ)

ទៀត) នឹងធ្វើឲ្យកាន់តែមានទំងន់កាន់តែតិច ដែលនឹងត្រូវដាក់លើកត្តានេះ។

២៦៦ សិទ្ធិលើសលុបដែលកាន់កាប់ដោយភាគីផ្សេងទៀតដែលដាក់កំហិត នៃការសម្រេចចិត្តរបស់អ្នកធ្វើការសម្រេចចិត្ត ត្រូវតែបានពិចារណា តាមរបៀបស្រដៀងគ្នាទៅនឹងសិទ្ធិនៃការដកចេញនៅពេលធ្វើការវាយតម្លៃថា តើអ្នកធ្វើ ការសម្រេចចិត្តគឺជាភ្នាក់ងារឬយ៉ាងណា។ ឧទាហរណ៍ អ្នកធ្វើការសម្រេចចិត្ត ដែលតម្រូវឲ្យមានការអនុម័តយល់ព្រមពីភាគីមួយចំនួនតូចសម្រាប់ការធ្វើសកម្មភាពរបស់ខ្លួន ជាទូទៅគឺជាភ្នាក់ងារ។ (មើលកថាខណ្ឌ ខ២២-ខ២៥ សម្រាប់ជាសេចក្តីណែនាំបន្ថែម អំពីសិទ្ធិ និងអំពីថាតើ វាជាសិទ្ធិលើសលែងឬយ៉ាងណា)។

២៦៧ ការពិចារណាអំពីសិទ្ធិដែលកាន់កាប់ដោយភាគីផ្សេងៗត្រូវរាប់បញ្ចូល នូវការវាយតម្លៃនូវសិទ្ធិណាមួយដែលអាច អនុវត្តន៍បានដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនរងការវិនិយោគ (ឬ គណៈអភិបាលផ្សេងទៀត) និងផលប៉ះពាល់របស់វាលើអំណាចនៃការសម្រេចចិត្ត (មើលកថាខណ្ឌ ខ២៣(ខ))។

*លាភការ*

២៦៨ ទំហំកាន់តែធំនិងភាពងាយប្រែប្រួលជាមួយនឹងលាភការរបស់អ្នកធ្វើការសម្រេចចិត្តទាក់ទងនឹងប្រាក់ចំណេញ ដែលរំពឹងបានពីសកម្មភាពរបស់ក្រុមហ៊ុនរងការវិនិយោគ វាកាន់តែបញ្ជាក់ថា អ្នកធ្វើការសម្រេចចិត្តគឺជាភារប្បទាយី។

២៦៩ នៅក្នុងការកំណត់ថាតើខ្លួនជាភារប្បទាយីឬជាភ្នាក់ងារ អ្នកធ្វើការសម្រេចចិត្ត ត្រូវពិចារណាផងដែរថាតើលក្ខខណ្ឌខាងក្រោមកើតឡើងឬយ៉ាងណាៈ

(ក) លាភការរបស់អ្នកធ្វើការសម្រេចចិត្តប្រដំប្រសងនឹងសេវាកម្ម ដែលបានផ្តល់ឲ្យ។

(ខ) កិច្ចព្រមព្រៀងលាភការរួមបញ្ចូលតែលក្ខខណ្ឌ ការដាក់កម្រិត ឬបរិមាណដែលបង្ហាញនៅក្នុងកិច្ចព្រមព្រៀង សម្រាប់សេវាកម្មនិងកម្រិតជំនាញដែលស្រដៀងគ្នាដែលបានចរចារដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា។

២៧០ អ្នកធ្វើការសម្រេចចិត្តមិនអាចជាភ្នាក់ងារបានទេ ដរាបណា លក្ខខណ្ឌនានាដែលបានកំណត់នៅក្នុងកថាខណ្ឌ ២៦៩(ក) និង (ខ) ត្រូវបានបង្ហាញ។ ទោះជាយ៉ាងណា ការបំពេញលក្ខខណ្ឌទាំងនោះតែឯកឯង មិនគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា អ្នកធ្វើការសម្រេចចិត្តគឺជាភ្នាក់ងារឡើយ។

*ការប្រឈមនឹងភាពងាយប្រែប្រួលនៃប្រាក់ចំណេញពីភាគកម្មផ្សេងៗ*

២៧១ អ្នកធ្វើការសម្រេចចិត្ត ដែលកាន់កាប់ភាគកម្មផ្សេងទៀតនៅក្នុងក្រុមហ៊ុនរងការវិនិយោគ (ឧ.ការវិនិយោគនៅក្នុង ក្រុមហ៊ុនរងការវិនិយោគ ឬផ្តល់ការធានាដោយយោងតាមលទ្ធផលរបស់ក្រុមហ៊ុនរងកាវិនិយោគ)ត្រូវពិចារណា ការប្រឈមរបស់ខ្លួនទៅនឹងភាពប្រែប្រួលនៃប្រាក់ចំណេញពីភាគកម្មផ្សេងៗ នៅក្នុងការវាយតម្លៃថាតើខ្លួនជា ភ្នាក់ងារឬយ៉ាងណា។ ការកាន់កាប់ភាគកម្មផ្សេងទៀតនៅក្នុងក្រុមហ៊ុនរងការវិនិយោគបង្ហាញថា អ្នកធ្វើការសម្រេចចិត្តអាចជាភារប្បទាយី។

២៧២ ក្នុងការវាយតម្លៃការប្រឈមរបស់ខ្លួន ទៅនឹងភាពប្រែប្រួល នៃប្រាក់ចំណេញពីភាគកម្មផ្សេងៗ នៅក្នុងក្រុមហ៊ុនរងការវិនិយោគ អ្នកធ្វើការសម្រេចចិត្តត្រូវពិចារណាខាងក្រោម៖

(ក) ទំហំកាន់តែធំនិងភាពប្រែប្រួលពាក់ពន្ធ័នឹងអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួន, ពិចារណាអំពីលាភការនិង ភាគកម្មផ្សេងៗជាសរុបរួមវាកាន់តែបញ្ជាក់ថា អ្នកធ្វើការសម្រេចចិត្តគឺជាភារប្បទាយី។

(ខ) ថាតើការប្រឈមនឹងភាពប្រែប្រួលនៃប្រាក់ចំណេញមានភាពខុសគ្នាពីអ្វីដែលវិនិយោគិនផ្សេងទៀតបានទទួល ប្រសិនបើមាន, ថាតើទាំងនេះមានឥទ្ធិពលលើសកម្មភាពរបស់ខ្លួនឬយ៉ាងណា។ឧទាហរណ៍នេះអាចជាករណី នៅពេលដែលអ្នកធ្វើការសម្រេចចិត្តកាន់កាប់ភាគកម្មថ្នាក់ទាប ឬផ្តល់ជាទម្រង់ឥណទានផ្សេងទៀត នៅក្នុងក្រុមហ៊ុនរងការវិនិយោគ។

អ្នកធ្វើការសម្រេចចិត្តត្រូវវាយតម្លៃការប្រឈមរបស់ខ្លួនទាក់ទងនឹងភាពប្រែប្រួលសរុបនៃប្រាក់ចំណេញរបស់ ក្រុមហ៊ុនរងការវិនិយោគ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយផ្អែកលើប្រាក់ចំណេញ ដែលបានមកពីសកម្មភាពរបស់ក្រុមហ៊ុនរងការវិនិយោគ ប៉ុន្តែមិនបោះបង់ចោលការប្រឈមជាអតិបរមារបសអ្នកធ្វើការសម្រេចចិត្តទៅនឹងភាពប្រែប្រួល នៃប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគតាមរយៈភាគកម្មផ្សេងៗដែលអ្នកធ្វើការសម្រេចចិត្តបានកាន់កាប់។

| ឧទាហរណ៍ |
|---|
| **ឧទាហរណ៍១៣**<br>អ្នកធ្វើការសម្រេចចិត្ត (អ្នកគ្រ់គ្រងមូលនិធិ) បង្កើតទីផ្សារនិងគ្រប់គ្រងមូលនិធិដាក់កម្រិតដែលសម្រាប់ផ្ទួញផ្ទូរជា សាធារណៈដោយយោងតាម ប៉ារ៉ាម៉ែត្រ ដែលបានកំណត់យ៉ាងចង្អៀត ដែលបានបង្កើតឡើងនៅក្នុងអាណត្តិនៃការវិនិយោគដូចដែលបានតម្រូវដោយច្បាប់និងនិយ័តកម្មនៅក្នុងប្រទេស។ មូលនិធិ ត្រូវបានលក់ទៅឱ្យបណ្ដា វិនិយោគិនថាជាការវិនិយោគនៅក្នុងផលបត្រកម្មសិទ្ធិ ដែលមានលក្ខណៈនានាភាពរបស់អង្គភាពដែលមូលបត្រដាក់ផ្ទួញផ្ទូរជាសាធារណៈ។ នៅក្នុងប៉ារ៉ាម៉ែត្រដែលបានកំណត់, អ្នកគ្រប់គ្រងមូលនិធិមានឆន្ទានុសិទ្ធិអំពីទ្រព្យសកម្មដែលត្រូវវនិយោគ។អ្នកគ្រប់គ្រងមូលនិធិបានធ្វើការវិនិយោគជាសមាមាត្រ ១០ភាគរយ នៅក្នុងមូលនិធិ និងទទួលបានប្រាក់កម្រៃតាមអត្រាទីផ្សារ សម្រាប់សេវាកម្មរបស់ខ្លួនស្មើ ១ភាគរយ នៃតម្លៃទ្រព្យសកម្មសុទ្ធរបស់មូលនិធិ។ កម្រៃមានតម្លៃប្រដំប្រសងជាមួយនឹងសេវាកម្មដែលបានផ្ដល់ឱ្យ។អ្នកគ្រប់គ្រងមូលនិធិមិនមានកាតព្វ កិច្ចណាមួយចំពោះការខាតបង់មូលនិធិ ដែលមានចំនួនលើស ១០ភាគរយ នៃការវិនិយោគឡើយ។មូលនិធមិនត្រូវបានតម្រូវឱ្យបង្កើត និងបានបង្កើតនូវក្រុមប្រឹក្សាភិបាលឡើយ។បណ្ដាវិនិយោគិនមិនកាន់កាប់សិទ្ធិលើសលែងដែលនឹងមានផលប៉ះពាល់ ដល់អំណាច នៃការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងមូលនិធិទេ ប៉ុន្តែអាចបន្ថយភាគកម្មរបស់ពួកគេនៅក្នុងព្រំដែនកំណត់ជាក់លាក់មួយ ដែលកំណត់ដោយមូលនិធិនោះ។ |

ទោះបីជាធ្វើប្រតិបត្តិការនៅក្នុង ប៉ារ៉ាម៉ែត្រ ដែលបានកំណត់នៅក្នុង អាណត្តិនៃការវិនិយោគ និងដោយអនុលោម តាមការតម្រូវរបស់ច្បាប់ក៏ដោយ អ្នកគ្រប់គ្រងមូលនិធិមានសិទ្ធិធ្វើការសម្រេចចិត្ត ដែលផ្តល់ឱ្យខ្លួននូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ព័ន្ធរបស់មូលនិធិ--បណ្តាវិនិយោគិនមិនកាន់កាប់សិទ្ធិលើសលែង ដែលអាចមានផលប៉ះពាល់ដល់អំណាច នៃការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងមូលនិធិឡើយ។ អ្នកគ្រប់គ្រងមូលនិធិទទួលបានកម្រៃសេវា តាមអត្រាទីផ្សារ ដែលមានលក្ខណៈប្រដំប្រសងគ្នានឹងសេវាកម្ម ដែលបានផ្តល់ និងបានធ្វើការវិនិយោគតាមសមាមាត្រនៃមូលនិធិនោះ។ លាភការ និងការវិនិយោគធ្វើឱ្យអ្នកគ្រប់គ្រងមូលនិធិត្រូវប្រឈមនឹងភាពប្រែប្រួលនៃប្រាក់ចំណេញ ដែលបានពីសកម្មភាពរបស់មូលនិធិ ដោយមិនចាំបាច់បង្កើតនូវការប្រឈម ដែលមានភាពជាដុំកំភួនដែលវាមានបង្ហាញថា អ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។

នៅក្នុងឧទាហរណ៍នេះ ការពិចារណាអំពីការប្រឈមរបស់អ្នកគ្រប់គ្រងទៅនឹងភាពប្រែប្រួលនៃប្រាក់ចំណេញពីមូលនិធិរួមជាមួយនឹងអំណាចនៃការសម្រេចចិត្តរបស់ខ្លួននៅក្នុងក្របខណ្ឌនៃប៉ារ៉ាម៉ែត្រដែលមានដាក់កំហិត បង្ហាញថាអ្នកគ្រប់គ្រងមូលនិធិគឺជាភ្នាក់ងារ។ដូច្នេះ អ្នកគ្រប់គ្រងមូលនិធិសន្និដ្ឋានថាខ្លួនមិនមានអភិបាលភាពលើមូលនិធិឡើយ។

**ឧទាហរណ៍ ១៤**

អ្នកធ្វើការសម្រេចចិត្តបង្កើតលក់ និងគ្រប់គ្រងមូលនិធិ ដែលផ្ដល់នូវឱកាសវិនិយោគទៅឲ្យវិនិយោគិនជាច្រើន។ អ្នកធ្វើការសម្រេចចិត្ត (អ្នកគ្រប់គ្រងមូលនិធិ) ត្រូវធ្វើការសម្រេចចិត្តសម្រាប់ផលប្រយោជន៍របស់គ្រប់វិនិយោគិនទាំងអស់ និងតាមកិច្ចព្រមព្រៀងនៃការគ្រប់គ្រងរបស់មូលនិធិ។ យ៉ាងណាក៏ដោយ អ្នកគ្រប់គ្រងមូលនិធិមានឆន្ទានុសិទ្ធិទូលំទូលាយរបស់ខ្លួន។ អ្នកគ្រប់គ្រងមូលនិធិទទួលបានប្រាក់កម្រៃតាមអត្រាទីផ្សារសម្រាប់សេវាកម្មរបស់ខ្លួនដែលស្មើនឹង ១ភាគរយ នៃទ្រព្យសកម្មដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ខ្លួន និង ២០ភាគរយ នៃប្រាក់ចំណេញសរុបរបស់មូលនិធិ ប្រសិនបើ ខ្លួនសម្រេចបានកម្រិតប្រាក់ក្នុងកម្រិតកំណត់មួយ។ ប្រាក់កម្រៃមានកម្រិតប្រហាក់ប្រហែលនឹងសេវាកម្មដែលបានផ្ដល់។

ទោះបីវាត្រូវធ្វើកាសម្រេចចិត្តនៅក្នុងផលប្រយោជន៍របស់វិនិយោគិនទាំងអស់ក៏ដោយ អ្នកគ្រប់គ្រងមូលនិធិមាន សិទ្ធិអំណាចនៃការសម្រេចចិត្តយ៉ាងទូលំទូលាយដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័របស់មូលនិធិ។ អ្នកគ្រប់គ្រងមូលនិធិត្រូវបានទទួលនូវប្រាក់កម្រៃថេនិងប្រាក់កម្រៃទាក់ទងនឹងលទ្ធផលដែលមានលក្ខណៈប្រហាក់ប្រហែលនឹង សេវាកម្មបានផ្ដល់។ ជាការបន្ថែម លាភការត្រូវធ្វើឲ្យស៊ីគ្នា រវាងអត្ថប្រយោជន៍របស់អ្នកគ្រប់គ្រងមូលនិធិ ជាមួយនឹងអត្ថប្រយោជន៍របស់អ្នកវិនិយោគផ្សេងទៀតដើម្បីបង្កើនតម្លៃរបស់មូលនិធិ ដោយមិនបង្កើតឲ្យមានការប្រឈមទៅនឹងភាពប្រែប្រួលនៃប្រាក់ចំណេញដែលបានពីសកម្មភាពរបស់មូលនិធិដែលមានសារៈសំខាន់ចំពោះ លាភការនោះ នៅពេលមានការពិចារណាដាច់ដោយឡែក បង្ហាញថាអ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។

គម្រូនៃហេតុការណ៍និងការវិភាគខាងលើអនុវត្តចំពោះឧទាហរណ៍១៤ក-១៤គ ខាងក្រោម។ ឧទាហរណ៍និមួយៗ មិនទាក់ទងគ្នាទេ។

**ឧទារហរណ៍ ១៤ ក**

អ្នកគ្រប់គ្រងមូលនិធិមាន២ភាគរយនៃការវិនិយោគនៅក្នុងមូលនិធិដែលស្របគ្នានឹងអត្ថប្រយោជន៍របស់វិនិយោគិនផ្សេងៗទៀត។ អ្នកគ្រប់គ្រងមិនមានកាតព្វកិច្ចចំពោះការខាតបង់របស់មូលនិធិដែលលើស ២ភាគរយ នៃការវិនិយោគរបស់ខ្លួនឡើយ។ បណ្តាវិនិយោគិនអាចដកអ្នកគ្រប់គ្រងមូលនិធិ ដោយសម្លេងគាំទ្រភាគច្រើន ប៉ុន្តែ សម្រាប់តែករណីដែលមិនគោរពតាមកិច្ចសន្យាប៉ុណ្ណោះ។

ការិនិយោគ ២ភាគរយ របស់អ្នកគ្រប់គ្រងមូលនិធិបង្កើនការប្រឈមរបស់ខ្លួនជាមួយនឹងភាពប្រែប្រួល នៃប្រាក់ចំណេញពីសកម្មភាពរបស់មូលនិធិ ដោយមិនមានការបង្កើតការប្រឈមដែលមានសារៈសំខាន់សម្រាប់បង្ហាញថា អ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។សិទ្ធិរបស់វិនិយោគិនផ្សេងទៀតដើម្បីដកចេញអ្នកគ្រប់គ្រងមូលនិធិ ត្រូវបានពិចារណាថាជាសិទ្ធិដែលមានការការពារពីព្រោះសិទ្ធិទាំងនោះអាចប្រើបានតែក្នុងករណីដែលមានការមិនគោរពកិច្ចសន្យាប៉ុណ្ណោះ។ ក្នុងឧទាហរណ៍នេះ បើទោះបីជាអ្នកគ្រប់គ្រងមូលនិធិមានសិទ្ធិអំណាច នៃការសម្រេច ចិត្តយ៉ាងទូលំទូលាយ និងត្រូវប្រឈមជាមួយនឹងភាពប្រែប្រួល នៃប្រាក់ចំណេញពីភាគកម្មនិងលាភការរបស់ខ្លួន ក៏ការប្រឈមរបស់អ្នកគ្រប់គ្រងមូលនិធិបង្ហាញថា អ្នកគ្រប់គ្រងមូលនិធិគឺជាភ្នាក់ងារ។ដូច្នេះ អ្នគ្រប់គ្រងមូលនិធិសន្និដ្ឋាន

ថា ខ្លួនមិនមានអភិបាលភាពលើមូលនិធិឡើយ។

## ឧទាហរណ៍ ១៤ខ

អ្នកគ្រប់គ្រងមូលនិធិមានការវិនិយោគតាមសមាមាត្រភាគច្រើននៅក្នុងមូលនិធិ ប៉ុន្តែ មិនមានកាតព្វកិច្ចធ្វើហិរញ្ញប្បទាន ចំពោះការខាតបង់លើសពីបរិមាណវិនិយោគរបស់ខ្លួនឡើយ។ បណ្តាវិនិយោគិន អាចដកអ្នកគ្រប់គ្រងមូលនិធិចេញបានដោយមានសម្លេងគាំទ្រភាគច្រើន ប៉ុន្តែសម្រាប់តែករណីនៃការមិនគោរពតាមកិច្ចសន្យាប៉ុណ្ណោះ។

នៅក្នុងឧទាហរណ៍នេះ សិទ្ធិរបស់វិនិយោគិនផ្សេងទៀតដើម្បីដកចេញអ្នកគ្រប់គ្រងមូលនិធិត្រូវបានពិចារណា ថាជាសិទ្ធិដែលមានការការពារ ពីព្រោះសិទ្ធិទាំងនោះ អាចប្រើបានតែក្នុងករណី ដែលមានការមិនគោរពតាមកិច្ចសន្យាប៉ុណ្ណោះ។ ទោះជាយ៉ាងណា អ្នកគ្រប់គ្រងមូលនិធិត្រូវបានទទួលនូវប្រាក់កម្រៃថេរ និងប្រាក់កម្រៃទាក់ទងនឹង លទ្ធផលដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មបានផ្តល់, ការរួមផ្សំការវិនិយោគរបស់អ្នកគ្រប់គ្រងមូលនិធិជាមួយនឹងលាភការរបស់ខ្លួនអាចបង្កើតការប្រឈមទៅនឹងភាពប្រែប្រួលនៃប្រាក់ចំណេញដែលបានពីសកម្មភាពរបស់មូលនិធិ ដែលមានសារៈសំខាន់ ដើម្បីបង្ហាញថាអ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។ ទំហំកាន់តែធំនិងភាពប្រែប្រួលកាន់តែខ្លាំងពាក់ពន្ធ័ ជាមួយនឹងអត្ថប្រយោជន៍សេដ្ឋកិច្ច របស់អ្នកគ្រប់គ្រងមូលនិធិ (ពិចារណាអំពីលាភការនិងអត្ថប្រយោជន៍ផ្សេងៗជារួម), កាន់តែធ្វើឲ្យអ្នកគ្រប់គ្រងមូលនិធិកាន់តែផ្តោតលើអត្ថប្រយោជន៍សេដ្ឋកិច្ចនៅក្នុងការវិភាគ និងកាន់តែ

បង្ហាញថាអ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។

ជាឧទាហរណ៍ដោយបានពិចារណាអំពីលាភការរបស់ខ្លួននិងកត្តាផ្សេងៗទៀតអ្នកគ្រប់គ្រងមូលនិធិអាចពិចារណាថាការវិនិយោគ ២០ភាគរយ មានភាពគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថាខ្លួនមានអភិបាលភាពលើមូលនិធិ។ ទោះជាយ៉ាងណានៅក្នុងកាលៈទេសៈផ្សេងៗគ្នា (មានន័យថាប្រសិនបើលាភការឬកត្តាផ្សេងទៀតមានភាពខុសគ្នា) អភិបាលភាពអាចកើតឡើងនៅពេលដែលកម្រិត នៃការវិនិយោគខុសគ្នា។

**ឧទាហរណ៍ ១៤ គ**

អ្នកគ្រប់គ្រងមូលនិធិមានសមាមាត្រវិនិយោគ២០ភាគរយនៅក្នុងមូលនិធិ ប៉ុន្តែមិនមានកាតព្វកិច្ចណាមួយចំពោះមូលនិធិសម្រាប់ការខាតបង់ ដែលលើសពី ២០ភាគរយ នៃការវិនិយោគឡើយ។ មូលនិធិមានក្រុមប្រឹក្សាភិបាល ដែលសមាជិកទាំងអស់របស់ក្រុមប្រឹក្សាភិបាលមានភាពឯករាជ្យពីអ្នកគ្រប់គ្រងមូលនិធិដែលត្រូវបានតែងតាំងដោយវិនិយោគិនផ្សេងទៀត។ ក្រុមប្រឹក្សាភិបាលតែងតាំងអ្នកគ្រប់គ្រងមូលនិធិជារៀងរាល់ឆ្នាំ ។ ប្រសិនបើ ក្រុមប្រឹក្សាសម្រេចមិនបន្តកិច្ចសន្យាជាមួយនឹងអ្នគ្រប់គ្រងមូលនិធិ សេវាកម្ម ដែលបានផ្តល់ឲ្យដោយអ្នកគ្រប់គ្រងមូលនិធិនឹងត្រូវបានផ្តល់ឲ្យដោយអ្នគ្រប់គ្រងផ្សេងទៀត នៅក្នុងឧស្សាហកម្មនេះ។

ទោះបីយ៉ាងណា អ្នកគ្រប់គ្រងមូលនិធិបានទទួលប្រាក់កម្រៃថេរ និងពាក់ពន្ធ័នឹងលទ្ធផល ដែលមានលក្ខណៈប្រហាក់ប្រហែលនឹង សេវាកម្មដែលបានផ្តល់ឲ្យ, ការគួបផ្សំនូវការវិនិយោគ២០ភាគរយរបស់អ្នកគ្រប់គ្រងមូលនិធិ ជាមួយនឹងលាភការរបស់ខ្លួនបង្កើតបាននូវការប្រឈមចំពោះភាពប្រែប្រួលនៃប្រាក់ចំណេញពីសកម្មភាពរបស់មូលនិធិ ដែលមានសារៈសំខាន់ដែលបង្ហាញថា អ្នកគ្រប់គ្រងមូលនិធិគឺជាភារប្បទាយី។ ទោះជាយ៉ាងណាក្តី វិនិយោគិនមានសិទ្ធិលើសលែងដើម្បីដកចេញនូវអ្នកគ្រប់គ្រងមូលនិធិ--ក្រុមប្រឹក្សាភិបាលផ្តល់ជាយន្តការដើម្បីធានាថា វិនិយោគិនអាចដកអ្នកគ្រប់គ្រងមូលនិធិ ចេញបានប្រសិនបើពួកគេចង់ធ្វើដូច្នោះ។

នៅក្នុងឧទាហរណ៍នេះ អ្នកគ្រប់គ្រងមូលនិធិផ្តោតធ្ងន់ទៅលើសិទ្ធិនៃការដកចេញពីតំណែងនៅក្នុងការវិភាគនេះ។ ដូច្នេះទោះបីជាអ្នកគ្រប់គ្រងមូលនិធិ មានសិទ្ធិអំណាចនៃការសម្រេចចិត្តយ៉ាងធំទូលាយ និងត្រូវប្រឈមជាមួយនឹងភាពប្រែប្រួលនៃប្រាក់ចំណេញរបស់មូលនិធិពីលាភការនិងការវិនិយោគរបស់ខ្លួនយ៉ាងណាក្តី សិទ្ធិលើសលែង ដែលបានកាន់កាប់ដោយវិនិយោគិនផ្សេងទៀត បង្ហាញថាអ្នកគ្រប់គ្រងមូលនិធិគឺជាភ្នាក់ងារ។ ដូច្នេះអ្នកគ្រប់គ្រងមូលនិធិសន្និដ្ឋានថាខ្លួនមិនមានអភិបាលភាពលើមូលនិធិឡើយ។

## ឧទាហរណ៍ ១៥

ក្រុមហ៊ុនរងការវិនិយោគត្រូវបានបង្កើតឡើងដើម្បីទិញក្រុមនៃមូលបត្រដែលមានទ្រព្យសកម្មដាក់បញ្ចាំ ត្រូវបានផ្តល់មូលនិធិ ដោយឧបករណ៍ហិរញ្ញវត្ថុបំណុលដែលមានអត្រាការប្រាក់ថេរនិងឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិ។ ឧបករណ៍ហិរញ្ញវត្ថុ

កម្មសិទ្ធិត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការការពារការខាតបង់លើកដំបូងចំពោះ វិនិយោគិន បំណុល និងទទួលបានផលចំណេញ នៅសល់របស់ក្រុមហ៊ុនរងការវិនិយោគ។ប្រតិបត្តិការត្រូវបានលក់ទៅឲ្យវិនិយោគិន បំណុល សក្តានុពលថាជាការវិនិយោគ នៅក្នុងក្រុមនៃមូលបត្រដែលមានទ្រព្យសកម្មដាក់បញ្ចាំ ជាមួយនឹងការប្រឈមទៅនឹងហានិភ័យឥណទានដែលពាក់ពន្ធ័នឹងការបោកប្រាស់ មិនសងដែលអាចកើតឡើងរបស់អ្នកបោះផ្សាយមូលបត្រ ដែលមានទ្រព្យសកម្មដាក់បញ្ចាំនៅក្នុងក្រុមមូលបត្រនោះ និងប្រឈមនឹងហានិភ័យអត្រាការប្រាក់ដែលពាក់ពន្ធ័នឹងការគ្រប់គ្រងក្រុមនៃមូលបត្រ។ នៅក្នុងការបង្កើត ឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិមាន ១០ភាគរយ នៃតម្លៃទ្រព្យសកម្ម ដែលបានទិញ។ អ្នកធ្វើការសម្រេចចិត្ត (អ្នកគ្រប់គ្រងទ្រព្យសកម្ម) គ្រប់គ្រងក្រុមនៃទ្រព្យសកម្ម ដែលសកម្ម ដោយការធ្វើការសម្រេចចិត្តវិនិយោគនៅក្នុង ប៉ារ៉ាម៉ែត្រ ដែលបានកំណត់នៅក្នុងទស្សនវិស័យរបស់ក្រុមហ៊ុនរងការវិនិយោគ។ សម្រាប់សេវាកម្មទាំងនោះអ្នកគ្រប់គ្រងទ្រព្យសកម្ម ទទួលបានប្រាក់កម្រៃថេរ តាមអត្រាទីផ្សារ (មានន័យថា ១ភាគរយ នៃទ្រព្យសកម្មស្ថិតក្រោមការគ្រប់គ្រង) និងប្រាក់កម្រៃផ្អែកលើលទ្ធផល (មានន័យថា ១០ភាគរយ នៃប្រាក់ចំណេញ) ប្រសិនបើប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគបានលើសពីកម្រិតដែលបានកំណត់។ ប្រាក់កម្រៃមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មបានផ្តល់ឲ្យ។ អ្នកគ្រប់គ្រងទ្រព្យសកម្មកាន់កាប់៣ ៥ភាគរយ នៃកម្មសិទ្ធិរបស់ក្រុមហ៊ុនរងការវិនិយោគ។ ចំណែកដែលនៅសល់ ៦៥ភាគរយ នៃកម្មសិទ្ធិ និងឧបករណ៍ហិរញ្ញវត្ថុបំណុលទាំងអស់ត្រូវបានកាន់កាប់ដោយវិនិយោគិនផ្សេងៗទៀត ដែលជាភាគីទីបី ដែល

មិនមានការពាក់ពន្ធ័។ អ្នកគ្រប់គ្រងទ្រព្យសកម្មអាចត្រូវបានដកចេញ ដោយមិនចាំបាច់មានមូលហេតុ ដោយការសម្រេចចិត្តដែលមានសម្លេងភាគច្រើនរបស់វិនិយោគិនផ្សេងទៀត។

អ្នកគ្រប់គ្រងទ្រព្យសកម្មបានទទួលប្រាក់កម្រៃថេរនិងពាក់ពន្ធ័នឹងលទ្ធផលដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មដែលបានផ្តល់ឲ្យ។ លាភការសម្រប ជាមួយនឹងភាគកម្មរបស់អ្នកគ្រប់គ្រងមូលនិធិជាមួយនឹងភាគកម្មរបស់វិនិយោគិនផ្សេងទៀតដើម្បីបង្កើតនូវតម្លៃរបស់មូលនិធិ។ អ្នកគ្រប់គ្រងទ្រព្យសកម្មមានការប្រឈមនឹងទៅនឹង ភាពប្រែប្រួលប្រាក់ចំណេញ ដែលបានពីសកម្មភាពរបស់មូលនិធិ ពីព្រោះខ្លួនបានកាន់កាប់៣៥ភាគរយនៃកម្មសិទ្ធិ និងពីលាភការរបស់ខ្លួន។

ទោះជាយ៉ាងណាក្តី ការធ្វើប្រតិបត្តិការនៅក្នុងវង្វង់នៃប៉ារ៉ាម៉ែត្រដែលបានកំណត់នៅក្នុងទស្សនទានរបស់ក្រុមហ៊ុនរងការវិនិយោគ, អ្នកគ្រប់គ្រងទ្រព្យសកម្ម មានលទ្ធភាពបច្ចុប្បន្ន ដើម្បីធ្វើការសម្រេចចិត្តវិនិយោគ ដែលមានផលប៉ះពាល់ជាដុំកំភួនលើផលចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ - សិទ្ធិនៃការដកចេញពីតំណែងដែលកាន់កាប់ ដោយវិនិយោគិនផ្សេងៗ ទទួលបានទំងន់តិចតួចនៅក្នុងការវិភាគពីព្រោះសិទ្ធិទាំងនោះ ត្រូវបានកាន់កាប់ដោយវិនិយោគិនផ្សេងៗគ្នាជាច្រើននាក់។ នៅក្នុងឧទាហរណ៍នេះ អ្នកគ្រប់គ្រងទ្រព្យសកម្មផ្តោតធ្ងន់ទៅលើការប្រឈមរបស់ខ្លួនទៅនឹងភាពប្រែប្រួលប្រាក់ចំណេញរបស់មូលនិធិ ពីភាគកម្មកម្មសិទ្ធិរបស់ខ្លួនដែលជាកម្រិតមួយទាបជាងឧបករណ៍បំណុល។ ការកាន់កាប់ ៣៥ភាគរយ នៃកម្មសិទ្ធិបង្កើតនូវការប្រឈមមានកម្រិតទៅនឹងការខាតបង់

និងសិទ្ធិចំពោះប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគដែលមានសារៈសំខាន់ ដែលនឹងបង្ហាញថា អ្នកគ្រប់គ្រងទ្រព្យសកម្មគឺជាភារប្បទាយី។ ដូច្នេះ អ្នកគ្រប់គ្រងទ្រព្យសកម្មសន្និដ្ឋានថាខ្លួនមានអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ។

**ឧទាហរណ៍ ១៦**

អ្នកធ្វើការសម្រេចចិត្ត (អ្នកធានា) ឧបត្ថម្ភអភិបាលនៃអ្នកផ្តត់ផ្គង់ចំរុះមួយ ដែលបោះផ្សាយឧបករណ៍បំណុលរយៈពេលខ្លី ទៅឲ្យវិនិយោគិន ដែលជាភាគីទីបីដែលមិនពាក់ពន្ធ័។ ប្រតិបត្តិការត្រូវបានលក់ទៅឲ្យវិនិយោគិនសក្តានុពលថាជាការវិនិយោគនៅក្នុងផលបត្រដែលមានទ្រព្យសកម្មរយៈពេលមធ្យម ដែលមានអត្រាខ្ពស់ជាមួយនឹង ការរប្រឈមអប្បបរមាទៅនឹងហានិភ័យឥណទាន ដែលពាក់ពន្ធ័នឹងការបោកប្រាស់មិនសងដែលអាចកើតមានរបស់ក្រុមហ៊ុនបោះផ្សាយទ្រព្យសកម្ម នៅក្នុងផលបត្រ។ អ្នកផ្ទេរកម្មសិទ្ធិជាច្រើននាក់ លក់ផលបត្រទ្រព្យសកម្មរយៈពេលមធ្យមដែលមានគុណភាពខ្ពស់ទៅអ្នកដែលជាអភិបាល។ អ្នកផ្ទេរកម្មសិទ្ធិនិមួយៗផ្តល់សេវាដល់ផលបត្រទ្រព្យសកម្ម ដែលខ្លួនលក់ទៅឲ្យអភិបាលនិងគ្រប់គ្រងគណនីត្រូវទទួលដែលមានការបោកប្រាស់មិនសងសម្រាប់ប្រាក់កម្រៃសេវាដែលផ្អែកលើទីផ្សារ។ អ្នកផ្ទេរកម្មសិទ្ធិនិមួយៗ ក៏ផ្តល់នូវការការពារលើការខាតបង់លើកដំបូងចំពោះការខាតបង់ ខាងឥណទានដែលកើតឡើងដោយផលបត្រទ្រព្យសកម្មរបស់ខ្លួនតាមរយៈភាវូបនីយកម្មទ្រព្យបញ្ចាំ នៃ

ទ្រព្យសកម្មដែលបានផ្ទេរទៅឲ្យអភិបាល។ អ្នកធានាបង្កើតលក្ខខណ្ឌនៃអភិបាល-ភាព និងគ្រប់គ្រងប្រតិបត្តិការរបស់អភិបាល ដើម្បីបានប្រាក់កម្រៃ ដែលផ្អែកលើអត្រាទីផ្សារ។ ប្រាក់កម្រៃមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មបានផ្តល់ឲ្យ។ អ្នកធានាយល់ព្រមឲ្យអ្នកលក់ដែលមានការអនុញ្ញាតិលក់ទៅឲ្យអភិបាល, អនុម័តយល់ព្រមលើទ្រព្យសកម្មដែលត្រូវទិញដោយអភិបាល និងធ្វើការសម្រេចចិត្តអំពីទុនរបស់អភិបាល។ អ្នកធានាត្រូវធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់វិនិយោគិនទាំងអស់។

អ្នកធានាមានសិទ្ធិទទួលបានចំណែកនៅសល់ នៃប្រាក់ចំណេញរបស់អភិបាល និងផ្តល់នូវឧបករណ៍សម្របសម្រួលឥណទាន និងសន្ទនីយភាពចំពោះអភិបាល។ ឧបករណ៍សម្របសម្រួលឥណទាន ដែលបានផ្តល់ឲ្យដោយអ្នកធានាស្រូបយកនូវការខាតបង់រហូតដល់៥ភាគរយនៃទ្រព្យសកម្មសរុបរបស់អភិបាលបន្ទាប់ពីការខាតបង់ដែលបានស្រូបយក ដោយអ្នកផ្ទេរកម្មសិទ្ធិ។ ឧបករណ៍សម្របសម្រួលសន្ទនីយភាពមិនត្រូវបានធ្វើឲ្យប្រសើរឡើងនូវទ្រព្យសកម្ម ដែលមានលទ្ធភាពនៃការមិនសង។ វិនិយោគិនមិនកាន់កាប់សិទ្ធិលើសលែង ដែលអាចមានផលប៉ះពាល់ដល់សិទ្ធិអំណាចនៃការសម្រេចចិត្តរបស់អ្នកធានា។

បើទោះបីជា អ្នកធានាបានទទួលកម្រៃផ្អែកលើអត្រាទីផ្សារសម្រាប់សេវារបស់ខ្លួនដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសេវាកម្មដែលបានផ្តល់ អ្នកធានាមានការប្រឈមទៅនឹងភាពប្រែប្រួលនៃប្រាក់ចំណេញដែលបានពី សកម្មភាពរបស់អភិបាលដោយសារតែសិទ្ធិរបស់ខ្លួនចំពោះប្រាក់ចំណេញ ដែលនៅសល់របស់អភិបាលនិងការត្រៀមបំរុងឧបករណ៍សម្របសម្រួលឥណទាន និងសន្ទនីយភាព

(មានន័យថា អភិបាលត្រូវប្រឈមនឹងហានិភ័យសន្ទនីយភាព ដោយការប្រើឧបករណ៍ហិរញ្ញវត្ថុបំណុលរយៈពេលខ្លីសម្រាប់ធ្វើហិរញ្ញប្បទានទ្រព្យសកម្មរយៈពេលមធ្យម)។ ទោះបីជា អ្នកផ្ទេរកម្មសិទ្ធិនិមួយៗ មានសិទ្ធិធ្វើការសម្រេចចិត្តដែលមានផលប៉ះពាល់ដល់តម្លៃរបស់ទ្រព្យសកម្មរបស់អភិបាល, អ្នកធានាមានសិទ្ធិអំណាចនៃការសម្រេចចិត្តយ៉ាងទូលំទូលាយ ដែលផ្តល់ឱ្យខ្លួននូវលទ្ធភាពបច្ចុប្បន្នដើម្បីដឹកនាំសកម្មភាព ដែលមានផលប៉ះពាល់ជាដុំកំភួនបំផុតលើប្រាក់ចំណេញរបស់អភិបាល (មានន័យថា អ្នកធានាលក្ខខណ្ឌនៃអភិបាលភាព, មានសិទ្ធិធ្វើការសម្រេចចិត្តអំពីទ្រព្យសកម្ម (អនុម័តលើទ្រព្យសកម្មបានទិញ និងអ្នកផ្ទេរកម្មសិទ្ធិនៃទ្រព្យសកម្មទាំងនោះ) និងដើមទុនរបស់អភិបាល (សម្រាប់ការវិនិយោគថ្មីដែលត្រូវតែស្វែងរក លើមូលដ្ឋានទៀងទាត់))។ សិទ្ធិចំពោះប្រាក់ចំណេញ នៅសល់របស់អភិបាល និងការត្រៀមបម្រុងឧបករណ៍សម្របសម្រួលឥណទាននិងសន្ទនីយភាពធ្វើឱ្យអ្នកធានាត្រូវប្រឈមនឹងភាពប្រែប្រួលប្រាក់ចំណេញ ដែលបានពីសកម្មភាពរបស់អភិបាល ដែលមានភាពខុសគ្នាពីចំណែករបស់វិនិយោគិនផ្សេងៗទៀត។ ដោយយោងតាមនេះ ការប្រឈមនោះបង្ហាញថាអ្នកធានាគឺជាភារប្បទាយី និងហេតុដូច្នេះ អ្នកធានាសន្និដ្ឋានថា ខ្លួនមានអភិបាលភាពលើអភិបាល។ កាតព្វកិច្ចរបស់អ្នកធានា ដែលត្រូវធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់វិនិយោគិនទាំងអស់មិនរារាំងអ្នកធានា ពីការក្លាយជាភារប្បទាយីឡើយ។

## ទំនាក់ទំនងជាមួយបណ្តាភាគីផ្សេងទៀត

២៧៣ នៅពេលវាយតម្លៃលើអភិបាលភាព ក្រុមហ៊ុនវិនិយោគត្រូវពិចារណាអំពីចរិតលក្ខណៈនៃទំនាក់ទំនងរបស់ខ្លួនជាមួយបណ្តាភាគីផ្សេងទៀត និងថាតើបណ្តាភាគីទាំងនោះកំពុងធ្វើសកម្មភាពក្នុងនាមរបស់វិនិយោគិន ឬយ៉ាងណា (មានន័យថា ជាភ្នាក់ងារតាមព្រឹត្តន័យ(de facto agent))។ ការកំណត់ថាតើបណ្តាភាគីផ្សេងទៀត ធ្វើសកម្មភាពជាភ្នាក់ងារ តាមព្រឹត្តន័យតម្រូវឲ្យមានការវិនិច្ឆ័យ ដោយពិចារណាទាំងចរិតនៃទំនាក់ទំនង និងរបៀបដែលបណ្តា ភាគីផ្សេងទៀតធ្វើអន្តរសកម្មភាពជាមួយគ្នាទៅវិញទៅមក និងជាមួយនឹងក្រុមហ៊ុនវិនិយោគ។

២៧៤ ទំនាក់ទំនងនោះមិនចាំបាច់មានការរៀបចំជាកុងត្រាឡើយ។ ភាគីមួយគឺជាភ្នាក់ងារតាមព្រឹត្តន័យ នៅពេលដែលក្រុមហ៊ុនវិនិយោគមាន ឬភ្នាក់ងារនោះដឹកនាំសកម្មភាពរបស់ក្រុមហ៊ុនវិនិយោគមានលទ្ធភាពដឹកនាំភាគីនោះ ដើម្បីធ្វើសកម្មភាព ក្នុងនាមក្រុមហ៊ុនវិនិយោគ។ នៅក្នុងកាលៈទេសៈទាំងនេះ ក្រុមហ៊ុនវិនិយោគត្រូវពិចារណាសិទ្ធិនៃការសម្រេចចិត្តរបស់ភ្នាក់ងារតាមព្រឹត្តន័យរបស់ខ្លួននិងការប្រឈមដោយប្រយោល ឬសិទ្ធិចំពោះប្រាក់ចំណេញដែលមានការប្រែប្រួលតាមរយៈភ្នាក់ងារ តាមព្រឹត្តន័យ រួមជាមួយនឹងសិទ្ធិរបស់ខ្លួនផ្ទាល់ ពេលពិចារណា អំពីអភិបាល-ភាព លើក្រុមហ៊ុនរងការវិនិយោគ។

២៧៥ ឧទាហរណ៍ខាងក្រោម ស្ដីពីបណ្ដាភ្នាក់ងារផ្សេងៗដែល, តាមចរិតនៃទំនាក់ទំនងរបស់ពួកគេ, អាចធ្វើសកម្មភាព ជាភ្នាក់ងារតាមព្រឹត្តន័យសម្រាប់ក្រុមហ៊ុនវិនយោគៈ

(ក) បណ្ដាភាគីពាក់ពន្ធ័របស់ក្រុមហ៊ុនវិនិយោគ។

(ខ) ភាគីដែលបានទទួលភាគកម្មនៅក្នុងក្រុមហ៊ុនរងការវិនិយោគ ក្នុងទម្រង់ជាប្រាក់វិនិយោគឬជាប្រាក់កម្ចីពីក្រុមហ៊ុនវិនិយោគ។

(គ) ភាគីដែលមិនយល់ព្រមលក់ ផ្ទេរ ឬដាក់ទម្ងន់ភាគកម្មរបស់ខ្លួននៅក្នុងក្រុមហ៊ុនរងការវិនិយោគដោយមិន ចាំបាច់ទទួលបានការអនុម័តយល់ព្រមជាមុន ពីក្រុមហ៊ុនវិនិយោគឡើយ (លើកលែងតែស្ថានភាពដែលក្រុមហ៊ុនវិនិយោគ និងបណ្ដាភាគីផ្សេងទៀតមានសិទ្ធិស្ដីពីការអនុម័តជាមុននិងមានសិទ្ធិដែលផ្អែកលើលក្ខខណ្ឌដែលបានព្រមព្រៀងទៅវិញទៅមកដោយបណ្ដាភាគីឯករាជ្យ)។

(ឃ) ភាគី ដែលមិនអាចធ្វើហិរញ្ញប្រទានលើប្រតិបត្តិការរបស់ខ្លួនឯងបាន ដោយមិនមានការគាំពារផ្នែកហិរញ្ញវត្ថុថ្នាក់ទាបពីក្រុមហ៊ុនវិនិយោគ។

(ង) ក្រុមហ៊ុនរងការវិនិយោគ ដែលមានសមាជិកមួយចំនួនធំ នៃក្រុមប្រឹក្សាភិបាល ឬដែលមានអ្នកគ្រប់គ្រងជាន់ខ្ពស់គឺជាបុគ្គលតែមួយជាមួយនឹងក្រុមហ៊ុនវិនិយោគ។

(ច) ភាគី ដែលមានទំនាក់ទំនងអាជីវកម្មជិតស្និទ្ធ ជាមួយក្រុមហ៊ុនវិនិយោគ ដូចជាទំនាក់ទំនងរវាងអ្នកផ្ដល់សេវាវិជ្ជាជីវៈជាមួយនឹងបណ្ដាអតិថិជនសំខាន់ៗរបស់ខ្លួន។

## អភិបាលភាពលើទ្រព្យសកម្មជាក់លាក់

២៧៦ ក្រុមហ៊ុនវិនិយោគត្រូវពិចារណាថាតើ ខ្លួនប្រព្រឹត្តចំណែកមួយរបស់ក្រុមហ៊ុនរងការវិនិយោគ ថាជាអង្គភាពដាច់ដោយឡែកយ៉ាងណា និង, ប្រសិនបើដូច្នោះ ថាតើខ្លួនធ្វើអភិបាលភាព លើអង្គភាពដាច់ដោយឡែកនោះដែរ ឬយ៉ាងណា។

២៧៧ ក្រុមហ៊ុនវិនិយោគត្រូវប្រព្រឹត្តិចំណែកមួយរបស់ក្រុមហ៊ុនរងការវិនិយោគ ថាជាអង្គភាពដាច់ដោយឡែកមួយ ប្រសិនបើ និងតែក្នុងករណី ដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញៈ

ទ្រព្យសកម្មជាក់លាក់ របស់ក្រុមហ៊ុនរងការវិនិយោគ (និងឧបករណ៍សម្រួលឥណទាន ប្រសិនបើមាន) គឺជាប្រភពតែមួយគត់នៃការទូទាត់សម្រាប់បំណុលជាក់លាក់មួយ ឬសម្រាប់ភាគកម្មផ្សេងទៀតរបស់ក្រុមហ៊ុនរងការវិនិយោគ។ បណ្តាភាគី ដែលមិនមែនពាក់ពន្ធ័នឹងបំណុលជាក់លាក់មិនមានសិទ្ធិ ឬមិនមានកាតព្វកិច្ចទាក់ទងនឹងទ្រព្យសកម្មជាក់លាក់ ឬចំពោះលំហូរសាច់ប្រាក់ដែលនៅសល់ពីទ្រព្យសកម្មទាំង នោះ។ នៅក្នុងន័យនេះ មិនមានប្រាក់ចំណេញពីទ្រព្យសកម្មជាក់លាក់អាចត្រូវបានប្រើដោយក្រុមហ៊ុនរងការវិនិយោគដែលនៅសល់និងមិនមានបំណុលរបស់អង្គភាពដាច់ដោយឡែក អាចត្រូវបានសងដោយប្រើទ្រព្យសកម្មរបស់ក្រុមហ៊ុនរងការវិនិយោគដែលនៅសល់ឡើយ។ដូច្នេះ នៅក្នុងន័យនេះ ទ្រព្យសកម្មទាំងអស់ បំណុលទាំងអស់ និងទ្រព្យម្ចាស់ទាំងអស់របស់អង្គភាពដាច់ដោយឡែកនោះគឺជាខែល

ការពារក្រុមហ៊ុនរងការវិនិយោគទាំងមូល។ អង្គភាពដាច់ដោយឡែកបែបនេះ ត្រូវបានហៅថា “ផលារាជ”។

២៧៨ នៅពេលដែលលក្ខខណ្ឌ នៅក្នុងកថាខណ្ឌ ២៧៧ ត្រូវបានបំពេញ, ក្រុមហ៊ុនវិនិយោគត្រូវកំណត់សកម្មភាពដែល មានផលប៉ះពាល់ជាដុំកំភួនលើប្រាក់ចំណេញរបស់អង្គភាពដាច់ដោយឡែកនោះនិងរបៀបដែលសកម្មភាពទាំងនោះត្រូវ បានដឹកនាំដើម្បីវាយតម្លៃថាតើ ខ្លួនមានអំណាច លើចំណែកណាមួយរបស់ក្រុមហ៊ុនរងការវិនិយោគ។ នៅពេលវាយតម្លៃអភិបាលភាព នៃអង្គភាព ដោយឡែកនោះ ក្រុមហ៊ុនវិនិយោគត្រូវពិចារណាផងដែរថាតើ ខ្លួនមានការប្រឈម ឬសិទ្ធិចំពោះប្រាក់ចំណេញអថេរដែលបានពីការពាក់ពន្ធ័របស់ខ្លួនជាមួយនឹងអង្គភាពដាច់ដោយឡែកនោះនិងលទ្ធភាពនៃការប្រើប្រាស់អំណាចលើចំណែកមួយរបស់ក្រុមហ៊ុនរងការវិនិយោគនៅពេលវាយតម្លៃអភិបាលភាពលើ, និងក្នុងការរួមបញ្ចូល, ក្រុមហ៊ុនរងការវិនិយោគ។

២៧៩ ប្រសិនបើ ក្រុមហ៊ុនវិនិយោគធ្វើអភិបាលភាព លើអង្គភាពដាច់ដោយឡែកនោះ ក្រុមហ៊ុនវិនិយោគត្រូវរួមបញ្ចូល ចំណែកមួយរបស់ក្រុមហ៊ុនរងការវិនិយោគ។ នៅក្នុងករណីនោះ បណ្តាភាគីផ្សេងទៀត ត្រូវដកចេញនូវផ្នែកនោះរបស់ក្រុមហ៊ុនរងការវិនិយោគនៅពេលវាយតម្លៃ អភិបាល-ភាពលើនិងការរួមបញ្ចូលក្រុមហ៊ុនរងការវិនិយោគ។

## ការវាយតម្លៃបន្ត

២៨០ ក្រុមហ៊ុនវិនិយោគត្រូវវាយតម្លៃឡើងវិញថាតើខ្លួនធ្វើអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគឬយ៉ាងណាប្រសិនបើហេតុការណ៍ឬកាលៈទេសៈបង្ហាញថា មានការផ្លាស់ប្ដូរសមាសធាតុមួយឬច្រើននៃអភិបាលភាពដែលបានបង្ហាញនៅក្នុងកថាខណ្ឌ៧។

២៨១ ប្រសិនបើ មានការផ្លាស់ប្ដូរអំណាចទៅលើក្រុមហ៊ុនរងការវិនិយោក អាចត្រូវបានអនុវត្តន៍ ការផ្លាស់ប្ដូរនោះត្រូវតែបានឆ្លុះបញ្ចាំង នៅក្នុងរបៀបដែលក្រុមហ៊ុនវិនិយោគវាយតម្លៃអំពីអំណាចរបស់ខ្លួនទៅលើក្រុមហ៊ុនរងការវិនិយោគ។ ឧទាហរណ៍ ការផ្លាស់ប្ដូរចំពោះសិទ្ធិនៃការសម្រេចចិត្ត អាចមានន័យថា សកម្មភាពពាក់ពន្ធ័មិនត្រូវបានកំណត់តាមរយៈនៃការសំលេងឆ្នោតទៀតទេ តែត្រូវបានជំនួសដោយកិច្ចព្រមព្រៀងផ្សេងទៀត ដូចជាកុងត្រាដែលផ្ដល់ឲ្យភាគីមួយ ឬភាគីច្រើននូវលទ្ធភាពបច្ចុប្បន្ន ដើម្បីដឹកនាំសកម្មភាពពាក់ពន្ធ័។

២៨២ ព្រឹត្តិការណ៍មួយអាចបណ្ដាលឲ្យក្រុមហ៊ុនវិនិយោគទទួលបាន ឬបាត់បង់អំណាច លើក្រុមហ៊ុនរងការវិនិយោគ ដោយមិនចាំបាច់ឲ្យក្រុមហ៊ុនវិនិយោគ ពាក់ពន្ធ័នឹងព្រឹត្តិការណ៍នោះឡើយ។ ឧទាហរណ៍ ក្រុមហ៊ុនវិនិយោគអាចទទួលបានអំណាចលើក្រុមហ៊ុនរងការវិនិយោគដោយសារតែសិទ្ធិនៃការសម្រេចចិត្តដែលត្រូវបានកាន់កាប់ដោយភាគីមួយ ឬភាគីច្រើនផ្សេងទៀតដែលបានរារាំងក្រុមហ៊ុនវិនិយោគពីការធ្វើអភិបាលភាពលើក្រុមហ៊ុនរង ការវិនិយោគបានហួសកំណត់ពេល។

២៨៣ ក្រុមហ៊ុនវិនិយោគ ក៏ត្រូវពិចារណាផងដែរនូវការផ្លាសប្ដូរ ដែលមានផលប៉ះពាល់ដល់ការប្រឈម ឬសិទ្ធិចំពោះ ប្រាក់ចំណេញថេរ ដែល

បានពីការពាក់ព័ន្ធ ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ។ ឧទាហរណ៍ ក្រុមហ៊ុនវិនិយោគ ដែលមានអំណាចលើក្រុមហ៊ុនរងការវិនិយោគ អាចបាត់បង់អភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគ ប្រសិនបើ ក្រុមហ៊ុនវិនិយោគលែងមានសិទ្ធិទទួលប្រាក់ចំណេញឬលែងត្រូវប្រឈមនឹងកាតព្វកិច្ច ដោយសារតែក្រុមហ៊ុនវិនិយោគមិនបានបំពេញតាមកថាខណ្ឌ៧(ខ) (ឧទាហរណ៍ ប្រសិនបើកិច្ចសន្យា ដើម្បីទទួលបានប្រាក់កម្រៃផ្អែកលើលទ្ធផលត្រូវបានបញ្ចប់)។

ខ៨៤ ក្រុមហ៊ុនវិនិយោគត្រូវពិចារណាថាតើការវាយតម្លៃរបស់ខ្លួនថាតើខ្លួនជាភ្នាក់ងារឬជាភារប្បទាយីត្រូវបានផ្លាស់ប្តូរ ឬយ៉ាងណា។ ការផ្លាស់ប្តូរនៅក្នុងទំនាក់ទំនងទូទៅរវាងក្រុមហ៊ុនវិនិយោគនិងបណ្តាភាគីផ្សេងទៀត អាចមានន័យថាក្រុមហ៊ុនវិនិយោគលែងជាភ្នាក់ងារទៀតហើយ បើទោះបីជា ពីមុនខ្លួនបានដើរតួជាភ្នាក់ងារក៏ដោយ,និងផ្ទុយមកវិញ។ ឧទាហរណ៍ ប្រសិនបើការផ្លាស់ប្តូរ ចំពោះសិទ្ធិរបស់ក្រុមហ៊ុនវិនិយោគ ឬរបស់ភាគីផ្សេងទៀតកើតឡើង ក្រុមហ៊ុនវិនិយោគត្រូវពិចារណាឡើងវិញ អំពីស្ថានភាពរបស់ខ្លួនជាភារប្បទាយីឬភ្នាក់ងារ។

ខ៨៥ ការវាយតម្លៃអំពីអភិបាលភាពលើកដំបូងរបស់ខ្លួន ឬស្ថានភាពរបស់ខ្លួនជាភ្នាក់ងារឬជាភារប្បទាយីនឹងមិនធ្វើឲ្យមានការផ្លាស់ប្តូរដោយសារតែការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារនោះឡើយ (ឧទាហរណ៍ ការផ្លាស់ប្តូរប្រាក់ចំណេញរបស់ក្រុមហ៊ុនរងការវិនិយោគ ដែលត្រូវបានជម្រុញ ដោយលក្ខខណ្ឌទីផ្សារ) ដរាបណា ការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌទីផ្សារធ្វើឲ្យ

ផ្លាស់ប្តូរសមាសធាតុមួយឬច្រើននៃអភិបាលភាព ដែលមានចែងនៅក្នុងកថាខណ្ឌ ៧ ឬ ការផ្លាស់ប្តូរទំនាក់ទំនងទៅរវាងភាគីប្រធាន និងភ្នាក់ងារ។

## ការតម្រូវផ្នែកគណនេយ្យ

### បែបបទនៃការធ្វើសមាស

ខ៨៦ របាយការណ៍ហិរញ្ញវត្ថុសមាសៈ

(ក) បង្រួមចូលគ្នានៃធាតុដែលដូចគ្នារបស់ទ្រព្យសកម្ម បំណុល ទ្រព្យម្ចាស់ ចំណូល ចំណាយ និងចលនាសាច់ប្រាក់របស់ក្រុមហ៊ុនមេជាមួយនឹងទ្រព្យសកម្ម បំណុល ទ្រព្យម្ចាស់ ចំណូល ចំណាយ និងចលនាសាច់ប្រាក់របស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

(ខ) កាត់កង (បំបាត់ចោល) បរិមាណលើបញ្ជីការវិនិយោគរបស់ក្រុមហ៊ុនមេ នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនិមួយៗ និងចំណែកមួយនៃទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេ នៅក្នុងទ្រព្យម្ចាស់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិ៣ ពន្យល់ពីរបៀបនៃការកំណត់មូលនិធិពាណិជ្ជកម្ម)។

(គ) បំបាត់ចោលទាំងស្រុង ទ្រព្យសកម្ម បំណុល ទ្រព្យម្ចាស់ ចំណូល ចំណាយ និងចលនាសាច់ប្រាក់របស់អន្តោសមុទាយទាក់ទងនឹងប្រតិបត្តិការណ៍រវាងអង្គភាពនានារបស់សុមទាយ (ចំណេញ ឬខាតដែលកើតឡើងពីប្រតិបត្តិការ អន្តោសមុទាយ ដែលត្រូវទទួលស្គាល់ទ្រព្យសកម្ម ដូចជាសន្និធិ និងទ្រព្យសកម្មរយៈពេលវែងត្រូវតែលុបចោលទាំងស្រុង)។ ការខាតបង់របស់អន្តោសមុទាយអាចបង្ហាញថាការថយចុះតម្លៃនឹងតម្រូវឲ្យមានការទទួលស្គាល់នៅ

ក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស។ស្តង់ដារគណនេយ្យអន្តរជាតិ ១២*ពន្ធលើប្រាក់ចំណេញ* អនុវត្តន៍ ចំពោះភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងពីការបំបាត់ចោលចំណេញឬខាតដែលកើតចេញពីប្រតិបត្តិការអន្តោសមុទាយ។

## បណ្តាគោលនយោបាយគណនេយ្យតែមួយដូចគ្នា

ខ៨៧ ប្រសិនបើ សមាជិកនៃសមុទាយប្រើគោលនយោបាយគណនេយ្យ ដែលមិនមែនជាគោលនយោបាយដែលប្រើនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាសសម្រាប់ប្រតិបត្តិការ និងព្រឹត្តិការណ៍ដូចគ្នានៅក្នុងកាលៈទេសៈស្រដៀងគ្នា, ការកែសម្រួលសមស្របត្រូវបានធ្វើឡើងចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់សមុទាយនោះ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាសដើម្បីធានានូវអនុលោមភាពជាមួយគោលនយោបាយគណនេយ្យរបស់សមុទាយ។

## ការវាស់វែង

ខ៨៨ អង្គភាពរួមបញ្ចូលចំណូលនិងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាសគិតពីថ្ងៃដែលខ្លួនទទួលបានអភិបាលភាពរហូតដល់កាលបរិច្ឆេទដែលអង្គភាពលែងមានអភិបាលភាពលើក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ចំណូលនិងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវផ្អែកលើបរិមាណនៃទ្រព្យសកម្ម និងបំណុល ដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាសនាកាលបរិច្ឆេទទិញ។ ឧទាហរណ៍ ចំណាយរំលស់ដែលទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលសរុបរួមសមាស

ក្រោយកាលបរិច្ឆេទនៃការទិញត្រូវផ្អែកលើតម្លៃសមស្របរបស់ទ្រព្យសកម្មអាចដកវិលស់បាន ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស នាកាលបរិច្ឆេទទិញ។

## សិទ្ធិបោះឆ្នោតសក្តានុពល

ខ៨៩ នៅពេលដែល សិទ្ធិបោះឆ្នោតសក្តានុពលឬនិស្សន្ទផ្សេងទៀតរួមមានសិទ្ធិបោះឆ្នោតសក្តានុពល សមាមាត្រនៃចំណេញឬការខាតបង់ និងការផ្លាស់ប្តូរនៅក្នុងទ្រព្យម្ចាស់ដែលបានបែងចែកទៅឲ្យក្រុមហ៊ុនមេនិងភាគកម្មគ្មានអភិបាលនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសមាស ត្រូវបានកំណត់ដោយផ្អែកលើតែភាគកម្មកម្មសិទ្ធិ ដែលមានស្រាប់ប៉ុណ្ណោះ និងមិនឆ្លុះបញ្ចាំងការអនុវត្តន៍ឬការបំប្លែងនៃសិទ្ធិបោះឆ្នោតសក្តានុពលឬនិស្សន្ទផ្សេងទៀតឡើយ ដរាបណា អនុវត្តន៍កថាខណ្ឌ ខ៩០។

ខ៩០ នភៅក្នុងកាលៈទេសៈខ្លះ អង្គភាពមួយមានភាគកម្មកម្មសិទ្ធិ ដែលមានស្រាប់ ដែលបានមកពីប្រតិបត្តិការដែល បច្ចុប្បន្ននេះផ្តល់ឲ្យអង្គភាពទទួលបាននូវប្រាក់ចំណេញពាក់ពន្ធ័នឹងភាគកម្មកម្មសិទ្ធិនោះ។ នៅក្នុងកាលៈទេសៈ បែបនេះសមាមាត្រ ដែលបានបែងចែកឲ្យក្រុមហ៊ុនមេ និងភាគកម្មគ្មានអភិបាលភាពនៅក្នុងការរៀបចំរបាយការណ៍សមាស ត្រូវបានកំណត់ដោយការដាក់បញ្ចូលការអនុវត្តជាយថាហេតុ នៃសិទ្ធិបោះឆ្នោតសក្តានុពល និងនិស្សន្ទផ្សេងទៀត ដែលបច្ចុប្បន្នផ្តល់ឲ្យអង្គភាព ទទួលបាននូវប្រាក់ចំណេញ។

ខ៩១ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ មិនអនុវត្តន៍ចំពោះភាគកម្មនៅក្នុងបណ្តាក្រុមហ៊ុនបុត្រសម្ពន្ធ័ដែលត្រូវធ្វើសមាសឡើយ។ នៅពេល

ដែលឧបករណ៍ហិរញ្ញវត្ថុមានសិទ្ធិបោះឆ្នោតសក្តានុពល ដែលមានសារៈសំខាន់ក្នុងការទទួលបាននូវប្រាក់ចំណេញពាក់ព័ន្ធនឹងភាគកម្មកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឧបករណ៍ហិរញ្ញវត្ថុនោះមិនមែនជាកម្មវត្ថុ ដែលតម្រូវនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ឡើយ។ នៅក្នុងគ្រប់ករណីផ្សេងទៀត ឧបករណ៍ហិរញ្ញវត្ថុដែលមានសិទ្ធិបោះឆ្នោតសក្តានុពលនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកំណត់ដោយយោង តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩។

## កាលបរិច្ឆេទរាយការណ៍

ខ៩២ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ និងបណ្តាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានប្រើនៅក្នុងការរៀបចំរបាយការរណ៍សមាសត្រូវមានកាលបរិច្ឆេទដូចគ្នា។ នៅពេលដែលការិយបរិច្ឆេទរាយការណ៍ចុងគ្រារបស់ក្រុមហ៊ុនមេខុសគ្នាពី ការិយបរិច្ឆេទរាយការណ៍របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ សម្រាប់គោលបំណងនៃការធ្វើសមាសក្រុមហ៊ុនបុត្រសម្ពន្ធ័ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ បន្ថែមតាមកាលបរិច្ឆេទដូចគ្នានឹងកាលបរិច្ឆេទរបស់ក្រុមហ៊ុនមេ ដើម្បីអាចឲ្យក្រុមហ៊ុនមេ ធ្វើសមាសពិត័មានហិរញ្ញវត្ថុ របស់ក្រុមហ៊ុនបុត្រសម្ពន្ធ័បាន ដរាបណា វាមិនអាចធ្វើដូច្នោះបាន។

ខ៩៣ ប្រសិនបើ វាមិនអាចធ្វើដូច្នោះបាន ក្រុមហ៊ុនមេត្រូវធ្វើសមាសពិត័មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ ដោយប្រើរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយបំផុតរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ដែលបានកែសម្រួលផលប៉ះពាល់នៃប្រតិបត្តិការឬព្រឹត្តិការណ៍សំខាន់ៗ ដែលកើតឡើងរវាងកាលបរិច្ឆេទនៃ

របាយការណ៍ហិរញ្ញវត្ថុទាំងនោះជាមួយនឹង កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសមាស។ នៅក្នុងករណីណាក៏ដោយភាពខុសគ្នារវាងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរបស់លក្រុមហ៊ុនបុត្រសម្ពន្ធ័ និងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសមាស មិនត្រូវលើសពីរយៈពេល ៣ខែ ឡើយ និងរយៈពេលនៃការិយបរិច្ឆេទរាយការណ៍និងភាពខុសគ្នារវាងកាលបរិច្ឆេទនៃរបាយការណ៍ទាំងនោះត្រូវតែដូចៗគ្នាទាំងអស់ ពីការិយបរិច្ឆេទមួយទៅកាលបរិច្ឆេទមួយទៀត។

## ភាគកម្មគ្មានអភិបាលភាព

១៩៤ អង្គភាពត្រូវបែងចែកចំណេញឬខាតនិងសមាសធាតុនិមួយៗនៃចំណេញបន្ទាប់បន្សំទៅឲ្យម្ចាស់នៃក្រុមហ៊ុនមេ និងទៅភាគកម្មគ្មានអភិបាលភាព។ អង្គភាព ត្រូវបែងចែកផងដែរ នូវចំណេញបន្ទាប់បន្សំសរុបទៅឲ្យម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមេនិងម្ចាស់ភាគហ៊ុននៃភាគកម្មគ្មានអភិបាលភាព បើទោះបីជា ការធ្វើបែបនេះនឹងនាំឲ្យភាគកម្ម គ្មានអភិបាលភាពមានតុល្យភាពឱនភាពក៏ដោយ។

១៩៥ ប្រសិនបើ ក្រុមហ៊ុនបុត្រសម្ពន្ធ័មានភាគហ៊ុនបុរិមាដែលមានការបូកបន្តភាគលាភដែលត្រូវបានចាត់ថ្នាក់ថាជាទ្រព្យម្ចាស់ និងត្រូវបានកាន់កាប់ដោយភាគកម្មគ្មានអភិបាលភាព អង្គភាពត្រូវគណនាចំណែកនៃចំណេញឬខាត បន្ទាប់ពីការកែសម្រួលសម្រាប់ភាគលាភរបស់បណ្ណ័ភាគហ៊ុន បុរិមា បើទោះបីជាភាគលាភត្រូវបានឬមិនត្រូវបានប្រកាសក៏ដោយ។

## ការផ្លាស់ប្តូរនៃសមាមាត្រដែលកាន់កាប់ដោយភាគកម្មគ្មានអភិបាលភាព

១៩៦ នៅពេលដែល សមាមាត្រនៃទ្រព្យម្ចាស់ដែលកាន់កាប់ដោយភាគកម្មគ្មានអភិបាលផ្លាស់ប្តូរ, អង្គភាពត្រូវកែសម្រួលបរិមាណលើបញ្ជីនៃភាគកម្មមានអភិបាល និងភាគកម្មគ្មានអភិបាលដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរភាគកម្មដែលពាក់ពន្ធ័របស់ពួកគេនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។អង្គភាពត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងទ្រព្យម្ចាស់នូវភាពខុសគ្នារវាងបរិមាណដែលភាគកម្មគ្មានអភិបាលភាពដែលត្រូវបានកែសម្រួលជាមួយនឹងតម្លៃសមស្របនៃកម្រៃតបសងដែលបានបង់ ឬបានទទួល និងបែងចែកវាទៅឲ្យម្ចាស់ភាគហ៊ុន នៃក្រុមហ៊ុនមេ។

## ការបាត់បង់អភិបាលភាព

១៩៧ ក្រុមហ៊ុនមេអាចបាត់បង់អភិបាលភាព លើក្រុមហ៊ុនបុត្រសម្ពន្ធ័ នៅក្នុងកិច្ចព្រមព្រៀង (ប្រតិបត្តិការ) ពីរឬច្រើន។ ទោះជាយ៉ាងណា ជួនកាលកាលៈទេសៈបង្ហាញថាកិច្ចព្រមព្រៀងពហុ ត្រូវតែបានរាប់បញ្ចូលសម្រាប់ប្រតិបត្តិការតែមួយគត់ប៉ុណ្ណោះ។ នៅក្នុងការកំណត់ថាតើត្រូវរាប់បញ្ចូលឬយ៉ាងណានូវកិច្ចព្រមព្រៀងជាច្រើនឲ្យទៅជាប្រតិបត្តិការតែមួយគត់នោះ ក្រុមហ៊ុនមេត្រូវពិចារណារាល់លក្ខខណ្ឌ និងការកំហិតនានា នៃកិច្ចព្រមព្រៀងនិង

ផលប៉ះពាល់ខាងសេដ្ឋកិច្ចរបស់ពួកវា។ចំណុចមួយឬច្រើនខាងក្រោមបង្ហាញថា ក្រុមហ៊ុនមេត្រូវតែរាប់បញ្ចូលសម្រាប់កិច្ចព្រមព្រៀងពហុ ថាជាប្រតិបត្តិការតែមួយគត់:

(ក) ពួកវាត្រូវបានដាក់បញ្ចូលនៅក្នុងពេលតែមួយឬនៅក្នុងសហបាលន៍របស់គ្នា។

(ខ) ពួកគេបង្កើតប្រតិបត្តិការតែមួយគត់ ដោយមានបំណងសម្រេចលទ្ធផលពាណិជ្ជកម្មរួមគ្នា។

(គ) ការកើតមានឡើងនៃកិច្ចព្រមព្រៀងមួយ គឺអាស្រ័យលើការកើតមានឡើងនូវកិច្ចព្រមព្រៀមួយផ្សេងទៀត។

(ឃ) កិច្ចព្រមព្រៀងមួយនៅពេលដែលពិចារណាតែឯងមិនផ្តល់យុត្តិកម្មខាងសេដ្ឋកិច្ចឡើយ តែវាផ្តល់យុត្តិកម្មខាងសេដ្ឋកិច្ច នៅពេលដែលវាត្រូវបានពិចារណា ជាមួយនឹងកិច្ចព្រមព្រៀងផ្សេងទៀត។ ឧទាហរណ៍ គឺនៅពេលដែលការលក់ចោលបណ្ណភាគហ៊ុន ដែលមានថ្លៃលក់ក្រោមទីផ្សារ និងត្រូវបានតបសងដោយការលក់នៅពេលក្រោយមកទៀតតាមថ្លៃលក់ដែលខ្ពស់ជាងទីផ្សារ។

ខ៩៨ ប្រសិនបើ ក្រុមហ៊ុនមេបាត់បង់អភិបាលភាព លើក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនត្រូវៈ

(ក) មិនទទួលស្គាល់ៈ

(១) ទ្រព្យសកម្ម (ដែលរួមមានទាំងមូលនិធិពាណិជ្ជកម្ម) និងបំណុលរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ តាមបរិមាណតម្លៃ លើបញ្ជីនាកាលបរិច្ឆេទដែលអភិបាលភាពត្រូវបាត់បង់ និង

(២)បរិមាណតម្លៃលើបញ្ជីរបស់ភាគកម្មគ្មានអភិបាលភាពនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ពន្ធ័នាកាលបរិច្ឆេទដែលអភិបាលភាពត្រូវបានបាតបង់ (រួមទាំងសមាសធាតុនៃចំណេញបន្ទាប់បន្សំដែលបែងចែកឱ្យ ពួកគេផងដែរ)។

(ខ) ទទួលស្គាល់ៈ

(១) តម្លៃសមស្របរបស់កម្រៃតបសងបានទទួល ប្រសិនបើមានពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬកាលៈទេសៈដែលបណ្តាលឲ្យមានការបាត់បង់អភិបាលភាព

(២) ប្រសិនបើប្រតិបត្តិការ ព្រឹត្តិការណ៍ ឬកាលៈទេសៈ ដែលបណ្តាលឲ្យបាត់បង់អភិបាលភាពពាក់ពន្ធ័នឹងការបែងចែកបណ្ណ័ភាគហ៊ុនរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ទៅឲ្យម្ចាស់ភាគហ៊ុនក្នុងនាមពួកគេជាម្ចាស់ភាគហ៊ុន ការបែងចែកនោះ និង

(៣) ការវិនិយោគដែលរក្សាទុកនៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធតាមតម្លសសមស្របនៅកាលបរិច្ឆេទ ដែលអភិបាលភាពត្រូវបានបាត់បង់។

(គ) ចាត់ថ្នាក់ឡើងវិញចំពោះចំណេញឬខាត ឬផ្ទេរដោយផ្ទាល់ទៅប្រាក់ចំណេញរក្សាទុកប្រសិនបើត្រូវបានតម្រូវ ដោយស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត, បរិមាណដែលបានទទួលស្គាល់នៅក្នុងផ្នែកចំណេញ បន្ទាប់បន្សំទាក់ទងនឹងក្រុមហ៊ុនបុត្រសម្ពន្ធ័នៅលើមូលដ្ឋានដែលបានបរិយាយនៅក្នុងកថាខណ្ឌ ខ៩៩។

(ឃ) ទទួលស្គាល់ភាពខុសគ្នាដែលកើតមានជាចំណេញ ឬខាត នៅក្នុងផ្នែករបាយការណ៍ចំណេញ ឬខាតដែលបានបែងចែកឲ្យក្រុមហ៊ុនមេ។

ខ៩៩ ប្រសិនបើ ក្រុមហ៊ុនមេបាត់បង់អភិបាលភាព លើក្រុមហ៊ុនបុត្រសម្ពន្ធ័ក្រុមហ៊ុនមេត្រូវគណនារាល់បរិមាណ ដែលបានទទួលស្គាល់ពីមុន នៅក្នុងផ្នែកចំណេញបន្ទាប់បន្សំទាក់ទងនឹងក្រុមហ៊ុនបុត្រសម្ពន្ធ័នោះដោយផ្អែក

លើមូលដ្ឋានដូចគ្នាដែលបានតម្រូវ ប្រសិនបើ ក្រុមហ៊ុនមេបានលក់ចោលនូវទ្រព្យសកម្មនិងបំណុលដែលពាក់ពន្ធ័។ ហេតុដូច្នេះ ប្រសិនបើចំណេញ ឬខាត ដែលបានទទួលស្គាល់ពីមុននៅក្នុងផ្នែកចំណេញបន្ទាប់បន្សំនឹងត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅក្នុងផ្នែកចំណេញ ឬខាត ដោយការលក់ចោលទ្រព្យសកម្មឬបំណុលពាក់ពន្ធ័, ក្រុមហ៊ុនមេត្រូវធ្វើការចាត់ថ្នាក់ឡើងវិញចំណេញ ឬខាតដែលកើតចេញពីទ្រព្យម្ចាស់ទៅជាផ្នែកចំណេញ ឬខាត (ដោយដាក់ថា ការកែសម្រួលដោយការធ្វើការចាត់ថ្នាក់ឡើងវិញ) នៅពេលដែលខ្លួនបាត់បង់អភិបាលភាពលើក្រុមហ៊ុនបុត្រសម្ពន្ធ័។ ប្រសិនបើលើ្មសនៃការវាយតម្លៃឡើងវិញ បានទទួលស្គាល់ពីមុននៅក្នុងផ្នែកចំណេញបន្ទាប់បន្សំនឹងត្រូវបានផ្ទេរដោយផ្ទាល់ទៅប្រាក់ចំណេញរក្សាទុកដោយការលក់ចោលទ្រព្យសកម្ម, ក្រុមហ៊ុនមេ ត្រូវផ្ទេរដោយផ្ទាល់នូវលើ្មសនៃការវាយតម្លៃឡើងវិញទៅផ្នែកប្រាក់ចំណេញរក្សាទុកនៅពេលដែលខ្លួនបាត់បង់អភិបាលភាពលើក្រុមហ៊ុនបុត្រសម្ព័ន្ធ។

**ឧបសម្ព័ន្ធ គ**

**កាលបរិច្ឆេទចូលជាធរមាន និង អន្តរកាល**

*ឧបសម្ព័ន្ធនេះគឺជាផ្នែកមួយនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងមានសិទ្ធិអំណាចដូចគ្នានឹងផ្នែកផ្សេងទៀត របស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។*

## កាលបរិច្ឆេទចូលជាធរមាន

គ១ អង្គភាពត្រូវអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឬបន្ទាប់ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ការអនុវត្តន៍មុនត្រូវបានអនុញ្ញាត។ ប្រសិនបើ អង្គភាពអនុវត្តស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ មុនពេលកំណត់ អង្គភាពត្រូវលាតត្រដាងនូវហេតុការណ៍នោះ និងអនុវត្តស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១២, ស្តង់ដារគណនេយ្យអន្តរជាតិ២៧ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក* , ស្តង់ដារគណនេយ្យអន្តរជាតិ២៨ (បានកែប្រែនៅឆ្នាំ២០១១) នៅពេលជាមួយគ្នា។

## អន្តរកាល

គ២ អង្គភាព ត្រូវអនុវត្តស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ជាប្រតិសកម្ម ដោយអនុលោមតាម ស្តង់ដារគណនេយ្យអន្តរជាតិ ៨

*គោលនយោបាយគណនេយ្យ បម្រែបម្រួលនៅក្នុងការប៉ាន់ស្មានគណនេយ្យ និងលំអៀង*លើកលែង តែអ្វីដែលមានចែងនៅក្នុងកថាខណ្ឌ គ៣-គ៦។

គ៣ នៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ លើកដំបូង, អង្គភាពមិនត្រូវបានតម្រូវឲ្យមានការធ្វើ ការកែសម្រួលចំពោះគណនេយ្យ សម្រាប់ការពាក់ពន្ធ័ជាមួយនឹង:

(ក) បណ្ដាអង្គភាពដែលត្រូវបានធ្វើសមាសពីមុន, ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ២៧ *របាយការណ៍ហិរញ្ញវត្ថុសមាស និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក* និង SIC-១២ ការធ្វើសមាស--អង្គភាពមានគោលបំណងពិសេស, ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, ត្រូវបន្តធ្វើសមាស ឬ

(ខ) អង្គភាពដែលពីមុនមិនធ្វើសមាស ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ២៧ និង SIC-១២ និង, ដោយយោងតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ, ត្រូវបន្តមិនធ្វើសមាស។

គ៤ នៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ លើកដំបូង បណ្ដាលឲ្យក្រុមហ៊ុនវិនិយោគធ្វើសមាស ក្រុមហ៊ុនរងការវិនិយោគ ដែលមិនត្រូវបានធ្វើសមាស ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ២៧ និង SIC-១២ ក្រុមហ៊ុនវិនិយោគត្រូវ:

(ក) ប្រសិនបើក្រុមហ៊ុនរងការវិនិយោគគឺជាអាជីវកម្ម (ដូចបានកំណត់នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣), ដែលវាស់វែងទ្រព្យសកម្ម បំណុល និងភាគកម្មគ្មានអភិបាលភាព នៅក្នុង

ក្រុមហ៊ុន រងការវិនិយោគដែល មិនទាន់ធ្វើសមាសពីមុនមក នាកាលបរិច្ឆេទនៃការអនុវត្តន៍លើកដំបូង ថាជាក្រុមហ៊ុនរងការវិនិយោគ ដែលបានធ្វើសមាស (និង ហេតុដូច្នេះ បានអនុវត្តគណនេយ្យសម្រាប់ការទិញអាជីវកម្ម ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣) ពីកាលបរិច្ឆេទដែលក្រុមហ៊ុនវិនិយោគ ទទួលបានអភិបាលភាព លើក្រុមហ៊ុនរងការវិនិយោគនោះ លើមូលដ្ឋាននៃការតម្រូវរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។

(ខ) ប្រសិនបើក្រុមហ៊ុនរងការវិនិយោគគឺមិនមែនជាអាជីវកម្ម (ដូចបានកំណត់នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣), ដែលវាស់វែងទ្រព្យសកម្ម បំណុល និងភាគកម្មគ្មានអភិបាលភាពនៅក្នុងក្រុមហ៊ុនរងការវិនិយោគដែលមិនទាន់ធ្វើសមាសពីមុនមក នាកាលបរិច្ឆេទនៃការអនុវត្តន៍លើកដំបូង ថាជាក្រុមហ៊ុនរងការវិនិយោគដែលបានធ្វើសមាស (ដោយអនុវត្តវិធីសាស្រ្តសម្រាប់ការទិញអាជីវកម្ម ដូចបានបរិយាយនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣ ដោយមិនទទួលស្គាល់មូលនិធិពាណិជ្ជកម្មណាមួយសម្រាប់ក្រុមហ៊ុនរងការវិនិយោគ) ពីកាលបរិច្ឆេទដែលក្រុមហ៊ុនវិនិយោគទទួលបានអភិបាលភាពលើក្រុមហ៊ុនរងការវិនិយោគនោះ លើមូលដ្ឋាននៃការតម្រូវរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។ ភាពខុសគ្នាណាមួយ រវាងបរិមាណ នៃទ្រព្យសកម្ម បំណុល និងភាគកម្មគ្មានអភិបាលភាពដែលបានទទួលស្គាល់ និង

បរិមាណតម្លៃលើបញ្ជីនៃការពាក់ព័ន្ធរបស់ក្រុមហ៊ុនរងការវិនិយោគ ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ ត្រូវបានគេទទួលស្គាល់ជាការកែសម្រួល ជាមួយនឹងសមតុល្យដើមគ្រារបស់ទ្រព្យម្ចាស់។

(គ) ប្រសិនបើការវាស់វែងទ្រព្យសកម្ម បំណុល និងភាគកម្មគ្មានអភិបាលរបស់ក្រុមហ៊ុនរងការវិនិយោគដោយ អនុលោមតាម (ក) ឬ (ខ) មិនអាចធ្វើទៅបាន ដូចបានកំណត់នៅក្នុង ស្តង់ដារគណនេយ្យអន្តរជាតិ៨), ក្រុមហ៊ុនវិនិយោគត្រូវៈ

(១) ប្រសិនបើក្រុមហ៊ុនរងការវិនិយោគគឺជាអាជីវកម្មដែលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣។ កាលបរិច្ឆេទនៃការទិញអាជីវកម្មត្រូវតែជាការចាប់ផ្តើមនៃការិយបរិច្ឆេទដំបូងបំផុតដែល ការអនុវត្តន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣ អាចអនុវត្តបានដែលអាចជាការិយបរិច្ឆេទបច្ចុប្បន្ន។

(២) ប្រសិនបើ ក្រុមហ៊ុនរងការវិនិយោគ មិនមែនជាអាជីវកម្មដែលអនុវត្តវិធីសាស្ត្រនៃការទិញដូចបាន បរិយាយនៅក្នុងស្តងដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣ ដោយមិនទទួលស្គាល់មូលនិធិពាណិជ្ជកម្ម ណាមួយសម្រាប់ក្រុមហ៊ុនរងការវិនិយោគ នាកាលបរិច្ឆេទនៃការទិញ។កាលបរិច្ឆេទនៃការទិញអាជីវកម្មត្រូវតែជាការចាប់ផ្តើមនៃការិយបរិច្ឆេទដំបូងបំផុតដែល ការអនុវត្តន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ

អន្តរជាតិ ៣ អាចអនុវត្តបាន ដែលអាចជាកាលបរិច្ឆេទបច្ចុប្បន្ន។

ក្រុមហ៊ុនវិនិយោគត្រូវទទួលស្គាល់ភាពខុសគ្នាណាមួយរវាងបរិមាណនៃទ្រព្យសកម្ម បំណុល និងភាគកម្មគ្មានអភិបាលភាព ដែលបានទទួលស្គាល់នាកាលបរិច្ឆេទនៃការទិញ និងបរិមាណដែលបានទទួលស្គាល់ពីមុនដោយសារតែការពាក់ព័ន្ធរបស់ខ្លួនថាជាការកែសម្រួលចំពោះទ្រព្យម្ចាស់សម្រាប់ការិយបរិច្ឆេទនោះ។ ជាការបន្ថែម ក្រុមហ៊ុនវិនិយោគត្រូវផ្តល់នូវព័ត៌មានប្រៀបធៀបនិងការលាតត្រដាងដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ៨។

គ៥ នៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះជាលើកដំបូងដែលបណ្តាលឲ្យ ក្រុមហ៊ុនវិនិយោគ លើកលែងធ្វើសមាសក្រុមហ៊ុនរងការវិនិយោគ ដែលត្រូវបានធ្វើសមាស ដោយអនុលោមតាមស្តង់ដារគណនេយ្យ អន្តរជាតិ២៧ (ដូចបានកែប្រែនៅឆ្នាំ២០០៨) និង SIC-១២, ក្រុមហ៊ុនវិនិយោគត្រូវវាស់វែងភាគកម្មរក្សាទុករបស់ខ្លួន នៅក្នុងក្រុមហ៊ុនរងការវិនិយោគនៅកាលបរិច្ឆេទនៃការអនុវត្តន៍លើកដំបូង តាមបរិមាណដែលខ្លួនអាចត្រូវបានគេវាស់វែង ប្រសិនបើការតម្រូវនៃស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុនេះបានចូលជាធរមាន នៅពេលដែលក្រុមហ៊ុនវិនិយោគបានពាក់ព័ន្ធជាមួយ ឬបាត់បង់អភិបាលភាពរបស់ខ្លួនលើ ក្រុមហ៊ុនរងការវិនិយោគ។ ប្រសិនបើ ការវាស់វែងនៃភាគកម្មរក្សាទុករបស់ខ្លួនមិនអាចអនុវត្តបាន (ដូចបានកំណត់នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ៨), ក្រុមហ៊ុនវិនិយោគ ត្រូវអនុវត្តតាមការតម្រូវ នៃស្តង់ដាររបាយការណ៍

ហិរញ្ញវត្ថុ អន្តរជាតិនេះសម្រាប់កិច្ចគណនេយ្យ សម្រាប់ការបាត់បង់អភិបាលភាពនាការចាប់ផ្តើមនៃការិយបរិច្ឆេទដំបូងបំផុតដែលការអនុវត្តនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះអាចអនុវត្តបានដែលអាចជាការិយបរិច្ឆេទបច្ចុប្បន្ន។ក្រុមហ៊ុនវិនិយោគ ត្រូវទទួលស្គាល់ភាពខុសគ្នាណាមួយរវាងបរិមាណនៃទ្រព្យសកម្ម បំណុល និង ភាគកម្មគ្មានអភិបាលភាពដែលបានទទួលស្គាល់ពីមុន និងបរិមាណតម្លៃលើបញ្ជី នៃការពាក់ពន្ធ័របស់ក្រុមហ៊ុនរងការវិនិយោគ ជាមួយនឹងក្រុមហ៊ុនរងការវិនិយោគ ថាជាការកែសម្រួលជាមួយនឹងទ្រព្យម្ចាស់ សម្រាប់ការិយបរិច្ឆេទនោះ។ ជាការបន្ថែម ក្រុមហ៊ុនវិនិយោគត្រូវផ្តល់នូវព័ត៌មានប្រៀបធៀប និងការលាតត្រដាងដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ៨។

គ៦ កថាខណ្ឌ២៣,កថាខណ្ឌ ខ៩៤, និង កថាខណ្ឌ ខ៩៦-៩៩ គឺជាកំណែប្រែចំពោះស្តង់ដារគណនេយ្យអន្តរជាតិ២៧ ដែលបានធ្វើនៅឆ្នាំ២០០៨ ដែលត្រូវបានដាក់ចូលទៅក្នុង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០។ លើកលែងតែពេលដែល អង្គភាពអនុវត្ត កថាខណ្ឌ គ៣, អង្គភាពត្រូវអនុវត្តការតម្រូវនានានៅក្នុងកថាខណ្ឌទាំង នោះដូចខាងក្រោមៈ

(ក) អង្គភាពមិនត្រូវចែងឡើងវិញការបែងចែលចំណេញ ឬខាតណាមួយសម្រាប់ការិយបរិច្ឆេទរាយការណ៍ មុនពេលដែលខ្លួនអនុវត្តកំណែប្រែនៅក្នុងកថាខណ្ឌខ ៩៤ សម្រាប់ពេលដំបូង។

(ខ) ការតម្រូវនៅក្នុងកថាខណ្ឌ ២៣ និង កថាខណ្ឌ ខ៩៦ សម្រាប់គណនេយ្យសម្រាប់ការផ្លាសប្តូរនៅក្នុងភាគកម្មកម្មសិទ្ធិភាព នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ បន្ទាប់ពីទទួលបានអភិបាលភាព មិនត្រូវ

អនុវត្តចំពោះការផ្លាស់ប្ដូរដែលបានកើតឡើង មុនពេលអង្គភាពបានអនុវត្តកំណែប្រែទាំងនេះសម្រាប់ពេលដំបូង។

(គ) អង្គភាពមិនត្រូវចែងឡើងវិញបរិមាណលើបញ្ជីនៃការវិនិយោគ នៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធឡើយ ប្រសិនបើ អភិបាលភាពត្រូវបានបាត់បង់ មុនពេលដែលខ្លួនអនុវត្តកំណែប្រែនានា នៅក្នុងកថាខណ្ឌ ២៥ និង កថាខណ្ឌ ខ៩៧-ខ៩៩ សម្រាប់ពេលដំបូង។

**សេចក្ដីយោងចំពោះស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩**

គ៧ ប្រសិនបើអង្គភាពអនុវត្តស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ប៉ុន្តែមិនទាន់អនុវត្តស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩, សេចក្ដីយោងណាមួយនៅក្នុងស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ទៅស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ត្រូវចាត់ទុកថាជាសេចក្ដីយោង ចំពោះស្ដង់ដារគណនេយ្យអន្តរជាតិ ៣៩ *ឧបករណ៍ហិរញ្ញវត្ថុៈ ការទទួលស្គាល់និងការវាស់វែង*។

## ការដកចេញនៃស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងៗ

គ៨ ស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ចូលជំនួសការតម្រូវនានាទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុសមាស នៅក្នុងស្ដង់ដារគណនេយ្យអន្តរជាតិ ២៧ (ដូចបានកែប្រែនៅ ឆ្នាំ២០០៨)។

គ៩ ស្ដង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ក៏ចូលជំនួស SIC-១២ ការធ្វើសមាស - អង្គភាពមានគោលបំណងពិសេស ។

## ឧបសម្ព័ន្ធ ឃ

## កំណែប្រែចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងៗទៀត

*ឧបសម្ព័ន្ធនេះកំណត់អំពីកំណែប្រែចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងៗដែលជាហេតុបច្ច័យរបស់ក្រុមប្រឹក្សា ដែលចេញផ្សាយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។ អង្គភាព ត្រូវអនុវត្តកំណែប្រែនេះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ១ ខែមករា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។ ប្រសិនបើអង្គភាពបានអនុវត្ត ស្តង់ដារនេះសម្រាប់ការិយបរិច្ឆេទមុន, អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនេះសម្រាប់ការិយបរិច្ឆេទមុន។ កថាខណ្ឌបានកែប្រែបានបង្ហាញដោយអត្ថបទថ្មីដែលមានគូសបន្ទាត់ និងអត្ថបទដែលលុបចោល ត្រូវបានគូសកាត់ចោល។*

### ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១ ការប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលើកដំបូង

ឃ១ កថាខណ្ឌ៣៩ឈត្រូវបានបន្ថែមដូចខាងក្រោមៈ

៣៩ឈ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមគ្នា* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៣១, កថាខណ្ឌខ៧, កថាខណ្ឌគ១, កថាខណ្ឌឃ១, កថាខណ្ឌឃ១៤, និងបានបន្ថែមកថាខណ្ឌឃ៣១។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួន

អនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

យ២ នៅក្នុងឧបសម្ពន្ធ័ **ខ** កថាខណ្ឌ ខ៧ ត្រូវបានកែប្រែដូចខាងក្រោមៈ

ខ៧ អ្នកប្រើប្រាស់លើកដំបូងត្រូវអនុវត្តការតម្រូវខាងក្រោមនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ទៅពេលអនាគត ដោយគិតចាប់ពីកាលបរិច្ឆេទ អន្តរកាលនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិៈ

(ក) ការតម្រូវនៅក្នុងកថាខណ្ឌ~~២៨~~ខ៩៤ ដែលថាចំណេញបន្ទាបន្សំសរុបត្រូវបានបែងចែកទៅម្ចាស់ភាគហ៊ុននៃ ក្រុមហ៊ុនមេ និងទៅភាគកម្មគ្មានអភិបាល ទោះបីជាប្រការនេះបណ្តាលឲ្យភាគកម្មគ្មានអភិបាលមានសមតុល្យឱនភាពក៏ដោយ,

(ខ) ការតម្រូវនៅក្នុងកថាខណ្ឌ~~៣០ និង៣១~~២៣និង ខ៩៣សម្រាប់ការកត់ត្រាការផ្លាសប្តូរនៅក្នុងភាគកម្មកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ដែលមិនបណ្តាលឲ្យមានការបាត់បង់អភិបាលភាព និង

(គ) ការតម្រូវនៅក្នុងកថាខណ្ឌ ~~៣៤-៣៧~~ខ៩៧-ខ៩៩ សម្រាប់គណនេយ្យសម្រាប់ការបាត់បង់អភិបាលភាពលើក្រុមហ៊ុនបុត្រសម្ពន្ធ័, និង ការតម្រូវពាក់ពន្ធ័នៃកថាខណ្ឌ ៨កនៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៥ *ទ្រព្យសកម្មរយៈពេលវែងដែលរក្សាទុកសម្រាប់លក់ និងប្រតិបត្តិការដែលបានបញ្ឈប់សកម្មភាព*។

ទោះជាយ៉ាងណាប្រសិនបើអ្នកប្រើប្រាស់លើកដំបូងជ្រើសរើសអនុវត្តដោយប្រតិសកម្មស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣ (ដូចបានកែប្រែនៅឆ្នាំ២០០៨)ចំពោះសមាយោគអាជីវកម្មពីអតីតកាល, ខ្លួនត្រូវអនុវត្តផងដែរ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧ (ដូចបានកែប្រែនៅ ឆ្នាំ២០០៨)~~<u>ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០</u> ដោយអនុលោមតាមកថាខណ្ឌ គ១នៃស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ។

ឃ៣ នៅក្នុងឧបសម្ព័ន្ធ គ, កថាខណ្ឌ គ១ ត្រូវបានកែប្រែដូចខាងក្រោមៈ

គ១

អ្នកប្រើប្រាស់លើកដំបូងអាចជ្រើសរើសមិនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣~~(ដូចបានកែប្រែនៅឆ្នាំ២០០៨)~~ ដោយប្រតិសកម្មចំពោះសមាយោគអាជីវកម្មពីអតីតកាល (សមាយោគអាជីវកម្មដែលបានកើតឡើងមុនកាលបរិច្ឆេទអន្តរកាលទៅកាន់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ)។ ប៉ុន្តែ ប្រសិនបើអ្នកប្រើប្រាស់លើកដំបូងថែងឡើងវិញនូវសមាយោគអាជីវកម្មណាមួយដើម្បីអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៣~~(ដូចបានកែប្រែនៅឆ្នាំ២០០៨),~~អ្នកប្រើនោះត្រូវថែងឡើងវិញរាល់សមាយោគអាជីវកម្មក្រោយៗមកទៀត និងត្រូវអនុវត្ត

~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧ (ដូចបានកែប្រែនៅឆ្នាំ២០០៨)~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ គិតចាប់តាំងពីកាលបរិច្ឆេទដូចគ្នានោះ។

ឧទាហរណ៍ប្រសិនបើអ្នកប្រើប្រាស់លើកដំបូងជ្រើសរើសចែងឡើងវិញនូវសមាយោគអាជីវកម្មមួយដែលបានកើតឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០x៦, អ្នកប្រើនោះត្រូវចែងឡើងវិញរាល់សមាយោគអាជីវកម្មដែលបានកើតឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០x៦ និងកាលបរិច្ឆេទអន្តរកាលទៅកាន់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនានា, ហើយអ្នកប្រើត្រូវអនុវត្តផងដែរ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧ (ដូចបានកែប្រែនៅឆ្នាំ២០០៨)~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ គិតចាប់តាំងពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០x៦។

## ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ២ *សំណងផ្អែកលើបណ្ណភាគហ៊ុន*

ឃ៤ កថាខណ្ឌ៦៣កត្រូវបានបន្ថែមដូចខាងក្រោម៖

៦៣ក ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ១១, ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៥ និងឧបសម្ព័ន្ធ ក។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលខ្លួនអនុវត្តស្តង់ដារ

របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

នៅក្នុងឧបសម្ពន្ធ័ **ក** ន័យលក្ខណៈចំពោះនិយមន័យរបស់ "កិច្ចព្រមព្រៀងសំណងផ្អែកលើបណ្ណ័ភាគហ៊ុន" ត្រូវបានកែប្រែដូចខាងក្រោម:

"សមុទាយ" ត្រូវបានឲ្យនិយមន័យនៅក្នុងកថាខណ្ឌ៤ ឧបសម្ពន្ធ័ ក ~~នៃស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*~~*និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក*~~ ថាជា "ក្រុមហ៊ុនមេនិងក្រុមហ៊ុនបុត្រសម្ពន្ធ័របស់ខ្លួន" ដោយឈរលើមូលដ្ឋានទស្សនទានរបស់ក្រុមហ៊ុនមេជិតបំផុតរបស់អង្គភាពរាយការណ៍។

## ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៣ *សមាយោគអាជីវកម្ម*

ឃ៥ កថាខណ្ឌ៧ត្រូវបានកែប្រែ និងកថាខណ្ឌ ៦៤ង ត្រូវបានបន្ថែម ដូចខាងក្រោម:

៧ សេចក្តីណែនាំនៅក្នុង~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* ~~*និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក*~~ ត្រូវបានគេប្រើដើម្បីកំណត់រកអ្នកទិញ- អង្គភាពដែលទទួលបានអភិបាលភាពលើអង្គភាពមួយផ្សេងទៀតមានន័យថាអ្នកលក់។ប្រសិនបើ សមាយោគអាជីវកម្មបានកើតឡើង ប៉ុន្តែអនុវត្តសេចក្តីណែនាំនៅក្នុង~~ស្តង់ដារ~~

~~គណនេយ្យអន្តរជាតិ២៧~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ១០

មិនបង្ហាញឲ្យច្បាស់លាស់អង្គភាពធ្វើសមាហរណកម្មមួយណាដែលជាអ្នកទិញបណ្តាកត្តាដែលមាននៅក្នុងកថាខណ្ឌខ១៤-កថាខណ្ឌខ១៨ត្រូវតែបានពិចារណានៅក្នុងការកំណត់នោះ។

៦៤ង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ ដែលបានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ ៧, កថាខណ្ឌ ខ១៣, កថាខណ្ឌ ខ៦៣(ង) និងឧបសម្ព័ន្ធ ក។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០។

ឃ៦ [មិនអាចអនុវត្តបានចំពោះការតម្រូវ]

ឃ៧ នៅក្នុងឧបសម្ព័ន្ធ ក និយមន័យនៃពាក្យ "អភិបាលភាព" ត្រូវបានលុបចោល។

ឃ៨ នៅក្នុងឧបសម្ព័ន្ធ ខ, កថាខណ្ឌ ខ១៣ និង ខ៦៣(ង) ត្រូវបានកែប្រែដូចខាងក្រោម:

ខ១៣ សេចក្តីណែនាំនៅក្នុង~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ អន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស~~និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក~~*ត្រូវបានគេប្រើដើម្បីកំណត់រកត្រូវបានគេប្រើដើម្បីកំណត់រកអ្នកទិញ--អង្គភាពដែលទទួលបានអភិបាលភាពលើអ្នកលក់។ប្រសិនបើ

សមាយោគអាជីវកម្មបានកើតឡើង ប៉ុន្តែអនុវត្តសេចក្តីណែនាំនៅក្នុង~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០

មិនបង្ហាញឱ្យច្បាស់លាស់អង្គភាពធ្វើសមាយោគមួយណាដែលជាអ្នកទិញ បណ្តាកត្តាដែលមាននៅក្នុងកថាខណ្ឌខ១៤-កថាខណ្ឌខ១៨ត្រូវតែបានពិចារណា នៅក្នុងការកំណត់នោះ។

ខ៦៣ ឧទាហរណ៍ អំពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនានា ដែលផ្តល់សេចក្តីណែនាំ អំពីការវាស់វែងជាបន្តបន្ទាប់ និង គណនេយ្យសម្រាប់ទ្រព្យសកម្មបានទិញនិងបំណុលបានទទួលយកឬបានកើតឡើងនៅក្នុងសមាយោគអាជីវកម្ម រួមមានៈ

(ក)..............

(ង)~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ផ្តល់សេចក្តីណែនាំអំពី គណនេយ្យសម្រាប់ការផ្លាស់ប្តូរនៅក្នុងភាគកម្មកម្មសិទ្ធិរបស់ក្រុមហ៊ុនមេនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធបន្ទាប់ពីទទួលបានអភិបាលភាព។

## ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៧ *ឧបករណ៍ហិរញ្ញវត្ថុៈ ការលាតត្រដាងព័ត៌មាន*

ឃ៩ កថាខណ្ឌ ៣(ក) ត្រូវបានកែប្រែ និងកថាខណ្ឌ ៤៤ណ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៣ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះត្រូវបានអនុវត្តគ្រប់អង្គភាពទាំងអស់ ចំពោះគ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ៖

(ក) ភាគកម្មទាំងនោះ នៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ ក្រុមហ៊ុនញ្ញាតិសម្ពន្ធ័ឬក្រុមហ៊ុនរួមទុនដែលត្រូវបានរាប់បញ្ចូល ដោយអនុលោមតាម<u>ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស,*</u> ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧របាយការណ៍ហិរញ្ញវត្ថុសមាសនិង~~របាយការណ៍ហិរញ្ញវត្ថុដោយឡែក, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ <u>និងក្រុមហ៊ុន រួមទុន</u> ឬ ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ ប៉ុន្តែ ក្នុងករណីខ្លះ ស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ ឬ ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~ អនុញ្ញាតិឲ្យអង្គភាពគណនាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញ្ញាតសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុនដោយប្រើស្តង់ដារគណនេយ្យអន្តរជាតិ៣៩, ក្នុងករណីទាំងនោះ,......។

៤៤ណ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយក្នុងខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៣។

អង្គភាព ត្រូវអនុវត្តកំណែប្រែនោះ នៅពេលខ្លួនអនុវត្តស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ឧបករណ៍ហិរញ្ញវត្ថុ (បានចេញផ្សាយនៅខែវិច្ឆិកា ឆ្នាំ២០០៩)

ឃ១០ កថាខណ្ឌ ៨.១.២ ត្រូវបានបន្ថែមដូចខាងក្រោម:

៨.១.២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស,* និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមគ្នា* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ គ៨ និងលុបចោលចំណងជើងខាងលើ កថាខណ្ឌ គ៨ និង កថាខណ្ឌ គ១៨-គ២៣។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលដែលខ្លួនអនុវត្ត ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

ឃ១១ នៅក្នុងឧបសម្ព័ន្ធ គ កថាខណ្ឌ១៨ និង គ១៩ និងចំណងជើងពីមុខ កថាខណ្ឌ គ១៨ និង គ១៩ ត្រូវបានលុបចោល និងកថាខណ្ឌ គ៨ ត្រូវបានកែប្រែដូចខាងក្រោម:

គ៨ ៣ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនេះ ត្រូវតែបានអនុវត្ត ដោយគ្រប់អង្គភាពទាំងអស់ សម្រាប់គ្រប់ប្រភេទ នៃឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ:

(ក) ភាគកម្មទាំងនោះនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញ្ញាតិសម្ពន្ធ័ ឬក្រុមហ៊ុនរួមទុន ដែលត្រូវបានរាប់បញ្ចូលដោយអនុលោម

តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស,* ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិង*~~*របាយការណ៍ហិរញ្ញវត្ថុដោយឡែក,* ឬស្តង់ដារគណនេយ្យអន្តរជាតិ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន* ឬ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~ ~~*ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ ប៉ុន្តែក្នុងករណីខ្លះ ស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ ឬ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~អនុញ្ញាតិឲ្យអង្គភាពគណនាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញ្ញាតសម្ព័ន្ធឬក្រុមហ៊ុនរួមទុនដោយប្រើស្តង់ដារគណនេយ្យអន្តរជាតិ៣៩ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, ក្នុងករណីទាំងនោះ,......។

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ៩ ឧបករណ៍ហិរញ្ញវត្ថុ (បានចេញផ្សាយនៅខែវិច្ឆិកា ឆ្នាំ២០១០)**

---

យ១២ កថាខណ្ឌ៣.២.១ ត្រូវបានកែប្រែ និងកថាខណ្ឌ ៧.១.២ ត្រូវបានបន្ថែម ដូចខាងក្រោម:

៣.២.១ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស, កថាខណ្ឌ៣.២.២ -- កថាខណ្ឌ ៣.២.៩, កថាខណ្ឌ ខ៣.១.២ និង ខ៣.២.១ -- កថាខណ្ឌ ៣.២.៧ ត្រូវបានអនុវត្តក្នុងកម្រិតនៃការធ្វើសមាស។ ដូច្នេះ ជាដំបូង អង្គភាពត្រូវធ្វើ សមាសរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ដោយអនុលោមតាម ~~ស្តង់ដារគណនេយ្យអន្តរជាតិ ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស*~~*និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*~~និង ~~SIC-១២ *ការធ្វើសមាស អង្គភាពមានគោលបំណងពិសេស*~~ និង បន្ទាប់មកអនុវត្ត កថាខណ្ឌ ~~៣.២.២-កថាខណ្ឌ ៣.២.៩, កថាខណ្ឌ ខ៣.១.២ និង កថាខណ្ឌ ខ៣.២.១ -កថាខណ្ឌ ខ៣.២.៧~~ ទាំងនោះចំពោះលទ្ធផលរបស់សមុទាយ។

៧.១.២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ គ២៣--គ២៨ និងចំណងជើងពាក់ពន្ធ័។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេល

ដែលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

ឃ១៣ នៅក្នុងឧបសម្ពន្ធ ខ កថាខណ្ឌ ខ៣.២.១ --ខ៣.២.៣ និងកថាខណ្ឌ ខ៥.៧.១៥ ត្រូវបានកែប្រែដូចខាងក្រោមៈ

នៅក្នុងកថាខណ្ឌ ខ៣.២.១, “(រួមមានទាំង អង្គភាពមានគោលបំណងពិសេស)” នៅក្នុងប្រអប់ដំបូងនៃតារាង លំហូរត្រូវបានលុបចោល។

ខ៣.២.២ ស្ថានភាពដែលបានបរិយាយនៅក្នុងកថាខណ្ឌ៣.២.៤(ខ) (នៅពេលដែល អង្គភាព រក្សាទុកសិទ្ធិតាមកុងត្រា ដើម្បីទទួលបានសាច់ប្រាក់ ពីទ្រព្យសកម្មហិរញ្ញវត្ថុ, ប៉ុន្តែទទួលយកកាតព្វកិច្ចដែលបញ្ញត្តិដោយកិច្ចសន្យាដើម្បីបង់សងសាច់ប្រាក់ទៅអ្នកទទួលមួយ ឬច្រើននាក់) កើតឡើង ជាឧទាហរណ៍ ប្រសិនបើអង្គភាពគឺជា~~អង្គភាពមានគោលបំណងពិសេស ឬ~~ បរធនបាល,និងបោះផ្សាយឲ្យក្រុមហ៊ុនវិនិយោគនូវភាគកម្មអត្ថប្រយោជន៍នៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលខ្លួនកាន់កាប់ និងផ្តល់សេវាកម្ម នៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ។ នៅក្នុងករណីនេះ ទ្រព្យសកម្ម ហិរញ្ញវត្ថុមានគុណវុឌ្ឍសម្រាប់ការមិនទទួលស្គាល់ ប្រសិនបើលក្ខខណ្ឌនានានៅក្នុងកថាខណ្ឌ៣.២.៥ និង ៣.២.៦ ត្រូវបានបំពេញ។

ខ៣.២.៣ នៅក្នុងការអនុវត្តន៍ កថាខណ្ឌ៣.២.៥, អង្គភាពអាចជាឧទាហរណ៍ អ្នកបង្កើតដំបូងនៃទ្រព្យសកម្ម ហិរញ្ញវត្ថុឬអាចជាច្រក នៃលំហូរសាច់ប្រាក់ចំពោះក្រុមហ៊ុនវិនិយោគដែលជាភាគីទីបីដែលមិនពាក់ព័ន្ធ។

ខ៥.៧.១៥ ខាងក្រោមគឺជាឧទាហរណ៍ស្តីអំពីហានិភ័យ នៃលទ្ធផលពាក់ព័ន្ធ នឹងទ្រព្យសកម្មៈ

(ក) ....

(ខ) បំណុលដែលបោះផ្សាយដោយ~~អង្គភាពមានគោលបំណងពិសេស~~ អង្គភាពមានរចនាសម្ព័ន្ធមានចរិតលក្ខណៈដូចខាងក្រោម។ អង្គភាព~~មានគោលបំណងពិសេស~~ត្រូវបានបំបែកចេញពីគ្នាតាមផ្លូវច្បាប់ដូច្នេះទ្រព្យសកម្មនៅក្នុងអង្គភាព~~មានគោលបំណងពិសេស~~គឺជាទ្រព្យសកម្មដែលបានការពារសម្រាប់ជាអត្ថប្រយោជន៍របស់ក្រុមហ៊ុនវិនិយោគ បើទោះបីជាវាស្ថិតនៅក្នុងស្ថានភាពក្ស័យធនក៏ដោយ។ អង្គភាព~~មានគោលបំណងពិសេស~~ មិនមានពាក់ព័ន្ធនឹងប្រតិបត្តិការផ្សេងទៀតណា ហើយទ្រព្យសកម្មនៅក្នុងអង្គភាព~~មានគោលបំណងពិសេស~~មិនអាចត្រូវបានដាក់បញ្ចាំឡើយ។បរិមាណដែលត្រូវបង់សងទៅឲ្យវិនិយោគិនរបស់អង្គភាព ~~មានគោលបំណងពិសេស~~ តែនៅពេលដែលទ្រព្យសកម្មដែលបានការពារបង្កើតបានសាច់ប្រាក់។ដូច្នេះ........

ឃ១៤ នៅក្នុងឧបសម្ព័ន្ធ គ, កថាខណ្ឌ គ២៣ និង គ២៤ និងចំណងជើងនៅមុខកថាខណ្ឌគ២៣ ត្រូវបានលុបចោល ហើយកថាខណ្ឌ គ១១ និង គ៣០ ត្រូវបានកែប្រែ ដូចខាងក្រោមៈ

គ១១ ៣ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះត្រូវតែបានអនុវត្តដោយគ្រប់ប្រភេទអង្គភាព សម្រាប់គ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុ លើកលែងតែ:

(ក) ភាគកម្មទាំងនោះនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធក្រុមហ៊ុនញ្ញាតិសម្ព័ន្ធឬក្រុមហ៊ុនរួមទុនដែលត្រូវបានរាប់បញ្ចូលដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស,* ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិង*~~*របាយការណ៍ហិរញ្ញវត្ថុដោយឡែក,* ឬស្តង់ដារគណនេយ្យអន្តរជាតិ២៨*ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធនិងក្រុមហ៊ុនរួមទុន* ឬ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ ប៉ុន្តែក្នុងករណីខ្លះ ស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ ឬ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~អនុញ្ញាតិឲ្យអង្គភាពគណនាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញ្ញាតសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ដោយប្រើស្តង់ដារ ៣៩ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, ក្នុងករណីទាំងនោះ,......។

គ៣០ **៤** ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនេះត្រូវតែបានអនុវត្តដោយគ្រប់ប្រភេទអង្គភាពសម្រាប់គ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុលើកលែងតែ:

**(ក)** ភាគកម្មទាំងនោះនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធឬក្រុមហ៊ុនរួមទុនដែលត្រូវបានរាប់បញ្ចូលដោយអនុលោម តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស,* ស្តង់ដារគណនេយ្យអន្តរជាតិ ២៧~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍*~~ *ហិរញ្ញវត្ថុដោយឡែក,* ឬស្តង់ដារគណនេយ្យអន្តរជាតិ២៨*ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនិងក្រុមហ៊ុនរួមទុន* ~~ឬស្តង់ដារគណនេយ្យអន្តរជាតិ៣១*ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។*~~ ប៉ុន្តែក្នុងករណីខ្លះ ស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬស្តង់ដារគណនេយ្យអន្តរជាតិ២៨~~ឬស្តង់ដារគណនេយ្យអន្តរជាតិ៣១~~អនុញ្ញាតិឲ្យអង្គភាពគណនាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញាតសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ដោយប្រើស្តង់ដារគណនេយ្យអន្តរជាតិ ៣៩ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៩, ក្នុងករណីទាំងនោះ,......។

ឃ១៥ កថាខណ្ឌ៤និង កថាខណ្ឌ១២៣ ត្រូវបានកែប្រែ ហើយ កថាខណ្ឌ ១៣៩ជ ត្រូវបានបន្ថែម ដូចខាងក្រោម:

៤ ស្តង់ដារនេះ មិនអនុវត្តចំពោះរចនាសម្ពន្ធ័ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុបំព្រួញក្នុងអំឡុងពេល ដែលបានរៀបចំដោយអនុលោមតាម ស្តង់ដារគណនេយ្យអន្តរជាតិ ៣៤ *ការរាយការណ៍ហិរញ្ញវត្ថុ ក្នុងអំឡុងពេល*។ ទោះបីជាយ៉ាងណា, កថាខណ្ឌ ១៥--៣៥ អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ បែបនោះ។ ស្តង់ដារនេះអនុវត្តដូចគ្នាចំពោះគ្រប់អង្គភាពទាំងអស់ ដោយរួមមានទាំងអង្គភាព ដែលបង្ហាញរបាយការណ៍សមាស ដោយអនុលោមតាម *ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ១០ របាយការណ៍ហិរញ្ញវត្ថុសមាស* និង អង្គភាពទាំងឡាយណាដែលបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ដូចបានកំណត់ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាស*~~*និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក*។

១២៣ នៅក្នុងដំណើការ នៃការអនុវត្ត គោលនយោបាយគណនេយ្យរបស់អង្គភាព អ្នកគ្រប់គ្រង ធ្វើការវិនិច្ឆ័យជាច្រើនផ្សេងៗគ្នា, លើកលែងតែ ពាក់ពន្ធ័នឹងការប៉ាន់ស្មាន ដែលអាចមានផល

ប៉ះពាល់ជាដុំកំភួនលើ បរិមាណដែលអង្គភាពទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ជាឧទាហរណ៍ អ្នកគ្រប់គ្រងអាចធ្វើការវិនិច្ឆ័យដើម្បីកំណត់៖

(ក) ....

(ខ) ដោយលក្ខណៈជាដុំកំភួន នៅពេលដែលរាល់ហានិភ័យ និងផលចំណេញចំបងៗនៃកម្មសិទ្ធិរបស់ ទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មភតិសន្យាត្រូវបានផ្ទេរទៅអង្គភាពផ្សេងទៀត, និង

(គ) ដោយសារសារៈសំខាន់ ថាតើចំណូលពីការលក់ទំនិញដ៏ជាក់លាក់មួយគឺជាកិច្ចព្រមព្រៀងហិរញ្ញប្រទានឬយ៉ាណា និងហេតុដូច្នេះមិនធ្វើឲ្យមានការកើនចំណូលឡើយ, ~~និង~~

(ដ) ~~ថាតើសារៈសំខាន់នៃទំនាក់ទំនងរវាងអង្គភាពនិងអង្គភាពមានគោលបំណងពិសេសបង្ហាញថា អង្គភាពធ្វើអភិបាលភាពលើលើអង្គភាពមានគោលបំណងពិសេសឬយ៉ាងណា។~~

១៣៩ជ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២ ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៤, កថាខណ្ឌ១១៩, កថាខណ្ឌ១២៣ និងកថាខណ្ឌ១២៤។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១២ ។

ឃ១៦ កថាខណ្ឌ៤២ខ ត្រូវបានកែប្រែ ហើយកថាខណ្ឌ ៥៧ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៤២ខ ការផ្លាស់ប្តូរភាគកម្មកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ ដែលមិនបណ្តាលឲ្យបាត់បង់អភិបាលភាព ដូចជាការទិញ ឬការលក់អាជីវកម្ម ដែលបានធ្វើដោយក្រុមហ៊ុនមេនៃឧបករណ៍ហិរញ្ញវត្ថុកម្មសិទ្ធិរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័ត្រូវបានរាប់ថាជាប្រតិបត្តិការពាក់ពន្ធ័នឹងទ្រព្យម្ចាស់

(មើល~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*~~*និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក*(ដូចបានកែប្រែនៅឆ្នាំ២០០៨),~~។

ដោយយោងតាមនោះ, .........

៥៧ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ ៣៧ កថាខណ្ឌ៣៨ និង កថាខណ្ឌ៤២ខ និងបានលុបចោលកថាខណ្ឌ ៥០(ខ)។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

ឃ១៧ [មិនអាចអនុវត្តនតាមការតម្រូវ]

ឃ១៨ កថាខណ្ឌ១៩ កថាខណ្ឌ៤៥ និង កថាខណ្ឌ៤៦ ត្រូវបានកែប្រែហើយ កថាខណ្ឌ ៦០ច ត្រូវបានបន្ថែម ដូចខាងក្រោមៈ

១៩ ស្តង់ដារនេះក៏អនុញ្ញាតិឲ្យអង្គភាពឯករាជ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឬអង្គភាពមួយរៀបចំរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ ២៧ ~~របាយការណ៍ហិរញ្ញវត្ថុសមាសនិង~~របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកដើម្បីដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួនដោយប្រើរូបិយបណ្ណ៍បរទេសណាមួយ( ឬរូបិយបណ្ណ៍ច្រើន)។ ប្រសិនបើ........

៤៥ ការរួមបញ្ចូលលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិការបរទេសជាមួយប្រតិបត្តិការរបស់អង្គភាពរាយការណ៍ អនុវត្តតាម បែបបទនៃការធ្វើសមាសធម្មតា, ដូចជា ការបំបាត់ចោលសមតុល្យ របស់អន្តោសមុទាយ និងប្រតិបត្តិការអន្តោសមុទាយរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ (មើល~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*និង ~~ស្តង់ដារគណនេយ្យ~~

~~អន្តរជាតិ៣១~~

~~ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន)~~។ទោះជាយ៉ាងណាក៏ដោយ........

៤៦ នៅពេលដែល របាយការណ៍ហិរញ្ញវត្ថុរបស់ប្រតិបត្តិការបរទេស មានកាលបរិច្ឆេទខុសគ្នាពីកាលបរិច្ឆេទរបស់អង្គភាពរាយការណ៍, ជាធម្មតា ប្រតិបត្តិការបរទេសនោះរៀបចំរបាយការណ៍ហិរញ្ញវត្ថុបន្ថែម ទៅតាមកាលបរិច្ឆេទរបស់របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពរាយការណ៍។ នៅពេលដែលប្រតិបត្តិការបរទេសនោះមិនធ្វើដូច្នេះទេ ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ អនុញ្ញាតិនូវការប្រើប្រាស់កាលបរិច្ឆេទខុសគ្នាមួយដែលភាពខុសគ្នានោះមិនឲ្យលើសរយៈពេលបីខែឡើយ ហើយការកែសម្រួលត្រូវតែបានធ្វើឡើងសម្រាប់ផលប៉ះពាល់នៃប្រតិបត្តិការសំខាន់ៗ ឬ ព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងរវាងកាលបរិច្ឆេទខុសគ្នានោះ។ នៅក្នុងករណីបែបនេះទ្រព្យសកម្ម និង បំណុលរបស់ប្រតិបត្តិការបរទេសត្រូវបានបកប្រែតាមអត្រាប្តូរប្រាក់នៅចុងការិយបរិច្ឆេទរបស់អង្គភាពរាយការណ៍របស់ប្រតិបត្តិការបរទេស។ការកែសម្រួលត្រូវបានធ្វើឡើងសម្រាប់បម្រែបម្រួលអត្រាប្តូរប្រាក់បរទេសសំខាន់ៗរហូតដល់ចុងការិយបរិច្ឆេទរបស់អង្គភាពរាយការណ៍ដោយអនុលោមតាម~~ស្តង់ដារគណនេយ្យ~~

~~អន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ ។ ដូចគ្នានេះដែរ........

៦០ច ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ ៣(ខ), កថាខណ្ឌ៨, កថាខណ្ឌ១១, កថាខណ្ឌ១៨, កថាខណ្ឌ១៩, កថាខណ្ឌ៣៣, កថាខណ្ឌ៤៤ --កថាខណ្ឌ៤៦, និងកថាខណ្ឌ ៤៨ក។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្ត ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ ។

## ស្តង់ដារគណនេយ្យអន្តរជាតិ ២៤ ការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ

ឃ១៩ កថាខណ្ឌ៣ត្រូវបានកែប្រែដូចខាងក្រោមៈ

៣ **ស្តង់ដារនេះតម្រូវនូវការលាតត្រដាងអំពីទំនាក់ទំនងភាគីពាក់ព័ន្ធ ប្រតិបត្តិការនិងសមតុល្យជាប់ជំពាក់, រួមមានទាំងការសន្យា (commitment) នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស និង របាយការណ៍ ហិរញ្ញវត្ថុ ដាច់ដោយឡែករបស់ក្រុមហ៊ុនមេ, ~~ក្រុមហ៊ុនរួមទុន~~ ឬ បណ្តាវិនិយោគិនដែល<u>មានអភិបាលភាពរួម ឬ មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុនរងការវិនិយោគ</u>ដែលបានដាក់បង្ហាញ ដោយអនុលោមតាម<u>ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស*</u> *ឬ***

**ស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~របាយការណ៍ហិរញ្ញវត្ថុសមាសនិង~~**

**របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក។ស្តង់ដារនេះក៏អនុវត្តចំ**

**ពោះ របាយការណ៍ហិរញ្ញវត្ថុនិមួយៗផងដែរ។**

នៅក្នុងកថាខណ្ឌ៩ និយមន័យ “អភិបាលភាព” “អភិបាលភាពរួម” និង “ឥទ្ធិពលខ្លាំង” ត្រូវបានលុបចោល និងប្រយោគមួយ ត្រូវបានបន្ថែមដូចខាងក្រោម:

**ពាក្យ “អភិបាលភាព” “អភិបាលភាពរួម” និង “ឥទ្ធិពលខ្លាំង” ត្រូវបានឲ្យនិយមន័យនៅក្នុង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀង រួមទុន* និងស្តង់ដារគណនេយ្យអន្តរជាតិ ២៨ *ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន* និង ត្រូវបានប្រើនៅក្នុងស្តង់ដារនេះជាមួយនឹងអត្ថន័យជាក់លាក់នៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទាំងនោះ។**

កថាខណ្ឌ២៨ក ត្រូវបានបន្ថែមដូចខាងក្រោម:

២៨ក ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១*កិច្ចព្រមព្រៀងរួមទុន* និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២ ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ ៣, កថាខណ្ឌ៩, កថាខណ្ឌ១១(ខ), កថាខណ្ឌ១៥, កថាខណ្ឌ១៩(ខ) និង(ង) និងកថាខណ្ឌ២៥។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំង

នោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១២។

## ស្តង់ដារគណនេយ្យអន្តរជាតិ ២៧ របាយការណ៍ហិរញ្ញវត្ថុសមាស និង របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក

ឃ២០ នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២៧ របាយការណ៍ហិរញ្ញវត្ថុសមាស និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក, ការតម្រូវទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុសមាស ត្រូវបានលុបចោល និងដាក់ចូលទៅក្នុង ស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិ១០ នៅកន្លែងដែលសមស្រប។ ការតម្រូវផ្នែកគណនេយ្យ និងការលាតត្រដាងពិត័មាន សម្រាប់របាយ-ការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកដែលនៅមាននៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២៧, ចំណងជើងត្រូវ បានកែប្រែទៅជា *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក,* កថាខណ្ឌដែលនៅសេសសល់ត្រូវបានដាក់លេខឡើងវិញជាបន្តបន្ទាប់,ក្របខណ្ឌនៃស្តង់ដារត្រូវបានកែសម្រួល ហើយការផ្លាស់ប្តូរនៃពណ្ណាធីការត្រូវបានធ្វើ។ ការតម្រូវផ្នែកគណនេយ្យ និងការលាតត្រដាងពិត័មាន ដែលមាននៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២៧ (ដូចបានកែប្រែ នៅឆ្នាំ២០១១) ក៏ត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងសេចក្តីណែនាំនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១២ និងស្តង់ដារគណនេយ្យអន្តរជាតិ២៨ (ដូចបានកែប្រែនៅក្នុងឆ្នាំ២០១១)។ សេចក្តីលំអិតនៃគោលបំណងរបស់កថាខណ្ឌនានា

នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ២៧ (ដូចបានកែប្រែ នៅក្នុងឆ្នាំ២០០៨) មាននៅក្នុងតារាងមាលីសព្ទ ដែលបានភ្ជាប់ជាមួយស្តង់ដារគណនេយ្យអន្តរជាតិ ២៧ (ដូចបានកែប្រែ នៅឆ្នាំ២០១១)។

## ស្តង់ដារគណនេយ្យអន្តរជាតិ៣២ ឧបករណ៍ហិរញ្ញវត្ថុៈ ការដាក់បង្ហាញ

ឃ២១ កថាខណ្ឌ ៤(ក) ត្រូវបានកែប្រែ ហើយកថាខណ្ឌ៩៧ថ ត្រូវបានបន្ថែម ដូចខាងក្រោមៈ

៤ ស្តង់ដារនេះត្រូវអនុវត្តដោយគ្រប់អង្គភាពអាជីវកម្ម ចំពោះគ្រប់រាល់ឧបករណ៍ហិរញ្ញវត្ថុ លើកលងតែៈ

(ក) ភាគកម្មទាំងនោះ នៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញ្ញាតិសម្ពន្ធ័, ឬក្រុមហ៊ុនរួមទុន ដែលត្រូវបានរាប់បញ្ចូលដោយយោងតាម<u>ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០</u> <u>*របាយការណ៍ហិរញ្ញវត្ថុសមាស*</u>, ស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិង*~~*របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*, <u>ឬ</u> ស្តង់ដារគណនេយ្យអន្តរជាតិ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ* <u>*និងក្រុមហ៊ុនរួមទុន*</u> ~~ឬ ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~ *ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន*។ ប៉ុន្តែនៅក្នុងករណីខ្លះ, ស្តង់ដារគណនេយ្យអន្តរជាតិ២៧, ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨, ~~ឬស្តង់ដារគណនេយ្យអន្តរជាតិ៣១~~

អនុញ្ញាតិឲ្យអង្គភាពគណនាភាគកម្មនៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័, ក្រុមហ៊ុនញ្ញាតិសម្ពន្ធ័ឬ ក្រុមហ៊ុនរួមទុន ដោយប្រើស្តង់ដារគណនេយ្យអន្តរជាតិ៣៩.....

៩៧ថ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ ដែលបាន ចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៤(ក) និង កច២៩។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

ឃ២២ នៅក្នុងឧបសម្ព័ន្ធ កថាខណ្ឌ កច២៩ ត្រូវបានកែប្រែ ដូចខាងក្រោមៈ

កច២៩ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស អង្គភាពបង្ហាញភាគកម្មគ្មានអភិបាលភាព-មានន័យថា ភាគកម្មរបស់ភាគីផ្សេងៗ នៅក្នុងទ្រព្យម្ចាស់ និងប្រាក់ចំណេញរបស់ក្រុមហ៊ុនបុត្រសម្ពន្ធ័របស់ខ្លួន--ដោយអនុលោមតាម ស្តង់ដារគណនេយ្យអន្តរជាតិ១ ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០។ នៅពេល.......

## ស្តង់ដារគណនេយ្យអន្តរជាតិ៣៣ ប្រាក់ចំណេញក្នុងមួយបណ្ណ័ភាគហ៊ុន

ឃ២៣ កថាខណ្ឌ ៤ ត្រូវបានកែប្រែ ហើយកថាខណ្ឌ៧៤ខត្រូវបានបន្ថែម ដូចខាងក្រោមៈ

**៤ នៅពេលអង្គភាព ដាក់បង្ហាញទាំងរបាយការណ៍ហិរញ្ញវត្ថុសមាស និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ដែលបានរៀបចំ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស* និង ស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការហិរញ្ញវត្ថុ*~~ ដាច់ដោយឡែករៀងៗគ្នា, ការលាតត្រដាងដែលបានតម្រូវដោយស្តង់ដារនេះចាំបាច់ត្រូវដាក់បង្ហាញតែ នៅលើមូលដ្ឋាននៃព័ត៌មានសមាសប៉ុណ្ណោះ។ .....**

៧៤ខ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៤ កដាខណ្ឌ៤០ និងកថាខណ្ឌ ក១១។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្ត ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

## ស្តង់ដារគណនេយ្យអន្តរជាតិ៣៦ ការថយចុះតម្លៃរបស់ទ្រព្យសកម្ម

ឃ២៤ កថាខណ្ឌ៤(ក) ត្រូវបានកែប្រែ ហើយកថាខណ្ឌ ១៤០ជ ត្រូវបានបន្ថែមដូចខាងក្រោម:

៤ ស្តង់ដារនេះអនុវត្តចំពោះគ្រប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានចាត់ថ្នាក់ថាជាៈ

(ក) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ដូចបានកំណត់អត្ថន័យនៅក្នុង ~~ស្តង់ដារគណនេយ្យអន្តរជាតិ ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*

(ខ) ......

១៤០ច ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ៤ ចំណងជើងខាងលើកថាខណ្ឌ ១២(ច) និងកថាខណ្ឌ ១២(ច)។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលខ្លួនអនុវត្តស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## ស្តង់ដារគណនេយ្យអន្តរជាតិ ៣៨ *ទ្រព្យសកម្មអរូបិយ*

ឃ២៦ កថាខណ្ឌ៣(ង) ត្រូវបានកែប្រែ ហើយ កថាខណ្ឌ១៣០ច ត្រូវបានបន្ថែមដូចខាងក្រោមៈ

៣ ប្រសិនបើស្តង់ដារផ្សេងទៀតដាក់បញ្ញត្តិអំពីគណនេយ្យសម្រាប់ប្រភេទនៃទ្រព្យសកម្មអរូបិយ, អង្គភាពអនុវត្តត្រូវស្តង់ដារនោះ

ជំនួស ស្តង់ដារនេះ។ ឧទាហរណ៍ ស្តង់ដារនេះមិនអនុវត្តចំពោះ÷

(ក) ......

(ខ) ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកំណត់ នៅក្នុងស្តង់ដារគណនេយ្យអន្តរជាតិ ៣២។ ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួនត្រូវបានគ្របដណ្តប់ដោយ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស,* ស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិង*~~ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក,* និងស្តង់ដារគណនេយ្យអន្តរជាតិ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន* ~~និងស្តង់ដារគណនេយ្យអន្តរជាតិ៣១ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*~~។

(ច) .......

១៣០ច ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ ៣(ង)។ អង្គភាព ត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

---

ឃ២៧ កថាខណ្ឌ ២(ក) និង កថាខណ្ឌ១៥ ត្រូវបានកែប្រែ ហើយកថាខណ្ឌ ១០៣ប ត្រូវបានបន្ថែម ដូចខាងក្រោមៈ

២ ស្តង់ដារនេះត្រូវអនុវត្តដោយគ្រប់ប្រភេទអង្គភាព ចំពោះគ្រប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុទាំងអស់ លើកលែងតែៈ

**(ខ) ភាគកម្មទាំងនោះនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ, ឬ ក្រុមហ៊ុនរួមទុនដែលត្រូវបានរាប់បញ្ចូលដោយយោងតាម <u>ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ *របាយការណ៍ហិរញ្ញវត្ថុសមាស,*</u> ស្តង់ដារគណនេយ្យអន្តរជាតិ២៧ ~~*របាយការណ៍ហិរញ្ញវត្ថុសមាសនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក,*~~ ឬ ស្តង់ដារគណនេយ្យអន្តរជាតិ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ <u>និង ក្រុមហ៊ុនរួមទុន</u>* ឬ ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១~~ *ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន។* ប៉ុន្តែអង្គភាពត្រូវអនុវត្តស្តង់ដារនេះចំពោះភាគកម្មនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធឬ ក្រុមហ៊ុនរួមទុន ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិ២៧,**

**ឬស្តង់ដារគណនេយ្យអន្តរជាតិ២៨, ឬស្តង់ដារគណនេយ្យអន្តរជាតិ ៣១ត្រូវបានរាប់បញ្ចូលនៅក្រោមស្តង់ដារនេះ។**

១៥ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស កថាខណ្ឌ១៦--២៣ និង ឧបសម្ព័ន្ធ ក កថាខណ្ឌ កង៣៤-កង៥២ ត្រូវបានអនុវត្ត នៅក្នុងកម្រិតនៃការធ្វើសមាស។ ដូច្នេះ ជាដំបូង អង្គភាពត្រូវធ្វើសមាសគ្រប់ក្រុមហ៊ុនបុត្រ សម្ព័ន្ធដោយអនុលោមតាមស្តង់~~ដារគណនេយ្យអន្តរជាតិ២៧, និង sic ១២ *ការធ្វើសមាសអង្គភាពមានគោលបំណងពិសេស*~~ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០ និង បន្ទាប់មកអនុវត្តកថាខណ្ឌ១៦-២៣ និង ឧបសម្ព័ន្ធ ក កថាខណ្ឌ កង៣៤- កង៥២ ចំពោះលទ្ធផលរបស់សមុទាយ។

១០៣ប ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ *កិច្ចព្រមព្រៀងរួមទុន* ដែលបានចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០១១ បានកែប្រែកថាខណ្ឌ ២(ក), កថាខណ្ឌ១៥, កថាខណ្ឌ កង៣,កថាខណ្ឌ កង៣៦-កង៣៨ និង កថាខណ្ឌ កង៤១(ក) ។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះ នៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១។

ឃ២៨ នៅក្នុងឧបសម្ព័ន្ធ កថាខណ្ឌ កង៣៦-កង៣៨ ត្រូវបានកែប្រែ ដូចខាងក្រោម៖

នៅក្នុងកថាខណ្ឌកង៣៨, “(រួមទាំង អង្គភាពមានគោលបំណងពិសេស)” នៅក្នុងប្រអប់ទីមួយនៃលំហូរតារាង ត្រូវបានលុបចោល។

កង៣៧ ស្ថានភាពដែលបានបរិយាយនៅក្នុងកថាខណ្ឌ ១៨(ខ) (នៅពេលដែលអង្គភាពរក្សាទុកសិទ្ធិតាមកុងត្រា ដើម្បីទទួលសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ ប៉ុន្តែទទួលយកកាតព្វកិច្ចដែលបញ្ញត្តិដោយកិច្ចសន្យាដើម្បីសងសាច់ប្រាក់ទៅអ្នកទទួលម្នាក់ ឬច្រើននាក់) កើតឡើង ជាឧទាហរណ៍ ប្រសិនបើអង្គភាពគឺជា~~អង្គភាពមានគោលបំណងពិសេស~~ ឬ បរធន, និងបោះផ្សាយទៅវិនិយោគិននូវភាគកម្មដែលមានអត្ថប្រយោជន៍នៅក្នុងទ្រព្យសកម្មហិរញ្ញវត្ថុដែលខ្លួនមានជាកម្មសិទ្ធិ និងការផ្តល់សេវាកម្មរបស់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ។ នៅក្នុងករណីនោះ, ទ្រព្យសកម្មហិរញ្ញវត្ថុមានគុណវុឌ្ឍិសម្រាប់ការមិនទទួលស្គាល់ ប្រសិនបើលក្ខខណ្ឌនានានៅក្នុងកថាខណ្ឌ១៩ និង កថាខណ្ឌ២០ ត្រូវបានបំពេញ។

កង៣៨ នៅក្នុងការអនុវត្ត កថាខណ្ឌ១៩, អង្គភាពអាច ជាឧទាហរណ៍ អ្នកបង្កើតដើមដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ, ឬវាអាចជាក្រុមដែលរួមមាន~~អង្គភាពមានគោមបំណងពិសេសដែលធ្វើសមាស~~ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានទិញយកទ្រព្យសកម្មហិរញ្ញវត្ថុ និង ផ្ទេរសាច់ប្រាក់ទៅវិនិយោគិនជាភាគីទីបីដែលមិនពាក់ព័ន្ធ។

យ២៩ នៅក្នុង “យោងឬសេចក្តីបញ្ជាក់” ការបញ្ចូលសម្រាប់ ស្តង់ដារគណនេយ្យអន្តរជាតិ២៧ និងស្តង់ដារគណនេយ្យអន្តរជាតិ ៣១ ត្រូវបានលុបចោល, ការបញ្ចូល សម្រាប់ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ ត្រូវបានកែប្រែទៅជា “ស្តង់ដារគណនេយ្យអន្តរជាតិ ២៨ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័និងក្រុមហ៊ុនរួមទុន”* និងការបញ្ចូលសម្រាប់ស្តង់ដាររបាយ-ការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០*របាយការណ៍ហិរញ្ញវត្ថុសមាស* និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១ *កិច្ចព្រមព្រៀងរួមទុន* ត្រូវវាបបន្ថែម។ កថាខណ្ឌ៨ត្រូវបានកែប្រែ ហើយ កថាខណ្ឌ១៤ខ ត្រូវបានបន្ថែមដូចខាងក្រោម៖

៨ អ្នកផ្តល់បរិវិសទានត្រូវកំណត់ថាតើខ្លួនមានអភិបាលភាពឬ មានអភិបាលភាពរួមគ្នា ឬ មានឥទ្ធិពលខ្លាំងលើមូលនិធិ ដោយមានសេចក្តីបញ្ជាក់ឬយោងចំពោះ~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០, ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១១និង ស្តង់ដារគណនេយ្យអន្តរជាតិ២៨, ~~ស្តង់ដារគណនេយ្យអន្តរជាតិ៣១, និង sic១២។~~ប្រសិនបើដូច្នោះ, អ្នកផ្តល់បរិវិសទានត្រូវគណនាភាគកម្មរបស់ខ្លួននៅក្នុងមូលនិធិ ដោយយោងតាមស្តង់ដារទាំងនោះ។

១៤ខ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១ ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ៨ និងកថាខណ្ឌ ៩។ អង្គភាពត្រូវអនុវត្តកំណែប្រែទាំងនោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១១។

## IFRIC ១៧ ការបែងចែកទ្រព្យសកម្មរយៈពេលវែងទៅម្ចាស់

ឃ៣០ នៅក្នុង “យោងឬសេចក្តីបញ្ជាក់” ការបញ្ចូលសម្រាប់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០*របាយការណ៍ហិរញ្ញវត្ថុសមាស* ត្រូវបានបន្ថែម។

៧ ដោយអនុលោមតាម កថាខណ្ឌ៥, ការបកស្រាយនេះមិនអនុវត្តទេ នៅពេលដែលអង្គភាពបែងចែកភាគកម្មកម្មសិទ្ធិមួយចំនួននៅក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ័ ប៉ុន្តែនៅរក្សាអភិបាលភាព លើក្រុមហ៊ុនបុត្រសម្ពន្ធ័។ អង្គភាព ដែលធ្វើការបែងចែក ដែលបណ្តាលឲ្យអង្គភាពទទួលស្គាល់ភាគកម្មគ្មានអភិបាលភាព នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដោយរាប់បញ្ចូលការបែងចែកនោះដោយអនុលោមតាម~~ស្តង់ដារគណនេយ្យអន្តរជាតិ២៧~~ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ១០។

១៩ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០ ដែលបានចេញផ្សាយនៅខែឧសភា ឆ្នាំ២០១១ បានកែប្រែ កថាខណ្ឌ៧។

អង្គភាពត្រូវអនុវត្តកំណែប្រែនោះនៅពេលខ្លួនអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ១០។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ